ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១

គណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និង អំពើហិង្សាលើកុមារ

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

ក្រសួងទេសចរណ៍

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ក្រសួងព័ត៌មាន

ក្រសួងមហាផ្ទៃ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងសុខាភិបាល

ក្រសួងយុត្តិធម៌

ក្រសួងធម្មការ និងសាសនា

រចនាដោយ : © UNICEF Cambodia/2017/Youra Soeum និង Graphic Roots

រាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០១៧

# អារម្ភកថា

អំពើហិង្សាលើកុមារកើតមាននៅស្ទើរគ្រប់កន្លែងក្នុងបណ្ដាប្រទេសទាំងអស់ទូទាំងពិភពលោក ដោយមិនប្រកាន់ថាអ្នកមាន ឬអ្នកក្រឡើយ។ បើទោះជាដូច្នេះក្ដី អំពើហិង្សាដែលកុមារបានជួបប្រទះ មិនសូវបានគេមើលឃើញទេ អាស្រ័យដោយមានការលាក់បាំង ឬដោយសារខ្វះព័ត៌មាន និងភស្តុតាងអំពីផលប៉ះពាល់មកលើសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រទេស។

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសកម្ពុជាមានការអភិវឌ្ឍ និងសម្រេចបានសមិទ្ធផលនានាជាច្រើនលើគ្រប់វិស័យ។ រាជរដ្ឋាភិបាលបានប្រកាសនិងផ្សព្វផ្សាយរបាយការណ៍នៃការសិក្សាស្រាវជ្រាវស្ដីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជានៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ និងបានចាប់ផ្ដើមរៀបចំផែនការសកម្មភាពស្ដីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ចាប់ពីខែកក្កដា ឆ្នាំ២០១៥ រហូតដល់ខែកក្កដា ឆ្នាំ២០១៧។

ប្រទេសកម្ពុជាបានចូលរួមក្នុងចលនាសកល ដែលបានអះអាងថា មិនអាចមានហេតុផលណាមួយជាមូលដ្ឋានដែលនាំឱ្យមានការប្រព្រឹត្តអំពើហិង្សាលើកុមារជាដាច់ខាត ហើយវាក៏មិនមែនជាបញ្ហាដែលមិនអាចជៀសវាងបាននោះទេ ប្រសិនបើបុព្វហេតុឫសគល់ត្រូវបានរកឃើញ និងដោះស្រាយ។ ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវស្ដីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ដែលជាការសិក្សាស្រាវជ្រាវថ្នាក់ជាតិ និងលើកដំបូងគេបង្អស់ក្នុងតំបន់អាស៊ី អំពីបញ្ហាអំពើហិង្សាលើកុមារ ដែលបានផ្ដល់ភស្តុតាងអំពីវិសាលភាព និងចរិតនៃអំពើហិង្សាផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត ដែលកុមារី ស្ត្រីវ័យក្មេង កុមារា និងបុរសវ័យក្មេង ក្នុងប្រទេសកម្ពុជាបានជួបប្រទះ។ ការសិក្សាស្រាវជ្រាវស្ដីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាបានរកឃើញថាអំពើហិង្សាលើកុមារ កើតមានឡើង ហើយបានធ្វើឱ្យកុមារមួយចំនួនទទួលរងអំពើហិង្សា ជាច្រើនទម្រង់ ដូចជាអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ខណៈពេលដែលពួកគេចម្រើនវ័យឡើង។ អំពើហិង្សារមែងតែងប្រព្រឹត្តដោយអ្នកដែលកុមារស្រឡាញ់ និង នៅកន្លែងដែលកុមារមានអារម្មណ៍ថាគួរតែមានសុវត្ថិភាព។ របាយការណ៍នេះបានគូសបញ្ជាក់ថា កុមារភាគច្រើនមិនដែលនិយាយជាមួយនរណាម្នាក់អំពីបទពិសោធន៍ដែលពួកគេបានជួបប្រទះ ហើយក៏មិនបានស្វែងរកជំនួយដែរ។ ប៉ុន្តែ នៅពេលដែលពួកគេស្វែងរកជំនួយ គេតែងជួបប្រទះនូវឧបសគ្គជាច្រើនក្នុងការទទួលបានកិច្ចគាំទ្រ។

គំហើញពីការអង្កេតនេះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១។ ផែនការសកម្មភាពនេះ សម្រេចទៅបានតាមរយៈការដឹកនាំ និងសម្របសម្រួលពីសំណាក់សហប្រធានជាន់ខ្ពស់របស់ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កិច្ចសហការភាពជាដៃគូ និងការប្ដេជ្ញាចិត្តដ៏ខ្លាំងក្លាពីបណ្ដាក្រសួងស្ថាប័ន ដែលមានតំណាងនៅក្នុងគណៈកម្មការដឹកនាំពហុវិស័យ និងក្រុមការងារបច្ចេកទេសទាំង៤ នៃគណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និងអំពើហិង្សាលើកុមារ។ សកម្មភាពដែលមានគូសបញ្ជាក់នៅក្នុងផែនការសកម្មភាពនេះ ត្រូវបានតាក់តែងឡើងដើម្បីជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងប្រទេសកម្ពុជាសំដៅអភិវឌ្ឍន៍ និង អនុវត្តយុទ្ធសាស្ត្រទប់ស្កាត់ដែលមានលក្ខណៈកុមារមេត្រីប្រកបដោយប្រសិទ្ធភាព ព្រមទាំងកែលម្អការផ្ដល់សេវាជូនដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ជាពិសេស កុមារា និងកុមារី ដែលបានទទួលរងបទពិសោធន៍ពីអំពើហិង្សា។

ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូជាតិ អន្តរជាតិ មានការតាំងចិត្តខ្ពស់ក្នុងការអនុវត្តការប្ដេជ្ញាចិត្តរបស់ខ្លួនដើម្បីឧត្តមប្រយោជន៍របស់កុមារគ្រប់រូប និងក្រុមគ្រួសាររបស់គេ។ ក្នុងនាមក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យើងខ្ញុំសូមថ្លែងការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះមតិ យោបល់ ពេលវេលា និងកិច្ចខិតខំប្រឹងប្រែងដ៏មានតម្លៃរបស់គណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និង អំពើហិង្សាលើកុមារ ដែលមានតំណាងចូលរួមមកពីក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រសួងធម្មការ និងសាសនា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

តាងនាមឱ្យគណៈកម្មការដឹកនាំ ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានកិត្តិយស និងមោទនភាព ដែលបានសម្របសម្រួលដំណើរការអភិវឌ្ឍផែនការសកម្មភាពនេះ ព្រមទាំងរួមគ្នាបន្តកិច្ចសហប្រតិបត្តិការ ដើម្បីអនុវត្តផែនការសកម្មភាពនេះឱ្យមានប្រសិទ្ធភាព។ ការគាំទ្ររបស់រាជរដ្ឋាភិបាល និងការចូលរួមពីដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាកុមារ និងក្រុមគ្រួសាររបស់ពួកគេ ពិតជាមានសារៈសំខាន់ ដើម្បីសម្រេចឱ្យបាននូវគោលដៅក្នុងការបញ្ចប់អំពើហិង្សាលើកុមារនេះ។ យើងរួមគ្នា ក្រោកឈរឡើងដោយមិនអធ្យាស្រ័យជាដាច់ខាត ចំពោះអំពើហិង្សា និងការរំលោភបំពានលើកុមារ។

| | |
|---|---|
| រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ | រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ |
| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **ក្រសួងកិច្ចការនារី** |
| **វង សូត** | **វេជ្ជ. អ៊ឹង កន្ថាផាវី** |

# សេចក្តីថ្លែងអំណរគុណ

គណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និងអំពើហិង្សាលើកុមារ ដែលមានក្រសួងកិច្ចការនារីជាប្រធាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាអនុប្រធាន និងមានក្រសួងដទៃទៀតចូលរួម សូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោកស្រី លោក ដែលបានចូលរួម និងរួមចំណែកផ្តល់វិភាគទានគ្រប់បែបយ៉ាងក្នុងការអភិវឌ្ឍផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេស ចំពោះសមាជិក សមាជិកា នៃគណៈកម្មការដឹកនាំអន្តរក្រសួងស្តីពីអំពើហិង្សាលើកុមារសម្រាប់ការប្តេជ្ញាចិត្ត និងទិសដៅបច្ចេកទេសនៅក្នុងដំណើរការទាំងមូល ក្នុងនោះរួមមាន ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រសួងធម្មការ និងសាសនា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ ក្រសួងព័ត៌មាន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការយូនីសេហ្វ សម្រាប់កិច្ចគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលនៃក្រុមការងារបច្ចេកទេស ដែលរួមមានជាអាទិ៍ មន្ទីរពេទ្យកុមារអង្គរ អង្គការជំហានដំបូង អង្គការ Friends International អង្គការ GIZ អង្គការ Global Alliance for Children អង្គការ ICS-SP អង្គការ International Justice Mission អង្គការម្លប់ឫស្សី សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGO-CRC) អង្គការ Plan International សាកលវិទ្យាល័យភូមិន្ទភ្នំពេញ អង្គការ Save the Children អង្គការសេវាសង្គមកិច្ចកម្ពុជា អង្គការមូលនិធិអាស៊ី អង្គការ UNWOMEN អង្គការ UNFPA អង្គការ WHO អង្គការវីនរ៉ក់អន្តរជាតិ និង អង្គការទស្សនៈពិភពលោក។ សូមថ្លែងអំណរគុណចំពោះជំនួយហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកាណាដា តាមរយៈ the Global Affairs Canada និង the Together for Girls ដែលបានគាំទ្រដល់ការរៀបចំផែនការសកម្មភាពនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះក្រុមទីប្រឹក្សានៃមជ្ឈមណ្ឌលច្បាប់កូរ៉ាម[1]សម្រាប់កុមារ ដែលបានសម្របសម្រួលធ្វើការពិនិត្យឯកសារ និងការស្រាវជ្រាវ ការវិភាគទិន្នន័យមធ្យម និងទ្រឹស្តីនៃការផ្លាស់ប្តូរ ស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ដែលជាមូលដ្ឋាននៃការកសាងផែនការសកម្មភាពនេះ។

ជាចុងក្រោយ យើងខ្ញុំសូមទទួលស្គាល់ចំពោះវិភាគទានរួមចំណែកដ៏ធំធេង ពីកុមារី កុមារា និងគ្រួសាររបស់ពួកគេជាច្រើនដែលបានចែករំលែកឱ្យយើងបានដឹងអំពីរឿងរ៉ាវនៃជីវិត ព្រមទាំងសេចក្តីលម្អិតដ៏ក្រៀមក្រំនៃបទពិសោធន៍ក្នុងការទទួលរងអំពើហិង្សា ការកេងប្រវ័ញ្ច និងការមិនអើពើ។ រឿងរ៉ាវរបស់ពួកគេ បានផ្តល់នូវព័ត៌មានដ៏មានសារៈប្រយោជន៍ ដែលបានជួយយើងឱ្យយល់កាន់តែច្បាស់អំពីស្ថានភាពនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា និងបានកំណត់ទ្រង់ទ្រាយនៃចំណាត់ការសម្រាប់ការបង្ការនិងឆ្លើយតប ដូចដែលបានបង្ហាញនៅក្នុងផែនការសកម្មភាពនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់ក្មួយៗក្រុមកុមារវ័យជំទង់ និងក្រុមយុវជន ដែលបានចូលរួមយ៉ាងទៀងទាត់នៅក្នុងរាល់កិច្ចប្រជុំក្រុមការងារបច្ចេកទេស និងដែលអាចជាតំណាងឱ្យសំឡេងរបស់កុមារទូទាំងប្រទេសកម្ពុជា។ វិភាគទានដ៏មានតម្លៃនេះ នឹងផ្តល់នូវអត្ថប្រយោជន៍ទៅលើជីវិតរស់នៅរបស់កុមារ និងគ្រួសារជាច្រើនទៅអនាគត ខណៈពេលដែលប្រទេសកម្ពុជាបន្តបោះជំហានទៅមុខក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ។

1 មជ្ឈមណ្ឌលច្បាប់កូរ៉ាំសម្រាប់កុមារ ជាស្ថាប័នផ្តល់ទីប្រឹក្សាអំពីការសិក្សាស្រាវជ្រាវ និងផ្តល់ព័ត៌មាន និងជំនួយផ្នែកច្បាប់ដល់កុមារ មនុស្សវ័យក្មេង ក្រុមគ្រួសារកុមារនិងអ្នកថែទាំកុមារដោយឥតគិតកម្រៃ

# មាតិកា


**អារម្ភកថា** ........ ii

**សេចក្តីថ្លែងអំណរគុណ** ........ iv

**សេចក្តីសង្ខេប** ........ viii

**១. សេចក្តីផ្តើម** ........ ១

១.១. សេចក្តីសម្រេចដើម្បីរៀបចំផែនការសកម្មភាព ........ ១

១.២. វិធីសាស្ត្រក្នុងការរៀបចំផែនការសកម្មភាព ........ ១

**២. ចលនាសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ** ........ ៣

២.១. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ភាពជាដៃគូសកល ........ ៣

២.២. យុទ្ធសាស្ត្រចំនួនប្រាំពីរសម្រាប់បញ្ចប់អំពើហិង្សាលើកុមារ (**INSPIRE**) ........ ៤

២.៣. ការឆ្លើយតបរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ចំពោះអំពើហិង្សាលើកុមារ ........ ៤

២.៤. ការឆ្លើយតបរបស់កម្ពុជាចំពោះអំពើហិង្សាលើកុមារ ........ ៤

**៣. អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា** ........ ៦

៣.១. គោលគំនិត និង និយមន័យសំខាន់ៗ ........ ៦

៣.២. ស្ថានភាពនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ........ ៦

៣.២.១. អំពើហិង្សាផ្លូវកាយ ........ ៧

៣.២.២. អំពើហិង្សាផ្លូវភេទ ........ ៧

៣.២.៣. អំពើហិង្សាផ្លូវចិត្ត ........ ៨

៣.២.៤. ការមិនអើពើចំពោះកុមារ ........ ៩

៣.២.៥. អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ ........ ៩

៣.២.៦. ពលកម្មកុមារ ........ ៩

៣.២.៧. ការជួញដូរកុមារ ........ ១០

៣.២.៨. អំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត ........ ១០

៣.២.៩. កុមារដែលមានការប្រឈមខ្ពស់ទៅនឹងអំពើហិង្សា ........ ១០

៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍផែនការសកម្មភាព ............ ១២
៤.១. ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារ ............ ១២
៤.២. គោលការណ៍ទូទៅ និងអភិក្រម ............ ១៣
៤.៣. វិសាលភាពនៃផែនការ ............ ១៤
៤.៤. យុទ្ធសាស្ត្រសំខាន់ៗ ............ ១៤
៤.៤.១. យុទ្ធសាស្ត្រទី១ ៖ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ ............ ១៥
៤.៤.២. យុទ្ធសាស្ត្រទី២ ៖ ការទប់ស្កាត់បឋម ............ ១៥
៤.៤.៣. យុទ្ធសាស្ត្រទី៣ ៖ សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ ............ ១៥
៤.៤.៤. យុទ្ធសាស្ត្រទី៤ ៖ ការបង្កើត និងការធ្វើវិសោធនកម្មច្បាប់ និង ការអនុវត្តគោលនយោបាយ ............ ១៦
៤.៤.៥. យុទ្ធសាស្ត្រទី៥ ៖ ការពិនិត្យតាមដាន និងវាយតម្លៃ ............ ១៦
៥. ក្របខ័ណ្ឌលទ្ធផលផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ............ ១៧
៦. ការពិនិត្យតាមដាន ការរាយការណ៍ និង ការវាយតម្លៃ ............ ៥០
៧. ការគណនាថ្លៃចំណាយនៃផែនការសកម្មភាព ............ ៥០
៨. សេចក្តីសន្និដ្ឋាន ............ ៥០
៩. សន្ទានុក្រម ............ ៥១
១០. ឯកសារយោង ............ ៥៧
ឧបសម្ព័ន្ធ ............ ៦១
ឧបសម្ព័ន្ធ ១ ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង គោលដៅពាក់ព័ន្ធនឹងកិច្ចការពារកុមារ ... ៦១
ឧបសម្ព័ន្ធ ២ ៖ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិស្តីពី សិទ្ធិកុមារក្នុងប្រទេសកម្ពុជា ............ ៦២
ឧបសម្ព័ន្ធ ៣ ៖ ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ............ ៦៥

# អក្សរកាត់

| | |
|---|---|
| **ACWC** | គណៈកម្មការអាស៊ានទទួលបន្ទុកការលើកកម្ពស់ និង កិច្ចការពារសិទ្ធិស្ត្រី និងកុមារ |
| **CCWC** | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ |
| **CDC** | មជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជំងឺ |
| **CDHS** | អង្កេតប្រជាសាស្ត្រ និងសុខភាពក្នុងប្រទេសកម្ពុជា |
| **CFS** | សាលារៀនកុមារមេត្រី |
| **CNCC** | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| **CRC** | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| **CSO** | អង្គការសង្គមស៊ីវិល |
| **CVACS** | អង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា |
| **GSHS** | អង្កេតសកលអំពីសុខភាពសិស្សតាមសាលារៀន |
| **ICT** | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន |
| **ILO** | អង្គការពលកម្មអន្តរជាតិ |
| **INSPIRE** | អនុវត្ត និងពង្រឹងការអនុវត្តច្បាប់ និយាមបទដ្ឋាន និងគុណតម្លៃ បរិយាកាសដែលមានសុវត្ថិភាព ការគាំទ្រដល់ឪពុកម្តាយ និងអ្នកមើលថែកុមារ ពង្រឹងសេដ្ឋកិច្ច និងប្រាក់ចំណូល សេវាឆ្លើយតបនិងគាំទ្រ ការអប់រំនិងបំណិនជីវិត |
| **LGBT** | អ្នកដែលស្រឡាញ់ភេទដូចគ្នា អ្នកដែលស្រឡាញ់ភេទទាំងពីរ អ្នកបំប្លែងភេទ(ខ្ទើយ) |
| **MIS** | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| **MoCR** | ក្រសួងធម្មការ និងសាសនា |
| **MoEYS** | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoH** | ក្រសួងសុខាភិបាល |
| **MoI** | ក្រសួងមហាផ្ទៃ |
| **MoInf** | ក្រសួងព័ត៌មាន |
| **MoJ** | ក្រសួងយុត្តិធម៌ |
| **MoLVT** | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **MoP** | ក្រសួងផែនការ |
| **MoSVY** | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **MoT** | ក្រសួងទេសចរណ៍ |
| **MoWA** | ក្រសួងកិច្ចការនារី |
| **NAA** | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| **NGO** | អង្គការមិនមែនរដ្ឋាភិបាល |
| **NIS** | វិទ្យាស្ថានជាតិស្ថិតិ |
| **OVC** | កុមារកំព្រា និងកុមារងាយរងគ្រោះ |
| **RGC** | រាជរដ្ឋាភិបាលកម្ពុជា |
| **SDG** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| **TOC** | ទ្រឹស្តីនៃការផ្លាស់ប្តូរ |
| **TWG** | ក្រុមការងារបច្ចេកទេស |
| **UNIAP** | គម្រោងអន្តរទីភ្នាក់ងារអង្គការសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស |
| **UNICEF** | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| **WCCC** | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| **WHO** | អង្គការសុខភាពពិភពលោក |

# សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការប្តេជ្ញាចិត្តដ៏រឹងមាំមួយ នៅក្នុងផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ (ផែនការសកម្មភាព) ដើម្បីចូលរួមជាមួយចលនាសកលសំដៅបញ្ចប់អំពើហិង្សាលើកុមារ ដូចមានបញ្ជាក់នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការសកម្មភាពរបស់អាស៊ានឆ្នាំ២០១៥ ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ។ គំហើញនៃការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាឆ្នាំ២០១៣ បានបង្ហាញឱ្យដឹងថាកុមារកម្ពុជាជាច្រើនបានទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ ប្រភពជាច្រើនក៏បានគូសបញ្ជាក់អំពីទិន្នន័យទាក់ទងនឹងទម្រង់ដទៃទៀតនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាផងដែរ ក្នុងនោះរួមមាន ការមិនអើពើ អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ ពលកម្មកុមារ អំពើជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។ បន្ថែមពីលើគំហើញពីការស្រាវជ្រាវនេះ អ្នកផ្តល់សេវា និងអ្នកពាក់ព័ន្ធសំខាន់ៗ បានកំណត់រកក្រុមកុមារដែលមានភាពងាយរងគ្រោះ ជាពិសេសចំពោះអំពើហិង្សា ក្នុងនោះរាប់បញ្ចូលទាំងកុមារពិការ កុមារមានផ្ទុកមេរោគអេដស៍ កុមារដែលរស់នៅក្នុងមណ្ឌល កុមារដែលត្រូវបានកំណត់ថាជាអ្នកស្រឡាញ់ភេទដូចគ្នា កុមារដែលរស់នៅ និងធ្វើការងារតាមចិញ្ចើមថ្នល់ កុមារនៅក្រៅសាលារៀន កុមារដែលធ្វើចំណាកស្រុក និងកូនរបស់គ្រួសារចំណាកស្រុក កុមារាដែលជាជនរងគ្រោះនៃអំពើរំលោភបំពានផ្លូវភេទ កុមាររស់នៅតំបន់ជនបទ ឬតំបន់ដាច់ស្រយាល កុមារនៃសហគមន៍ជនជាតិដើមភាគតិច ជាតិសាសន៍ ឬសាសនាភាគតិច កុមារដែលមានទំនាក់ទំនងជាមួយច្បាប់ និងកូនរបស់ស្ត្រីជាប់ពន្ធនាគារ។

ឆ្លើយតបទៅនឹងរបកគំហើញទាំងនេះ ក្នុងឆ្នាំ២០១៥ ក្រសួងកិច្ចការនារីត្រូវបានទទួលការឯកភាពឱ្យដឹកនាំការរៀបចំផែនការសកម្មភាពដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារដែលមានរយៈពេលប្រាំឆ្នាំ គឺ២០១៧-២០២១ ។ ក្រសួងកិច្ចការនារី បានបង្កើតគណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និង អំពើហិង្សាលើកុមារ ដោយមានសមាជិកចូលរួមពីបណ្តាក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន១៣ ព្រមទាំងក្រុមការងារបច្ចេកទេសចំនួន៤ ដែលមានសមាជិកមកពីក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងក្រុមកុមារវ័យជំទង់និងយុវជន។ ដំណើរការរៀបចំផែនការសកម្មភាពប្រកបដោយបរិយាប័ន្ន និងមានកិច្ចសហការបែបនេះ ត្រូវបានរចនាឡើងដើម្បីលើកកម្ពស់ការប្តេជ្ញាចិត្ត និងកិច្ចសហការក្នុងចំណោមវិស័យនានា (វិស័យសុខាភិបាល សុខុមាលភាពសង្គម អប់រំ និងយុត្តិធម៌) និងនៅគ្រប់កម្រិតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការប្តេជ្ញាចិត្ត និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធសំខាន់ៗទាំងនេះ មានសារៈសំខាន់ខ្លាំងណាស់ ចំពោះការពង្រឹងប្រព័ន្ធការពារកុមារ ដែលមានការសម្របសម្រួលទូទាំងប្រទេស ព្រមជាមួយនឹងកម្លាំងការងារដែលមានជំនាញ និងមានសមត្ថភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។

ទ្រឹស្តីនៃការផ្លាស់ប្តូរមួយស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ត្រូវបានក្រុមការងារបច្ចេកទេសរៀបចំឡើងក្នុងលក្ខណៈជាក្របខ័ណ្ឌទ្រឹស្តីមួយក្នុងកម្រិតប្រព័ន្ធ សម្រាប់រៀបចំអភិក្រមផែនការសកម្មភាព ដើម្បីដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ។ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ បានកំណត់អន្តរាគមន៍ជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ដែលរួមមាន ៖ ១) ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ ២) ការទប់ស្កាត់បឋម ៣) សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ ៤) ការបង្កើត និងការធ្វើវិសោធនកម្មច្បាប់និងគោលនយោបាយ និង ៥) ការពិនិត្យតាមដាន និងវាយតម្លៃ។ សកម្មភាពទប់ស្កាត់ និងឆ្លើយតប ដូចមានបញ្ជាក់នៅក្នុងផ្នែកនីមួយៗនៃផែនការសកម្មភាពនេះ នឹងត្រូវអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយក្រសួងស្ថាប័នដែលទទួលខុសត្រូវ ដោយផ្អែកលើការប្តេជ្ញាចិត្តគន្លឹះ និងដៃគូអភិវឌ្ឍន៍។

ដើម្បីគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការបញ្ចូលសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារទៅក្នុងផែនការប្រតិបត្តិ និងផែនការថវិកាប្រចាំឆ្នាំ ផែនការសកម្មភាពបានបញ្ចូលការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់ សកម្មភាពដែលមានគូសបញ្ជាក់នៅក្នុងក្របខ័ណ្ឌលទ្ធផលសំខាន់ៗ។ ក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃមួយ នឹងរាយការណ៍ឱ្យដឹងអំពីវឌ្ឍនភាពនិងបញ្ហាប្រឈមក្នុងការអនុវត្តផែនការសកម្មភាព ព្រមទាំងការបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់ជ្រុងជ្រោយមួយសម្រាប់ប្រមូលទិន្នន័យអំពីចរិត និងវិសាលភាពនៃអំពើហិង្សាលើកុមារ និងភស្តុតាងជាមូលដ្ឋានសម្រាប់ការអនុវត្តល្អៗនៅក្នុងអន្តរាគមន៍បង្ការ និងឆ្លើយតប។

រាជរដ្ឋាភិបាលកម្ពុជា និងអ្នកពាក់ព័ន្ធពហុវិស័យជាច្រើនទៀត សុទ្ធសឹងតែដើរតួនាទីសំខាន់ក្នុងការអនុវត្តផែនការសកម្មភាព និងកំណត់ទិសដៅអនាគតរបស់ប្រទេសកម្ពុជាថា ជាប្រទេសមួយដែលកុមារគ្រប់រូបទទួលបានកិច្ចការពារ និងរស់នៅដោយគ្មានអំពើហិង្សា។

# ១. សេចក្តីផ្តើម

## ១.១. សេចក្តីសម្រេចដើម្បីរៀបចំផែនការសកម្មភាព

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពក្នុងកិច្ចខិតខំដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ ហើយជំហានសំខាន់ៗត្រូវបានអនុវត្ត ដើម្បីរៀបចំគោលនយោបាយ ច្បាប់ យុទ្ធសាស្ត្រជាក់លាក់ និងក្របខ័ណ្ឌគតិយុត្តិសំខាន់ៗសម្រាប់កិច្ចការពារកុមារ។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការនៅក្នុងវិស័យជាច្រើន ដើម្បីដោះស្រាយបញ្ហាអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើ ព្រមទាំងបញ្ចូលបញ្ហាទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ បើទោះជាដូច្នេះក្តី ក៏នៅមានបញ្ហាប្រឈមគួរឱ្យកត់សម្គាល់មួយចំនួនក្នុងការអនុវត្តរចនាសម្ព័ន្ធទាំងនេះ នៅពេលដែលមិនមានកម្លាំងការងារគ្រប់គ្រាន់ និងប្រព័ន្ធកិច្ចការពារកុមារដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ នៅថ្នាក់កណ្តាល។

ក្នុងឆ្នាំ២០១៣ ការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា លើកដំបូងបាននាំឱ្យមានការផ្តោតយកចិត្តទុកដាក់យ៉ាងច្បាស់លាស់ទៅលើអត្រានៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ដែលជាជំហានមួយដ៏សំខាន់ក្នុងការស្វែងយល់អំពីបញ្ហានេះ។ សេចក្តីសម្រេចអភិវឌ្ឍន៍ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ត្រូវបានធ្វើឡើងក្រោយពេលទទួលបានលទ្ធផលពីការអង្កេត ស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងប្រែក្លាយការសិក្សាស្រាវជ្រាវទៅជាសកម្មភាព។ បន្ទាប់ពីការប្រកាសផ្សព្វផ្សាយគំហើញដែលទទួលបានពីការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជារួចមក គណៈកម្មការដឹកនាំសម្រាប់ការអង្កេតស្តីពីអំពើហិង្សាលើកុមារ បានធ្វើសេចក្តីសម្រេចជាឯកច្ឆន្ទថា ក្រសួងកិច្ចការនារីនឹងដឹកនាំការសម្របសម្រួលឱ្យមានយុទ្ធសាស្ត្រមួយដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដោយរាប់បញ្ចូលទាំងការអភិវឌ្ឍផែនការសកម្មភាពអន្តរក្រសួងមួយដែលមានរយៈពេល៥ឆ្នាំ និងដោយមានគណនាថ្លៃចំណាយរួចជាស្រេច។ ក្រោយមក ក្រសួងកិច្ចការនារី បានចេញសេចក្តីសម្រេចមួយ (លេខ ១៥៩៤) ដើម្បីបង្កើតគណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និង អំពើហិង្សាលើកុមារ ដែលមានតួនាទីភារកិច្ចជាអ្នកសម្របសម្រួលការអភិវឌ្ឍផែនការសកម្មភាពនេះ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ក្នុងរយៈពេលចន្លោះពីឆ្នាំ២០១៧-២០២១។

## ១.២. វិធីសាស្ត្រក្នុងការរៀបចំផែនការសកម្មភាព

គណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និង អំពើហិង្សាលើកុមារ មានការចូលរួមពីក្រសួងនិងស្ថាប័នចំនួន១៣ ដោយមានក្រសួងកិច្ចការនារីជាប្រធាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាអនុប្រធាន។ ក្រសួងនិងស្ថាប័នដែលចូលរួម មានដូចជា ក្រសួងធម្មការ និងសាសនា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងទេសចរណ៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

ដើម្បីទទួលបានទិន្នន័យបឋមពីប្រព័ន្ធ និងសកម្មភាពការពារកុមារដែលមានស្រាប់ ស្ថាប័ននីមួយៗដែលជាសមាជិករបស់គណៈកម្មការដឹកនាំ បានរៀបចំផែនទីសកម្មភាពបច្ចុប្បន្ន និងសកម្មភាពដែលរំពឹងទុកនាពេលអនាគត សំដៅដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ ដូចដែលមានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ តាមវិស័យនីមួយៗ ព្រមទាំងបានកត់ត្រាអំពីចំណុចខ្វះចន្លោះដែលតម្រូវឱ្យមានការបំពេញបន្ថែមផងដែរ។ ផ្អែកលើផែនទីសកម្មភាព និងគំហើញពីការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ក្រសួងពាក់ព័ន្ធបានអភិវឌ្ឍន៍ការប្តេជ្ញាចិត្តជាគន្លឹះ ដើម្បីទប់ស្កាត់ និងឆ្លើយតប ចំពោះអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ដែលជាការប្តេជ្ញាចិត្តគន្លឹះ របស់ក្រសួងស្ថាប័នទាំង១៣ ដែលជាសមាជិកនៃគណៈកម្មការដឹកនាំស្តីពីអំពើហិង្សាលើកុមារ ដើម្បីឆ្លើយតបទៅនឹងគំហើញ និងអនុសាសន៍នៃការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។ ការប្តេជ្ញាចិត្តជាគន្លឹះ ទាំងនេះត្រូវបានប្រកាសផ្សព្វផ្សាយព្រមជាមួយនឹងគំហើញពីការអង្កេតស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាក្នុងខែតុលា ឆ្នាំ២០១៤។

ក្នុងឆ្នាំ២០១៥ គណៈកម្មការដឹកនាំកិច្ចការអំពើហិង្សាលើស្ត្រី និង អំពើហិង្សាលើកុមារបានបង្កើតក្រុមការងារបច្ចេកទេសចំនួន ៤ ដើម្បីរៀបចំផែនការសកម្មភាពដែលជាដំណោះស្រាយពាក់ព័ន្ធនឹងបញ្ហាចម្បង៤ចំណុច គឺ ១) ការបង្ការ ២) ការឆ្លើយតប ៣) ច្បាប់ និងគោលនយោបាយ និង ៤) ការពិនិត្យតាមដាន និងវាយតម្លៃ។ ក្រុមការងារបច្ចេកទេសទាំង៤នេះរួមមានសមាជិកមកពីក្រសួងទាំង១៣ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងក្រុមកុមារវ័យជំទង់ និងយុវជន និងទីប្រឹក្សាបច្ចេកទេសដទៃទៀត។ ក្រុមការងារបច្ចេកទេសទាំង៤ បានជួបប្រជុំចំនួន៤ដងនៅកម្រិតថ្នាក់ជាតិក្នុងរាជធានីភ្នំពេញ និង២ដងនៅកម្រិតថ្នាក់ក្រោមជាតិ ក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុ។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ ក្រុមការងារបច្ចេកទេសបានសហការអភិវឌ្ឍន៍សកម្មភាព ទិន្នផល លទ្ធផល និងសូចនាករនៃផែនការសកម្មភាព ដោយផ្អែកលើការប្តេជ្ញាចិត្តជាគន្លឹះ និងផែនទីសកម្មភាពរបស់ក្រសួងទាំង១៣ ទៅលើកម្មវិធី និងសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារដែលមានស្រាប់។ ផែនការសកម្មភាពនេះ គឺជាផលិតផលចុងក្រោយនៃដំណើរការរួមគ្នារបស់គណៈកម្មការដឹកនាំ និងក្រុមការងារបច្ចេកទេស។ ផែនការសកម្មភាពនេះចែងអំពីយុទ្ធសាស្ត្រ និងសកម្មភាពដែលស្របតាមវិស័យជាយុទ្ធសាស្ត្រទាំង៥ ដូចជា ១)ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ ២)ការទប់ស្កាត់បឋម ៣)សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពាកុមារ ៤)ការបង្កើត និងការធ្វើវិសោធនកម្មច្បាប់ និងការអនុវត្តគោលនយោបាយ ៥)ការពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការកសាងសមត្ថភាពជាវិស័យដែលមានលក្ខណៈប្រទាក់ក្រឡាគ្នាអមជាមួយនឹងក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃដ៏គ្រប់ជ្រុងជ្រោយមួយផងដែរ។

# ២. ចលនាសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ

ការឆ្លើយតបរបស់ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃចលនាសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ។របាយការណ៍ឆ្នាំ២០០៦ របស់ជំនាញការឯករាជ្យសម្រាប់ការសិក្សាស្រាវជ្រាវរបស់អគ្គលេខាធិការ ស្តីពីអំពើហិង្សាលើកុមារ[2] (“ការសិក្សាស្រាវជ្រាវរបស់អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ”) បានផ្តល់ការសិក្សាស្រាវជ្រាវកម្រិតសកលដំបូងបង្អស់ស្តីពីអំពើហិង្សាលើកុមារ ។ ការសិក្សាស្រាវជ្រាវនេះ បានកត់សម្គាល់ថាអំពើហិង្សាលើកុមារមានទម្រង់មួយចំនួន ក្នុងនោះរួមមាន អំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ព្រមទាំងការមិនអើពើផងដែរ ។ ការសិក្សាបានរាយការណ៍ឱ្យដឹងផងដែរថា អំពើហិង្សាលើកុមារកើតឡើងនៅតាមកន្លែងមួយចំនួនដូចជា នៅតាមផ្ទះ សហគមន៍ សាលារៀន កន្លែងការងារ កន្លែងកំសាន្ត រាប់បញ្ចូលទាំង ក្លឹបកីឡា ក្លឹបយុវជន កន្លែងថែទាំកុមារ កន្លែងឃុំខ្លួន កន្លែងសាសនា និងក្នុងអំឡុងពេលអនុវត្តច្បាប់ និងនីតិវិធីតុលាការ[3] ។

ការសិក្សាស្រាវជ្រាវ បានគូសបញ្ជាក់អំពីផលវិបាកជាច្រើន នៃអំពើហិង្សាកាលពីកុមារភាព ក្នុងនោះរួមមាន ការចុះអន់ថយនៃការអភិវឌ្ឍផ្នែកសង្គម ស្មារតី និងសតិបញ្ញាពេញមួយជីវិត ព្រមទាំងមានទំនាក់ទំនងកាន់តែខ្ពស់ទៅនឹងបញ្ហាសុខភាព និងសុខភាពផ្លូវចិត្ត អំពើហិង្សាពីដៃគូស្និទ្ធស្នាល និងការប៉ុនប៉ងធ្វើអត្តឃាត[4] ។ ការសិក្សាស្រាវជ្រាវនេះ បានផ្តល់អនុសាសន៍ថា “រដ្ឋទាំងអស់ត្រូវអភិវឌ្ឍន៍ក្របខ័ណ្ឌពហុវិស័យមួយដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងដំណើរការរៀបចំផែនការជាតិ”[5] ។

## ២.១. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ភាពជាដៃគូសកល

ក្នុងឆ្នាំ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តទៅលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)[6] ថាជាក្របខ័ណ្ឌអភិវឌ្ឍន៍សកលចម្បងថ្មីមួយ និងកម្រងគោលដៅមួយចំនួនសម្រាប់រយៈពេលពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ ២០៣០។ ឆ្លើយតបទៅនឹងការសិក្សារបស់អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ គោលដៅរបស់ SDG បានរាប់បញ្ចូលការយកចិត្តទុកដាក់ថ្មីមួយទៅលើកិច្ចការពារកុមារ និងការដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ ក្នុងនោះរួមមាន ៖

- **គោលដៅ SDG ១៦.២** “បញ្ចប់ការរំលោភបំពាន អំពើកេងប្រវ័ញ្ច ការជួញដូរ និងអំពើហិង្សាគ្រប់ទម្រង់ ព្រមទាំងការធ្វើទារុណកម្មកុមារ”
- **គោលដៅ SDG ៥.២** “លុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រី និងកុមារីគ្រប់រូប នៅកន្លែងសាធារណៈ និងកន្លែងឯកជន រាប់បញ្ចូលទាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងការកេងប្រវ័ញ្ច ក្នុងទម្រង់ដទៃទៀត”
- **គោលដៅ SDG ១៦.១** “កាត់បន្ថយ គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា និងអត្រាមរណៈដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់នៅគ្រប់កន្លែងទាំងអស់[7]” ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដទៃទៀតដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ក៏រួមចំណែកដោះស្រាយកត្តាហានិភ័យនៃអំពើហិង្សាលើកុមារបន្ថែមទៀតដែរ ក្នុងនោះរួមមាន ភាពក្រីក្រ សុខភាព សមភាពយេនឌ័រ ការអប់រំ បរិយាកាសប្រកបដោយសុវត្ថិភាព និងយុត្តិធម៌។ **ឧបសម្ព័ន្ធ ១ ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង គោលដៅពាក់ព័ន្ធនឹងកិច្ចការពារកុមារ។**

ដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់កិច្ចការពារកុមារ ***ភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ*** ត្រូវបានបង្កើតឡើង ដើម្បីជួយគាំទ្ររដ្ឋាភិបាល អង្គការមូលនិធិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ សង្គមស៊ីវិល គ្រឹះស្ថានអប់រំ វិស័យឯកជន និងប្រជាពលរដ្ឋវ័យក្មេងក្នុងការជំរុញសកម្មភាព សំដៅសម្រេចឱ្យបាននូវគោលដៅសកលថ្មីដើម្បីបញ្ចប់អំពើរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរ និងអំពើហិង្សាគ្រប់ទម្រង់ ព្រមទាំងទារុណកម្មលើកុមារ ។

2 UN General Assembly. A/61/299: UN Study on Violence Against Children. 2006.
3 UN General Assembly. A/61/299: UN Study on Violence Against Children, para 38-80. 2006.
4 UN General Assembly. A/61/299: UN Study on Violence Against Children, para 36. 2006.
5 UN General Assembly. A/61/299: UN Study on Violence Against Children, para 96. 2006.
6 UN General Assembly. A/70/1: Transforming Our World - The 2030 Agenda for Sustainable Development. 2015.
7 Ibid

## ២.២. យុទ្ធសាស្ត្រចំនួនប្រាំពីរសម្រាប់បញ្ចប់អំពើហិង្សាលើកុមារ (INSPIRE)[8]

បេះដូងនៃយុទ្ធសាស្ត្ររបស់ភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ គឺ INSPIRE ៖ យុទ្ធសាស្ត្រចំនួនប្រាំពីរដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។ INSPIRE គឺជាកញ្ចប់អន្តរាគមន៍មួយដែលមានមូលដ្ឋានផ្អែកលើភស្តុតាងដើម្បីទប់ស្កាត់អំពើហិង្សា ដែលអង្គការសុខភាពពិភពលោក (WHO) បានអភិវឌ្ឍន៍ឡើង ដោយសហការជាមួយអ្នកឯកទេសគ្រប់វិស័យ[9] ដោយពង្រីកបន្ថែមទៅលើយុទ្ធសាស្ត្រទាំងប្រាំមួយរបស់អង្គការយូនីសេហ្វសម្រាប់ការធ្វើសកម្មភាព[10]។ យុទ្ធសាស្ត្ររបស់ INSPIRE ត្រូវបានពិចារណា និងបានដាក់បញ្ចូលក្នុងផែនការសកម្មភាពនេះ រួមមាន សកម្មភាព លទ្ធផល និងសូចនាករ ដែលផ្តោតទៅលើការអនុវត្តនិងការពង្រឹងច្បាប់ និយាមបទដ្ឋាននិងគុណតម្លៃ បរិយាកាសប្រកបដោយសុវត្ថិភាព កិច្ចគាំទ្រឪពុកម្តាយនិងអ្នកថែទាំ ការពង្រឹងប្រាក់ចំណូលនិងសេដ្ឋកិច្ច សេវាឆ្លើយតបនិងគាំទ្រ និងការអប់រំនិងជំនាញបំណិនជីវិត។

## ២.៣. ការឆ្លើយតបរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ចំពោះអំពើហិង្សាលើកុមារ

ក្នុងឆ្នាំ២០១១ គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ (ACWC) បានកំណត់ថា ការលុបបំបាត់អំពើហិង្សាលើកុមារ (EVAC) គឺជាវិស័យអាទិភាពមួយ នៅក្នុងផែនការ ការងាររបស់ACWC ក្នុងឆ្នាំ២០១២-២០១៦។ ការពិនិត្យឡើងវិញជាប្រព័ន្ធមួយក្នុងឆ្នាំ២០១២ ទៅលើការស្រាវជ្រាវស្តីពីអំពើហិង្សាក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលគាំទ្រដោយអង្គការយូនីសេហ្វ បានប៉ាន់ប្រមាណថា អត្រារំលោភបំពានផ្លូវកាយក្នុងចំណោមកុមារា និងកុមារីនៅក្នុងតំបន់មានកម្រិតចន្លោះពី ១០% ទៅ ៣០,៣% អំពើរំលោភបំពានផ្លូវភេទ មានកម្រិតចន្លោះពី ១,៧% ទៅ ១១,៦% អំពើរំលោភបំពានផ្លូវចិត្ត មានកម្រិតចន្លោះពី ៣១,៣% ទៅ ៦៨,៥% និង ពលកម្មកុមារ មានកម្រិតចន្លោះពី ៦,៥% ទៅ ៥៦%។ បន្ថែមពីនេះទៀត កុមារចំនួន៣នាក់ ក្នុងចំណោមកុមារ៤នាក់ នៅក្នុងតំបន់បានទទួលរងការអនុវត្តវិន័យបែបហិង្សា ដែលប្រព្រឹត្តដោយគ្រូបង្រៀន ឬឪពុកម្តាយ។ ក្នុងឆ្នាំ២០១៥ ផែនការសកម្មភាពរបស់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ (RPA/EVAC) ត្រូវបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ាននៃប្រមុខរដ្ឋ និង រដ្ឋាភិបាល។ ផែនការសកម្មភាពថ្នាក់តំបន់នេះ មានរយៈពេល១០ឆ្នាំ (២០១៦-២០២៥)។

## ២.៤. ការឆ្លើយតបរបស់កម្ពុជាចំពោះអំពើហិង្សាលើកុមារ

គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ក្នុងប្រទេសកម្ពុជា សម្រាប់ទប់ស្កាត់អំពើហិង្សាលើកុមារបានចាប់ផ្តើមពីការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC) ក្នុងឆ្នាំ១៩៩២ និង អនុសញ្ញាអន្តរជាតិសំខាន់ៗមួយចំនួនទៀតជាបន្តបន្ទាប់ ក្នុងគោលបំណងការពារសិទ្ធិកុមារ ដែលរួមមានអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងសេចក្តីប្រកាសអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច។ បន្ថែមពីនេះទៀត រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ និង មាត្រា ៤៨ ទទួលស្គាល់ និងគោរពអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងទទួលស្គាល់សិទ្ធិកុមារ ដូចមានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ និងការជៀសផុតពីអំពើកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងអំពើកេងប្រវ័ញ្ចផ្លូវភេទ។

---

8 INSPIRE យុទ្ធសាស្ត្រចំនួនប្រាំពីរដើម្បីបញ្ចប់អំពើហិង្សាលើកុមារ http://www.who.int/violence_injury_prevention/violence/inspire/en/

9 The United States Centers for Disease Control and Prevention (CDC), End Violence Against Children: The Global Partnership, the Pan American Health Organization (PAHO), the President's Emergency Program for AIDS Relief (PEPFAR), Together for Girls, the United Nations Children's Fund (UNICEF), United Nations Office on Drugs and Crime (UNODC), United States Agency for International Development (USAID), and the World Bank.

10 UNICEF. Ending Violence Against Children: Six Strategies for Action. 2014

ដើម្បីបង្ការអំពើហិង្សាលើកុមារ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនិងអនុម័តឯកសារគតិយុត្តិជាច្រើន ដែលរួមមានជាអាទិ៍ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើ ការអប់រំ និងសុខុមាលភាពគ្រួសារ និងការថែទាំជំនួស និង កុមារដែលពាក់ព័ន្ធនៅក្នុងប្រព័ន្ធយុត្តិធម៌ ព្រមទាំងគោលនយោបាយនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដូចជាគោលនយោបាយជាតិស្តីពីការអភិវឌ្ឍនិងគាំពារកុមារតូច និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍនិងគាំពារកុមារតូច (២០១៤-២០១៨)។ **ឧបសម្ព័ន្ធ ២ ៖ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិស្តីពី សិទ្ធិកុមារ ក្នុងប្រទេសកម្ពុជា។**

បន្ថែមពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតយុទ្ធសាស្ត្រ និងយន្តការជាច្រើននៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជួយដល់ការអភិវឌ្ឍប្រព័ន្ធការពារកុមារក្នុងប្រទេសកម្ពុជា ក្នុងនោះរួមមាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) និង គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (គកនក)។ បើទោះជាដូច្នេះក្តី រាជរដ្ឋាភិបាលកម្ពុជា ក៏ទទួលស្គាល់ផងដែរអំពីសេចក្តីត្រូវការ ក្នុងការបោះជំហានឱ្យហួសពីគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ដើម្បីឱ្យមានអន្តរាគមន៍ឆ្លើយតបដែលមានការកំណត់គោលដៅប្រសើរជាងនេះ ចំពោះបញ្ហាអំពើហិង្សាលើកុមារ។

# ៣. អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា

## ៣.១. គោលគំនិត និង និយមន័យសំខាន់ៗ

អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ (UNCRC) បានកំណត់ថាកុមារគឺជាបុគ្គលទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ។ បន្ថែមពីនេះ កថាខ័ណ្ឌទី១៧ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់អំពីនិយមន័យនៃពាក្យ អនីតិជនថាជា "បុគ្គលទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ"។ គោលគំនិត វាក្យស័ព្ទ និងនិយមន័យដទៃទៀតទាក់ទងនឹងអំពើហិង្សាលើកុមារមាននៅក្នុងសន្ទានុក្រម ក្នុងផ្នែកទី៩។

## ៣.២. ស្ថានភាពនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា

ជារៀងរាល់ថ្ងៃ កុមារី និង កុមារាក្នុងប្រទេសកម្ពុជាបន្តទទួលរង និងជួបប្រទះអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើ ក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ បទពិសោធន៍របស់កុមារក្នុងការទទួលរងអំពើហិង្សា កើតមាននៅក្នុងគ្រប់ស្រទាប់វណ្ណៈទាំងអស់នៅក្នុងសង្គម ទាំងអ្នកមាន និងអ្នកក្រ ប៉ុន្តែនិន្នាការនៃការប្រឈម ទៅនឹងអំពើហិង្សារបស់ពួកគេ កាន់តែមានភាពធ្ងន់ធ្ងរ ដោយសារបញ្ហាវិសមភាពយេនឌ័រ ការមិនសូវទទួលបានការយកចិត្តទុកដាក់ចំពោះជនក្រីក្រនៅតំបន់ទីក្រុង និងជនបទ ភាពបែកខ្ញែកនៃគ្រួសារដោយសារការ ចំណាកស្រុកស្វែងរកការងារធ្វើ និងឥរិយាបថអវិជ្ជមាន ព្រមទាំងការរើសអើងចំពោះកុមារដែលរស់នៅជាមួយពិការភាព។ កុមារទទួលរង និងជួបប្រទះអំពើហិង្សានៅកន្លែងសាធារណៈ កន្លែងឯកជន នៅផ្ទះ សាលារៀន សហគមន៍ និងកន្លែងសាសនា ព្រមទាំងតាមប្រព័ន្ធអ៊ីនធឺណិត។ អំពើហិង្សាលើកុមារកើតឡើងជាញឹកញាប់ដោយសារមនុស្សពេញវ័យ និងកុមារដែលមានវ័យច្រើនជាង ដែលពួកគាត់មានតួនាទីជាអ្នកផ្ដល់ការថែទាំ ក្នុងនោះរួមមាន ឪពុកម្ដាយ បងប្អូនបង្កើត និងសាច់ញាតិ គ្រូបង្រៀន មិត្តភក្តិនៅឯសាលារៀន សមាជិកសហគមន៍ មេដឹកនាំសាសនា និងអ្នកផ្ដល់ការថែទាំនៅតាមមណ្ឌល។ អំពើហិង្សាលើកុមារមានច្រើនទម្រង់ និង មានការជំរុញពីកត្តាជាច្រើននៅកម្រិតគ្រួសារ សហគមន៍ និងសង្គម ដូច្នេះតម្រូវឱ្យមានដំណោះស្រាយដោយប្រើប្រាស់នូវអន្តរាគមន៍ជាច្រើនបែបដែរ។

និយមន័យនៃ***អំពើហិង្សាលើកុមារ*** ដែលមានចែងនៅក្នុងផែនការសកម្មភាពនេះ ដកស្រង់ចេញពីប្រភពចំនួនពីរ ដែលមានការទទួលស្គាល់ជាអន្តរជាតិ ៖

- មាត្រា ១៩ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ៖ "រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាផ្លូវកាយ ឬផ្លូវចិត្ត របួសស្នាម ឬការរំលោភបំពាន ការមិនអើពើ ឬការប្រព្រឹត្តដែលមិនអើពើការធ្វើបាប ឬការកេងប្រវ័ញ្ច ហើយក៏រាប់បញ្ចូលទាំងការរំលោភបំពានផ្លូវភេទផងដែរ"។
- អង្គការសុខភាពពិភពលោក (WHO) នៅក្នុងរបាយការណ៍ពិភពលោកស្ដីពីអំពើហិង្សា និងសុខភាព (២០០២) ៖ "ការប្រើប្រាស់ដោយចេតនានូវកម្លាំងកាយ ឬអំណាច តាមរយៈការគំរាម ឬការប្រព្រឹត្តជាក់ស្ដែងដោយបុគ្គល ឬក្រុមណាមួយ ទៅលើកុមារដែលបណ្ដាល ឬមានលទ្ធភាពខ្ពស់នាំឱ្យមានគ្រោះថ្នាក់ជាក់ស្ដែង ឬមានសក្ដានុពលក្នុងការបង្កឱ្យមានគ្រោះថ្នាក់ ចំពោះសុខភាព ការរស់រាន ការអភិវឌ្ឍ ឬភាពថ្លៃថ្នូរបស់កុមារ"។

ការអង្កេតស្ដីពីអំពើហិង្សាលើកុមារនៅកម្ពុជា(CVACS) ឆ្នាំ២០១៣ បានផ្ដល់ទិន្នន័យបឋមអំពីប្រេវ៉ាឡង់នៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។ គំហើញពីការអង្កេតនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់កិច្ច អន្តរាគមន៍ឆ្លើយតបមានគោលដៅរយៈពេលវែង ដូចមានគូសបញ្ជាក់នៅក្នុងផែនការសកម្មភាពនេះ។ ប្រភពទិន្នន័យបន្ថែមអំពីអំពើហិង្សាលើកុមាររួមមាន ការសិក្សាពហុប្រទេសរបស់អង្គការសហប្រជាជាតិស្ដីពីបុរស និងអំពើហិង្សា[11] ដែលកម្ពុជាជាប្រទេសមួយនៃការសិក្សា ការធ្វើអង្កេតជាសកលស្ដីពីការយល់ដឹង និងការប្រព្រឹត្តទាក់ទងផ្នែកសុខភាពរបស់យុវសិស្សនៅតាមសាលារៀន (GSHS)[12] ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្ដីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា[13] និង ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) [14]។

11 Fulu E., Jewkes R., Roselli T., Garcia-Moreno C., UN Multi-country Study on Men and Violence, 2013.

12 World Health Organization (WHO), Ministry of Health (MoH), Ministry of Education, Youth and Sports (MoEYS), U.S. Centers for Disease Control and Prevention (CDC), Global School-based Student Health Survey in Cambodia, 2013.

13 Fulu E., National Survey on Women's Health and Life Experiences, 2015.

14 National Institute of Statistics (NIS), Cambodia Demographic and Health Survey, 2014.

ទិន្នន័យបង្ហាញពីប្រេវ៉ាឡង់ក្នុងកម្រិតមួយខ្ពស់ អំពីប្រភេទជាច្រើននៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ដែលរួមចំណែកធ្វើឱ្យមានការព្រួយបារម្ភមួយដ៏ធ្ងន់ធ្ងរ ចំពោះការអនុវត្តសិទ្ធិកុមារ និង បានបង្ហាញឱ្យឃើញថា មានផលប៉ះពាល់អវិជ្ជមានទៅលើសេដ្ឋកិច្ចប្រទេសកម្ពុជាផងដែរ។ របាយការណ៍របស់អង្គការយូនីសេហ្វស្តីពី បន្ទុកសេដ្ឋកិច្ចនៃផលវិបាកផ្នែកសុខភាពនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា បង្ហាញឱ្យដឹងថា បន្ទុកសេដ្ឋកិច្ចនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ដែលបណ្តាលមកពីផលវិបាកផ្នែកសុខភាព និង ការប្រព្រឹត្ត ដែលមានការប្រឈមចំពោះសុខភាព ព្រមទាំងការបាត់បង់ផលិតភាព មានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ ដោយផលវិបាកផ្នែកសុខភាពនាំឱ្យមានការខាតបង់ថវិកាប្រមាណ ១៦៨លានដុល្លារសហរដ្ឋអាមេរិក និង បាត់បង់ផលិតភាពប្រមាណ ៨៣,៣លានដុល្លាសហរដ្ឋអាមេរិក[15]។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពីស្ថានភាពនៃអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។

### ៣.២.១. អំពើហិង្សាផ្លូវកាយ

អំពើហិង្សាផ្លូវកាយ គឺជាប្រភេទអំពើហិង្សាដែលកុមារី និងកុមារាក្នុងប្រទេសកម្ពុជាទទួលរងញឹកញាប់បំផុតនៅក្នុងបរិបទនៃជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ ដូចជានៅផ្ទះ សាលារៀន និងសហគមន៍។ ភាគច្រើន អ្នកដែលបានប្រព្រឹត្តអំពើហិង្សាផ្លូវកាយលើកុមារគឺជាមនុស្សពេញវ័យ និងជាអ្នកថែទាំកុមារ ក្នុងនោះរួមមាន ឪពុកម្តាយ (ជាពិសេស ម្តាយ) ឬ អ្នកដែលមើលថែកុមារដទៃទៀត ដូចជាបងប្អូនបង្កើត សាច់ញាតិជិតស្និទ្ធ និង គ្រូបង្រៀន។

សំខាន់ជាងនេះទៀត មានកុមារចំនួន ៣ភាគ៤ បានទទួលរងហេតុការណ៍នៃអំពើហិង្សាច្រើនទម្រង់ ក្នុងចំណោមកុមារដែលរាយការណ៍ឱ្យដឹងថាបានទទួលរងអំពើហិង្សាផ្លូវកាយក្នុងទម្រង់ណាមួយកាលពីកុមារភាព។

- កុមារី និងកុមារា១នាក់ ក្នុងចំណោម២នាក់ រាយការណ៍ឱ្យដឹងថា បានទទួលរងអំពើហិង្សាផ្លូវកាយ[16]
- កុមារី និងកុមារា១នាក់ ក្នុងចំណោម២នាក់ អាយុចន្លោះពី ១៣ ទៅ ១៧ឆ្នាំ រាយការណ៍ឱ្យដឹងថា ធ្លាប់ ទទួលរងអំពើហិង្សាផ្លូវកាយធ្ងន់ធ្ងរ[17]
- ម្តាយគឺជាបុគ្គលទូទៅបំផុតដែលបានប្រព្រឹត្តអំពើហិង្សាផ្លូវកាយលើកុមារនៅផ្ទះ ដោយឡែកគ្រូបង្រៀន គឺជាបុគ្គលទូទៅបំផុតដែលបានប្រព្រឹត្តអំពើហិង្សានៅក្រៅផ្ទះ[18]
- សិស្សចំនួន១៧% ដែលរៀនថ្នាក់ទី៧-១២ បានរាយការណ៍ឱ្យដឹងថា ធ្លាប់រងការវាយលើរាងកាយ ចំនួន១លើក ឬ ច្រើនលើកនៅសាលារៀន[19]
- កុមារាចំនួន ៤៣% បានរាយការណ៍ឱ្យដឹងថា ធ្លាប់ត្រូវគេវាយ ឬ រងការដាក់ទណ្ឌកម្មលើរាងកាយ ពីសំណាក់គ្រូបង្រៀន ឬ នាយកសាលា[20]
- កុមារី និង កុមារាចំនួន៣នាក់ ក្នុងចំណោម៤នាក់ ដែលបានរាយការណ៍ឱ្យដឹងអំពីអំពើហិង្សាផ្លូវកាយ បានកំណត់ថាពួកគេបានរងហេតុការណ៍ហិង្សាជាច្រើនទម្រង់[21]

### ៣.២.២.អំពើហិង្សាផ្លូវភេទ

យោងតាមការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីអំពើហិង្សាលើកុមារនៅប្រទេសកម្ពុជាបានឱ្យដឹងថា អំពើហិង្សាផ្លូវភេទ បង្កឱ្យមានផលប៉ះពាល់ដល់កុមារី និងកុមារាកម្ពុជាអាយុចន្លោះពី ១៣-១៧ឆ្នាំ ប្រមាណ ៥,៥%។ ស្ថិតិអំពីប្រេវ៉ាឡង់អាចធ្វើការប៉ាន់ប្រមាណទាបពេកចំពោះកម្រិតវិសាលភាពពិតប្រាកដនៃអំពើហិង្សាផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា ដោយសារតែកង្វះការរាយការណ៍គ្រប់គ្រាន់ ដែលបណ្តាលមកពីការមាក់ងាយផ្នែកវប្បធម៌ដ៏ខ្លាំងក្លា ពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និង តថភាព

15 UNICEF. Economic Burden of the Health Consequences of Violence Against Children in Cambodia. 2015.
16 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.
17 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.
18 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.
19 WHO, CDC, MoEYS, MoH, Global School-based Student Health Survey in Cambodia, 2013.
20 Fulu E., Jewkes R., Roselli T., Garcia-Moreno C., UN Multi-country Study on Men and Violence, 2013.
21 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.

ជាក់ស្តែងដែលជនរងគ្រោះភាគច្រើនមានមធ្យោបាយតិចតួច ឬ គ្មានមធ្យោបាយក្នុងការស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ ឬ ដំណោះស្រាយផ្អែកសង្គម។ កុមារីដែលត្រូវបានគេរំលោភសេពសន្ថវៈ អាចទទួលរងនូវភាពអាម៉ាស់ និង ការមាក់ងាយគួរឱ្យកត់សម្គាល់ និង មានការលំបាកក្នុងការរៀបអាពាហ៍ពិពាហ៍ អាស្រ័យដោយពួកគេត្រូវបានចាត់ទុកថា "ខូចភាពបរិសុទ្ធ"[22]។ កុមារាដែលបានរងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទអាចទទួលការមាក់ងាយថា មានទំនាក់ទំនងផ្លូវភេទជាមួយមនុស្សប្រុសភេទដូចគ្នា។

បន្ថែមពីនេះទៀត ការប្រព្រឹត្តផ្លូវភេទប្រកបដោយគ្រោះថ្នាក់ របស់កុមារ ទាំងក្នុងប្រទេសកម្ពុជានិងសកល គឺជាទិដ្ឋភាពមួយគួរឱ្យកត់សម្គាល់នៃអំពើហិង្សាផ្លូវភេទលើកុមារ ហើយត្រូវបានកំណត់ថាជា "ការប្រព្រឹត្តផ្លូវភេទរបស់កុមារ និង យុវជនអាយុក្រោម១៨ឆ្នាំ ដែលពុំមានភាពសមស្របចំពោះការអភិវឌ្ឍ អាចមានគ្រោះថ្នាក់ចំពោះខ្លួនឯង ឬ អ្នកដទៃ និង/ឬ អាចបង្កការរំលោភបំពានចំពោះកុមារ យុវជន ឬ មនុស្សពេញវ័យដទៃទៀត"[23]។

កុមារី និងកុមារា អាយុចន្លោះពី១៣-១៧ឆ្នាំ លើសពី១នាក់ ក្នុងចំណោម២០នាក់ (៥,៥%) បានរាយការណ៍ឱ្យដឹងអំពីអំពើរំលោភបំពានផ្លូវភេទ យ៉ាងហោចណាស់ ចំនួន១ប្រភេទ[24]។

- ក្នុងចំណោមអ្នកដែលបានរួមភេទកាលពីកុមារ មានស្ត្រីចំនួន១នាក់ ក្នុងចំណោម៤នាក់ (២៤,២%) និង បុរស១នាក់ក្នុងចំណោម១១នាក់ (៨,៩%) អាយុ១៨ ទៅ ២៤ឆ្នាំ បានរាយការណ៍ឱ្យដឹងថា ការរួមភេទ លើកដំបូង គឺជាការរួមភេទដែលគេមិនចង់[25]។
- កុមារី និងកុមារាអាយុចន្លោះពី ១៣-១៧ឆ្នាំ ស្ទើរតែ១នាក់ក្នុងចំណោម១០នាក់ បានទទួលរងអំពើហិង្សា ផ្លូវភេទដោយគ្មានការប៉ះពាល់[26]។
- អំពើរំលោភសេពសន្ថវៈ មានចំនួនប្រមាណ ៧៥% នៃបទល្មើសហិង្សាលើស្ត្រី និងកុមារ ដែលបានរាយការណ៍ជូននគរបាល[27]។

### ៣.២.៣. អំពើហិង្សាផ្លូវចិត្ត

កុមារប្រមាណ១នាក់ក្នុងចំណោម៤នាក់ បានទទួលរងអំពើហិង្សាផ្លូវចិត្តពីសំណាក់ឪពុក ឬម្តាយ អ្នកមើលថែ ឬមនុស្សធំដទៃទៀតដែលជាសាច់ញាតិ។ អំពើហិង្សាផ្លូវចិត្តអាចកើតមាននៅផ្ទះ នៅសាលារៀន នៅក្នុងសហគមន៍ ឬនៅក្នុងប្រព័ន្ធអនុវត្តច្បាប់ ពីសំណាក់មិត្តភក្តិរបស់កុមារ ឬ មនុស្សពេញវ័យដទៃទៀតដែរ ដូចជា ការបំពានតាមពាក្យសម្តី ការធ្វើបាបផ្លូវចិត្ត និង ការរំខានផ្សេងៗទៀត រាប់បញ្ចូលតាមរយៈបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICTs) ដូចជាទូរស័ព្ទចល័ត និងអ៊ីនធឺណិត ដែលគេស្គាល់ថាជា "ការសម្លុតតាមប្រព័ន្ធអ៊ីនធឺណិត"[28]។ បើទោះបីជាវិសាលភាពនៃអំពើហិង្សាផ្លូវចិត្ត ដែលកុមារកម្ពុជាបានជួបប្រទះទាំងក្នុង និង ក្រៅផ្ទះមានទំហំគួរឱ្យកត់សម្គាល់ក៏ដោយ ប៉ុន្តែប្រធានបទនេះបានទទួលការយកចិត្តទុកដាក់តិចតួច ហើយតម្រូវឱ្យមានការស្រាវជ្រាវបន្ថែមទៀតទៅលើកម្រិតវិសាលភាព ស្ថានភាព និង កត្តាកំណត់នៃអំពើហិង្សាផ្លូវចិត្តក្នុងប្រទេសកម្ពុជា។

- កុមារី និងកុមារា១នាក់ក្នុងចំណោម៤នាក់ បានរាយការណ៍ឱ្យដឹងអំពីអំពើហិង្សាផ្លូវចិត្តនៅឯផ្ទះ[29]។
- កុមារី និងកុមារា១នាក់ក្នុងចំណោម៤នាក់បានរាយការណ៍ឱ្យដឹងថាពួកគេបានរងការសម្លុតនៅឯសាលារៀន[30]។

---

22 UNICEF, An Analysis of the Situation of Children & Women in Cambodia, 2009.

23 Hackett S., Holmes D., and Branigan P., Operational Framework for Children and Young People Displaying Harmful Sexual Behaviours, 2016.

24 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.

25 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.

26 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.

27 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.

28 UN Committee on the Rights of the Child (UNCRC), The Rights of the Child to Freedom from all Forms of Violence, 2011.

29 Steering Committee on Violence Against Children, Findings from Cambodia's Violence Against Children Survey (CVACS), 2013.

30 WHO, CDC, MoEYS, MoH, Global School-based Student Health Survey in Cambodia, 2013.

### ៣.២.៤. ការមិនអើពើចំពោះកុមារ

យោងតាមទិន្នន័យពីការអង្កេតប្រជាសាស្ត្រ និង សុខភាពកម្ពុជា (CDHS) បានឱ្យដឹងថា កុមារកម្ពុជា១នាក់ក្នុងចំណោម ១០នាក់ ដែលមានអាយុក្រោម១០ឆ្នាំ ទទួលបានការថែទាំមិនគ្រប់គ្រាន់។ CDHS គឺជាប្រភពទិន្នន័យបឋមតែមួយគត់អំពីការមិនអើពើចំពោះកុមារ ក្នុងប្រទេសកម្ពុជា និង គ្រឡេកមើលទៅលើបញ្ហាការថែទាំ និង ការគ្រប់គ្រងកុមារមិនបានគ្រប់គ្រាន់ ដែលនេះគ្រាន់តែជាទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពជាច្រើននៃការមិនអើពើចំពោះកុមារប៉ុណ្ណោះ។ ដូច្នេះ ត្រូវការឱ្យមានការស្រាវជ្រាវបន្ថែមទៀតអំពីកម្រិតវិសាលភាព ចរិត និង កត្តាកំណត់នៃការមិនអើពើចំពោះកុមារក្នុងប្រទេសកម្ពុជា។

នៅកម្រិតសកល ការមិនអើពើចំពោះកុមារត្រូវបានចាត់ទុកថា ជាប្រភេទទូទៅបំផុតនៃការធ្វើបាបកុមារ ដែលមានអត្រាខ្ពស់ជាងអំពើរំលោភបំពានផ្លូវកាយ ផ្លូវភេទ និង អំពើរំលោភបំពានប្រភេទដទៃទៀត។ ការមិនអើពើចំពោះកុមារ មានទំនាក់ទំនងទៅនឹងការបង្កការខូចខាតយ៉ាងទូលំទូលាយជាងការរំលោភបំពានដែលសកម្ម និង អាចមានផលប៉ះពាល់បំផ្លិចបំផ្លាញទៅលើសុខភាព និង ការអភិវឌ្ឍផ្លូវកាយរបស់កុមារ ការអភិវឌ្ឍសតិបញ្ញា ការអភិវឌ្ឍផ្លូវចិត្ត និងចិត្តសាស្ត្រ និង ការអភិវឌ្ឍផ្នែកសង្គម និង ការប្រព្រឹត្ត[31]។

- កុមារី និងកុមារាចំនួន១នាក់ ក្នុងចំណោម១០នាក់ ក្នុងប្រទេសកម្ពុជា ដែលមានអាយុក្រោម៥ឆ្នាំ ទទួលបានការថែទាំមិនបានគ្រប់គ្រាន់ យោងតាម CDHS ឆ្នាំ២០១៤ ។

### ៣.២.៥. អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ

***អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ*** ក្នុងប្រទេសកម្ពុជា គឺជាបញ្ហាមួយដែលបង្កឱ្យមានផលប៉ះពាល់ចំពោះកុមារីច្រើនជាងកុមារា និងមានវិសាលភាពធ្ងន់ធ្ងរជាង ព្រមទាំងត្រូវបានចាត់ទុកថា ជាទម្រង់មួយនៃអំពើកេងប្រវ័ញ្ចកុមារ។

អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់ដែលពាក់ព័ន្ធនឹងបញ្ហានេះគឺជាការព្រួយបារម្ភចម្បងមួយផ្នែកសុខភាព ដែលធ្វើឱ្យម្ដាយ និង កុមារមានការប្រឈមខ្ពស់ទៅនឹងជំងឺ និង មរណភាព។ ការស្រាវជ្រាវបានបង្ហាញឱ្យដឹងថា ឱកាសនៃអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ និង ការមានផ្ទៃពោះក្នុងវ័យជំទង់ មានការកើនឡើងនៅពេលដែលស្ត្រីទទួលបានការអប់រំទាប មានស្ថានភាពសេដ្ឋកិច្ចទាប និង ចំពោះកុមារីនៅសហគមន៍ជនបទ និងជនជាតិដើមភាគតិច។

- ស្ត្រីចំនួន១នាក់ក្នុងចំណោម៤នាក់ (២៣%) និង បុរសចំនួន១នាក់ ក្នុងចំណោម១៥នាក់ (៦,៥%) ដែលមានអាយុចន្លោះពី ១៨-៤៩ឆ្នាំ បានរាយការណ៍ឱ្យដឹងថា បានរៀបការមុនអាយុ១៨ឆ្នាំ[32]។
- សហគមន៍ជនបទ និង សហគមន៍ជនជាតិដើមភាគតិច មានអត្រាអាពាហ៍ពិពាហ៍ក្នុងវ័យកុមារខ្ពស់គួរឱ្យកត់សម្គាល់ ដូចជាសហគមន៍ជនជាតិដើមភាគតិច ក្នុងស្រុកអូរជុំ ខេត្តរតនគិរី ដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់ដល់ ៥៩% ដែលកុមារបានរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំ[33]។

### ៣.២.៦. ពលកម្មកុមារ

ផែនការសកម្មភាពជាតិស្ដីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) បានកំណត់ថា **ពលកម្មកុមារ** គឺជាការងារទាំងឡាយណា ទោះបីទទួលបានកម្រៃ ឬមិនបានទទួលកម្រៃក្តី ដែលប៉ះពាល់ ដល់ការរីកលូតលាស់ផ្នែកចិត្តគំនិត ផ្នែករាងកាយ ផ្នែកសង្គម និងផ្នែកសីលធម៌របស់កុមារអាយុក្រោម ១៨ឆ្នាំ ជាពិសេសរាំងស្ទះដល់ការអប់រំរបស់ពួកគេ។ ដោយឡែក**ការងារកុមារ**គឺជាការងារទាំងឡាយណាដែលជួយអប់រំ និងបណ្តុះបណ្តាលដល់កុមារឱ្យចេះធ្វើការនៅពេលអនាគត ដែលជាផ្នែកមួយនៃវិជ្ជាជីវៈគ្រួសារ ដែលមិនចាត់ទុកជាពលកម្មកុមារទេ។

---

31 Harvard University Center for the Developing Child. In Brief: The Science of Neglect, 2013.

32 NIS and MoH, Cambodian Demographic and Health Survey, 2014.

33 UNICEF, Cambodia Country Programme 2016-2018: Child Protection.

យោងតាមលទ្ធផលនៃការអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកុមារនៅឆ្នាំ២០១៣ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបង្ហាញថាស្ថានភាពពលកម្មកុមារនៅប្រទេសកម្ពុជា មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាព និងសមិទ្ធផលដ៏ធំធេងដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានក្នុងរយៈពេលមួយទសវត្សន៍កន្លង មកនេះ។

ពលកម្មកុមារ គឺជាបាតុភូតសង្គមដ៏ស្មុគស្មាញមួយដែលមានទំនាក់ទំនងទៅនឹងទិដ្ឋភាព សេដ្ឋកិច្ចសង្គមកម្ពុជា និងឥរិយាបថសហគមន៍។ ភាពក្រីក្រ និងការយល់ដឹងរបស់សហគមន៍ដែលមានកម្រិតទាបជាមូលហេតុចម្បងដែលនាំឱ្យមានពលកម្មកុមារ។ ក្រុមគ្រួសារក្រីក្រដែលខ្វះធនធាន ខ្វះជំនាញ មានការអប់រំទាប និងមានប្រាក់ចំណូលតិច ជាមុខសញ្ញាក្នុងការ ប្រើប្រាស់ពលកម្មកុមារ ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ដោយសារមូលហេតុនេះ គេសង្កេតឃើញពលកម្មកុមារមានគ្របដណ្តប់នៅតាមតំបន់ភូមិសាស្ត្រ មុខព្រួញសេដ្ឋកិច្ច និងទម្រង់ផ្សេងៗនៃវិស័យការងារ។ អង្កេតកម្លាំងពលកម្មនិងពលកម្មកុមារកុមារនៅ ឆ្នាំ២០១៣ បានបង្ហាញអោយឃើញថាកុមារធ្វើសកម្មភាពសេដ្ឋកិច្ចមានអាយុចន្លោះពី១៥ដល់១៧ឆ្នាំស្ទើរតែទាំងអស់ បានបំពេញការងារ៣ម៉ោងក្នុងមួយថ្ងៃ ឬ២១ម៉ោងក្នុងមួយសប្តាហ៍ ហើយក្នុងកុមារអាយុ១៥-១៧ឆ្នាំ ជិត៤លាននាក់មានកុមារ ៧៧៥,២៤៥នាក់ (ប្រមាណ ១៩%) ប៉ុណ្ណោះដែលបានចេញទៅធ្វើការ (ក្នុងនោះកុមារ ៦% ស្ថិតនៅក្នុងការងារប្រកបដោយគ្រោះថ្នាក់ ៤,៩% នៅក្នុងទម្រង់ផ្សេងៗនៃពលកម្ម និង ៨,២% ធ្វើការក្នុងលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព)។

ដោយពិនិត្យការបែងចែកនៃពលកម្មកុមារតាមវិស័យការងារនៅឆ្នាំ២០១២ ប្រមាណ ៥០,៤% នៃពលកម្មកុមារបានចូលរួមក្នុងវិស័យកសិកម្ម ព្រៃឈើ និងនេសាទ ១៩%ធ្វើការក្នុងផ្នែកកម្មន្តសាល ១៤,៧%ធ្វើការក្នុងផ្នែកពាណិជ្ជកម្ម និងជួសជុល ៣,៧%ក្នុងផ្នែកសំណង់ និង៥,១%ធ្វើការក្នុងផ្នែកការស្នាក់នៅ និងម្ហូបអាហារ ។

### ៣.២.៧. ការជួញដូរកុមារ

ការជួញដូរកុមារ ជាបញ្ហាមួយដែលមានផលប៉ះពាល់មកលើជីវិតរស់នៅរបស់កុមារា និង កុមារីក្នុងប្រទេសកម្ពុជា។ គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិប្រឆាំងការជួញដូរមនុស្ស (UNIAP) បានរាយការណ៍ឱ្យដឹងថា កុមារត្រូវបានជួញដូរទាំងនៅក្នុងប្រទេសនិងឆ្លងប្រទេស ដើម្បីឱ្យសុំទាន សម្រាប់ការកំសាន្តផ្លូវភេទ បម្រើការងារតាមផ្ទះ និងការរំលោភបំពានប្រភេទដទៃទៀត។ បញ្ហានេះមិនត្រូវបានដាក់បញ្ចូលក្នុងផែនការសកម្មភាព និងក្របខ័ណ្ឌលទ្ធផលស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ទេ ដោយសារព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងអនុវត្តផែនការសកម្មភាពជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) ឆ្នាំ២០១៤-២០១៨។

### ៣.២.៨. អំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត

បច្ចុប្បន្ន ពុំមានការស្រាវជ្រាវណាមួយអំពីប្រេវ៉ាឡង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតក្នុងប្រទេសកម្ពុជាឡើយ ប៉ុន្តែមន្ត្រីអនុវត្តច្បាប់ និង អ្នកផ្តល់សេវាបានរាយការណ៍ឱ្យដឹងអំពី កំណើននៃការផលិត កាន់កាប់ និង ចែកចាយតាមប្រព័ន្ធព័តមានសង្គមនិងតាមអ៊ីនធឺណិតនូវសម្ភារ និងរូបភាពស្តីពីអំពើរំលោភបំពានកុមារ ការលួងលោមកុមារតាមប្រព័ន្ធព័ត៌មានសង្គម ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងការផ្សាយផ្ទាល់ពីសកម្មភាពរំលោភបំពាននិងកេងប្រវ័ញ្ចកុមារតាមអ៊ីនធឺណិត។ មានភស្តុតាងជាច្រើនបានឱ្យដឹងថា អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត បណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះ ដូចជា ភាពអាម៉ាស់យូរអង្វែង និង គ្មានអំណាចក្នុងខ្លួន ខណៈពេលដែលពួកគេចម្រើនវ័យឡើង[34]។ គេត្រូវប្រមូលភស្តុតាងដើម្បីធ្វើការប៉ាន់ប្រមាណឱ្យបានច្បាស់លាស់អំពីវិសាលភាព និង លក្ខណៈជាក់លាក់នៃអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិតទៅលើកុមារក្នុងប្រទេសកម្ពុជា។

### ៣.២.៩. កុមារដែលមានការប្រឈមខ្ពស់ទៅនឹងអំពើហិង្សា

ជាទូទៅ កុមារគ្រប់រូបងាយរងគ្រោះខ្លាំងជាងមនុស្សពេញវ័យ ដោយសារតែពួកគេមានវ័យក្មេងជាង មានបទពិសោធន៍ជីវិតតិចតួច មានទំហំរូបរាងកាយតូចជាង ភាពចាស់ទុំ និង មានមធ្យោបាយតិចជាងមនុស្សពេញវ័យ។ ទោះបីជាដូច្នេះក្តី កុមារ

34 Ibid

មួយចំនួនកាន់តែងាយរងគ្រោះជាងកុមារដទៃទៀត និង មានការប្រឈមខ្ពស់ជាង ទៅនឹងអំពើហិង្សា ដោយសារតែលក្ខណៈសម្បត្តិបុគ្គល ឬ ដោយសារតែជាសមាជិកនៃក្រុមដែលងាយរងគ្រោះ។ កត្តាហានិភ័យជាច្រើនមានភាពត្រួតស៊ីគ្នា ហើយកុមារអាចធ្លាក់ទៅក្នុងប្រភេទចំណាត់ថ្នាក់ជាច្រើនយ៉ាងងាយ។

ផែនការសកម្មភាពនេះប្រើប្រាស់ឃ្លាថា ***"កុមារដែលមានការប្រឈមខ្ពស់ទៅនឹងអំពើហិង្សា"*** ដើម្បីបញ្ជាក់អំពីក្រុមងាយរងគ្រោះដាក់លាក់ខាងក្រោម ដែលត្រូវការឱ្យមានការពិចារណាពិសេស សម្រាប់ការទប់ស្កាត់ និង ឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ៖

- កុមារពិការ និង កុមារផ្ទុកមេរោគអេដស៍
- កុមារដែលរស់នៅក្នុងមណ្ឌល
- កុមារស្រឡាញ់ភេទដូចគ្នា
- កុមារដែលរស់នៅ ឬ ធ្វើការងារតាមចិញ្ចើមថ្នល់
- កុមារនៅក្រៅសាលារៀន
- កុមារចំណាកស្រុក និង កុមារជាកូនរបស់គ្រួសារចំណាកស្រុក
- កុមាររស់នៅតំបន់ជនបទ ឬ តំបន់ដាច់ស្រយាល
- កុមារនៃសហគមន៍ជនជាតិដើមភាគតិច ជាតិសាសន៍ ឬ សាសនាភាគតិច
- កុមារដែលមានទំនាក់ទំនងជាមួយច្បាប់
- កូនរបស់ស្ត្រីជាប់ពន្ធនាគារ

# ៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍផែនការសកម្មភាព

ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ ២០១៧-២០២១ ត្រូវបានអភិវឌ្ឍន៍ឡើង បន្ទាប់ពី ១) ការទទួលបាននូវលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា (ឆ្នាំ២០១៣) ២) ការពិនិត្យ និងវិភាគទៅលើចំណុចខ្វះចន្លោះនៃសកម្មភាពដែលមានស្រាប់ ៣) ការប្តេជ្ញាចិត្តជាគន្លឹះរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ៤) ការពិនិត្យទៅលើការអនុវត្ត និងបទពិសោធន៍ល្អៗ ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ នៅប្រទេសកម្ពុជា និងប្រទេសដទៃទៀត ៥) ដោយផ្តោតលើអភិក្រមអន្តរវិស័យ និងវដ្តនៃអំពើហិង្សា ៦) ការវិភាគទៅលើផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤-២០១៨ ៧) យុទ្ធសាស្ត្រ ព្រមទាំងផែនការសកម្មភាពតាមវិស័យដទៃទៀតដែលពាក់ព័ន្ធ និង ៨) ការអភិវឌ្ឍ និងត្រួតពិនិត្យឡើងវិញទៅលើទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។

## ៤.១. ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារ

ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ត្រូវបានអភិវឌ្ឍន៍ឡើងដើម្បីគាំទ្រដល់យុទ្ធសាស្ត្ររបស់ផែនការសកម្មភាព ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញក្នុងលក្ខណៈជាប្រព័ន្ធទៅលើឯកសារពាក់ព័ន្ធ និងការវិភាគកម្រិតមធ្យមទៅលើកម្រងទិន្នន័យបឋមដែលមានស្រាប់ ស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។ ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ប្រតិបត្តិនៅ "កម្រិតប្រព័ន្ធ" និងកំណត់អំពីរបៀបនៃការផ្លាស់ប្តូរទៅលើប្រព័ន្ធការពារកុមាររបស់ប្រទេសកម្ពុជា ដែលអាចនាំឱ្យសម្រេចបាននូវគោលបំណងក្នុងការកាត់បន្ថយ ឬ លុបបំបាត់អំពើហិង្សាលើកុមារគ្រប់ទម្រង់ក្នុងប្រទេសកម្ពុជា។ ទ្រឹស្តីនៃការផ្លាស់ប្តូរ បានរកឃើញកត្តាកំណត់ចម្បងៗនៃអំពើហិង្សាលើកុមារ ចំនួន៧ ដែលត្រូវដោះស្រាយនៅក្នុងផែនការសកម្មភាព៖ ភាពក្រីក្រ និងវិសមភាពផ្នែកសង្គមសេដ្ឋកិច្ច ការអប់រំ ទម្លាប់ដែលគាំទ្រដល់ការអនុវត្តន៍វិន័យបែបហិង្សា ទម្លាប់ផឹកស្រា និងប្រើប្រាស់គ្រឿងញៀន ការខ្វះខាតចំណេះដឹង... 

ក្នុងការអភិវឌ្ឍកិច្ចអន្តរាគមន៍ដើម្បីដោះស្រាយកត្តាកំណត់អំពីអំពើហិង្សាលើកុមារ ទ្រឹស្តីនៃការផ្លាស់ប្តូរ បានធ្វើការសំដៅដល់ការអនុវត្តល្អដែលមានស្រាប់ក្នុងការបង្ការ និង ឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ក្នុងនោះរាប់បញ្ចូលការសិក្សាស្រាវជ្រាវរបស់អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ[35] យុទ្ធសាស្ត្រ៦ចំណុចសម្រាប់ចំណាត់ការ របស់អង្គការយូនីសេហ្វ[36] និង យុទ្ធសាស្ត្រទាំង៧សម្រាប់បញ្ចប់អំពើហិង្សាលើកុមារ (INSPIRE) របស់ភាពជាដៃគូសកល។ បន្ថែមពីនេះទៀត អាទិភាព និង ការផ្តួចផ្តើមនានាដែលបានបញ្ចូលនៅក្នុងទ្រឹស្តីនៃការផ្លាស់ប្តូរ ត្រូវបានបង្ហាញក្នុងលក្ខណៈមួយដែលមានសង្គតិភាពទៅនឹងទ្រឹស្តីនៃការផ្លាស់ប្តូរសកលរបស់អង្គការយូនីសេហ្វ សម្រាប់ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១៤-២០១៧[37] កម្មវិធីការពារកុមារប្រចាំប្រទេសរបស់អង្គការយូនីសេហ្វ (២០១៦-២០១៨)[38] ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨)[39] ព្រមទាំងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ(២០១៦-២០១៨)។

ការអភិវឌ្ឍទ្រឹស្តីនៃការផ្លាស់ប្តូរ បានធ្វើឡើងនៅសិក្ខាសាលាថ្នាក់ជាតិចំនួន២ ក្នុងរាជធានីភ្នំពេញ និង ខេត្តសៀមរាប ដែលមានមន្ត្រីរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលដែលជាសមាជិករបស់គណៈកម្មការដឹកនាំស្តីពីអំពើហិង្សាលើកុមារ ព្រមទាំងក្រុមការងារបច្ចេកទេសទាំង៤ ដែលបានចូលរួមអភិវឌ្ឍន៍ដំណើរការស៊ីជម្រៅមួយ ពិនិត្យឡើងវិញ និង កែសម្រួលទៅលើទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់ប្រទេសកម្ពុជា។ សិក្ខាសាលាទាំងនេះមានគោលបំណងផ្សព្វផ្សាយអំពីគំហើញដែលទទួលបានពីការស្រាវជ្រាវ សហការអភិវឌ្ឍន៍ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា និង កសាងសមត្ថភាពក្នុងចំណោមអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ អំពីរបៀបប្រើប្រាស់អភិក្រមទ្រឹស្តីនៃការផ្លាស់ប្តូរ ចំពោះការតាក់តែងគោលនយោបាយ និងការរៀបចំកម្មវិធី។

35 UN General AssemblyA/61/299, Promotion and Protection of the Rights of the Child, 2006.
36 UNICEF, Ending Violence Against Children: Six Strategies for Action, 2014.
37 UNICEF, Revised Supplementary Programme Note on the Theory of Change for the UNICEF Strategic Plan 92014-2017), 2014.
38 UNICEF, UNICEF Cambodia Country Programme 2016-2018: Child Protection.
39 MoWA. National Action Plan to Prevent Violence Against Women, 2014-2018.

លទ្ធផលដែលទទួលបានពីទ្រឹស្តីនៃការផ្លាស់ប្តូរនេះ បានជួយកំណត់យុទ្ធសាស្ត្រនៅក្នុងផែនការសកម្មភាពនេះ។
**ឧបសម្ព័ន្ធ ៣ ៖ ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។**

## ៤.២. គោលការណ៍ទូទៅ និងអភិក្រម

គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិកុមារ បានពន្យល់អំពីអ្វីដែលត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃការសម្របសម្រួល ដើម្បីដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ ឬ ឆ្លើយតបទៅនឹងផែនការសកម្មភាពជាតិ[40]-[41] ដែលត្រូវបញ្ចូលវិធានការផ្នែកច្បាប់ រដ្ឋបាល សង្គម និងការអប់រំ ព្រមទាំងដំណាក់កាលនៃកិច្ចអន្តរាគមន៍ (ចាប់ពីការទប់ស្កាត់ រហូតដល់ពេលសះជាឡើងវិញ និងសមាហរណកម្ម)[42]។ ការអភិវឌ្ឍផែនការសកម្មភាពនេះ ទទួលបាននូវមគ្គុទ្ទេសក៍ណែនាំពីគោលការណ៍មួយចំនួនដូចខាងក្រោម ៖

- **ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលទៅលើផែនការសកម្មភាពនេះ** ៖ ការទទួលស្គាល់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជាទៅលើផែនការសកម្មភាពនេះ គឺផ្អែកលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះសិទ្ធិកុមារ ដែលត្រូវរួចផុតពីអំពើហិង្សាគ្រប់ទម្រង់។ ការអភិវឌ្ឍផែនការ សកម្មភាពរយៈពេល៥ឆ្នាំ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួល ក្រោមការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ដោយមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមយ៉ាងសកម្ម និងកិច្ចសហការពីក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ ក្រសួងទាំង១៣ ដែលជាសមាជិកនៅក្នុងគណៈកម្មការដឹកនាំពហុវិស័យស្តីពីអំពើហិង្សាលើកុមារ ទទួលខុសត្រូវចំពោះការអនុវត្តគោលដៅយុទ្ធសាស្ត្រ គោលបំណង លទ្ធផល និងសកម្មភាពរបស់ខ្លួន នៅក្នុងផែនការសកម្មភាពនេះ។
- **អភិក្រមសិទ្ធិកុមារ** ៖ ការទទួលស្គាល់ថា កុមារគឺជាម្ចាស់សិទ្ធិ និងមិនមែនជាអ្នកទទួលផលនៃសកម្មភាព មនុស្សធម៌របស់មនុស្សពេញវ័យឡើយ។ ការអភិវឌ្ឍផែនការសកម្មភាពនេះ មានការចូលរួមពីកុមារ និងកុមារវ័យជំទង់ ក្នុងនាមជាសមាជិកនៃក្រុមការងារបច្ចេកទេស ហើយនឹងខិតខំបញ្ចូលការចូលរួមរបស់ពួកគេទៅក្នុងការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃផងដែរ (ដោយពិចារណាទៅលើអាយុ និងសមត្ថភាពរបស់ពួកគេ)។
- **ទិដ្ឋភាពយេនឌ័រ និងអំពើហិង្សាលើកុមារ** ៖ ការពិចារណាអំពីហានិភ័យផ្សេងៗគ្នា ដែលកុមារី និងកុមារាកំពុងជួបប្រទះនៅក្នុងបរិបទផ្សេងៗគ្នា ទាក់ទងនឹងអំពើហិង្សាក្នុងទម្រង់ផ្សេងៗគ្នា ព្រមទាំងក្នុងគោលបំណងដោះស្រាយរាល់ទម្រង់ទាំងអស់នៃការរើសអើងផ្អែកយេនឌ័រ ដែលរួមចំណែកធ្វើឱ្យអំពើហិង្សាតែងកើតមានទៅលើកុមារ។
- **ការទប់ស្កាត់បឋម** ៖ យល់ថាការទប់ស្កាត់គឺជាសកម្មភាពសំខាន់បំផុតនៅក្នុងរាល់ការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ។
- **តួនាទីបឋមរបស់គ្រួសារ** ៖ ការទទួលស្គាល់ពីតួនាទីបឋមរបស់គ្រួសារក្នុងការការពារកុមារពីអំពើហិង្សា និងការទទួលស្គាល់ផងដែរថា អំពើហិង្សាអាចកើតមាននៅក្នុងបរិបទគ្រួសារ។
- **ភាពធន់ និងកត្តាការពារ** ៖ ការទទួលស្គាល់អំពីចំណុចខ្លាំងខាងក្នុង និងខាងក្រៅ ព្រមទាំងកិច្ចគាំទ្រ ដែលលើកកម្ពស់សន្តិសុខផ្ទាល់ខ្លួនរបស់កុមារ និងកាត់បន្ថយការរំលោភបំពាន និងការមិនអើពើ ព្រមទាំងផលប៉ះពាល់អវិជ្ជមាននៃសកម្មភាពទាំងនេះ។ ឧទាហរណ៍៖ គ្រួសារដែលមានស្ថិរភាព - មនុស្សពេញវ័យដែលជាអ្នកបីបាច់ថែទាំកុមារ បានបំពេញទៅតាមសេចក្តីត្រូវការរបស់កុមារ - ការប្រើវិន័យបែបវិជ្ជមាន និងក្នុងភាពអហិង្សា ការផ្សារភ្ជាប់ទំនាក់ទំនងជាមួយមនុស្សពេញវ័យប្រកបដោយសុវត្ថិភាព ទំនាក់ទំនងដែលផ្តល់កិច្ចគាំទ្រជាមួយមិត្តភក្តិ ការផ្សារភ្ជាប់ទៅក្នុងសង្គម និងបរិយាកាសអហិង្សានៅក្នុងសង្គម។
- **ការកាត់បន្ថយកត្តាហានិភ័យ** ៖ ការទទួលស្គាល់ថា ត្រូវចាត់វិធានការបែបប្រតិសកម្ម ទៅតាមស្ថានភាពជាក់ស្តែង ដើម្បីកាត់បន្ថយកត្តាហានិភ័យដែលកុមារម្នាក់ៗ និងក្រុមកុមារអាចរងការប្រឈម ក្នុងនោះរាប់បញ្ចូលការប្រើគ្រឿងញៀន បញ្ហាសុខភាពផ្លូវចិត្ត និងការផ្តាច់ខ្លួនពីសង្គម ព្រមទាំងកត្តាហានិភ័យគ្រួសារ ដូចជាភាពក្រីក្រ ភាពគ្មានការងារធ្វើ និងការរើសអើង។

---

40 UNCRC, The Rights of the Child to Freedom from all Forms of Violence, 2011.

41 Special Representative of the Secretary General on Violence Against Children, Toward a World Free from Violence: Global Survey on Violence Against Children, 2013.

42 UNCRC, The Rights of the Child to Freedom from all Forms of Violence, 2011.

- **កុមារដែលមានការប្រឈមខ្ពស់ និងស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ៖** ការទទួលស្គាល់កុមារដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ និងកុមារដែលមានការប្រឈមខ្ពស់ទៅនឹងអំពើហិង្សា។ ឧទាហរណ៍៖ កុមារដែលស្ថិតនៅក្នុងការថែទាំជំនួស កុមារដែលរស់នៅ និងធ្វើការងារតាមចិញ្ចើមថ្នល់ កុមារមានទំនាក់ទំនងជាមួយច្បាប់ កុមារពិការ កុមារនៃក្រុមជនជាតិដើមភាគតិច កុមារស្រឡាញ់ភេទដូចគ្នា កុមារដែលធ្លាប់រៀបអាពាហ៍ពិពាហ៍ កុមារដែលចូលរួមនៅក្នុងពលកម្មប្រកបដោយគ្រោះថ្នាក់ និងកុមារចំណាកស្រុក ឬកុមារដែលត្រូវបានជម្លៀស។
- **ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានបច្ចេកទេស៖** ការពិចារណាថា ធនធានគប្បីត្រូវបានបែងចែកទូទាំងវិស័យ ក្នុងកម្រិតអតិបរមានៃធនធានដែលមាន និងគប្បីអភិវឌ្ឍន៍យន្តការត្រួតពិនិត្យឱ្យបានរឹងមាំ ដើម្បីធានាបាននូវគណនេយ្យភាពក្នុងការវិភាជ និងប្រើប្រាស់ថវិកា។
- **ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព៖** ការយល់ថាត្រូវមានយន្តការដើម្បីធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន រវាងវិស័យនីមួយៗ និងជាមួយសង្គមស៊ីវិល និង
- **យន្តការគណនេយ្យភាព ៖** ការបង្កើតឱ្យមានយន្តការគណនេយ្យភាព ព្រមជាមួយនឹងប្រព័ន្ធ និង ឧបករណ៍នានាសម្រាប់ពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍អំពីកាតព្វកិច្ចក្នុងការអនុវត្តសកម្មភាព

## ៤.៣. វិសាលភាពនៃផែនការ

ផែនការសកម្មភាពនេះ មានវិសាលភាពគ្របដណ្តប់ទៅលើ ៖

- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ដៃគូអភិវឌ្ឍន៍
- សង្គមស៊ីវិល
- អង្គការសាសនា
- ជនរងគ្រោះ
- ជនងាយរងគ្រោះ
- សាធារណជនទូទៅ ។

## ៤.៤. យុទ្ធសាស្ត្រសំខាន់ៗ

ផែនការសកម្មភាពនេះផ្តោតទៅលើយុទ្ធសាស្ត្រជាអាទិភាពចំនួន៥ ៖

i. ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ
ii. ការទប់ស្កាត់បឋម
iii. សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ
iv. ការបង្កើត និង ការធ្វើវិសោធនកម្មច្បាប់ និងការអនុវត្តគោលនយោបាយ
v. ការពិនិត្យតាមដាន និងវាយតម្លៃ

ផ្អែកលើអាទិភាពទាំង៥នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

### ៤.៤.១. យុទ្ធសាស្ត្រទី១ ៖ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

**គោលបំណង ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារ ក្នុងក្របខ័ណ្ឌស្ថាប័នពហុវិស័យសម្រាប់កិច្ចការពារកុមារ តាមរយៈការសម្របសម្រួល ការងារទប់ស្កាត់បឋម និងយុទ្ធសាស្ត្រឆ្លើយតបជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធសំដៅកំណត់គោលដៅលើតួអង្គសំខាន់ៗ និងការកំណត់ឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។

**លទ្ធផល ៖**

- ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ លើកិច្ចខិតខំកាត់បន្ថយអំពើហិង្សាលើកុមារនៅគ្រប់កម្រិត មានការកើនឡើង ក្នុងនោះរាប់បញ្ចូល កម្រិតក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អ្នកផ្តល់សេវា សហគមន៍ និងសង្គមស៊ីវិល។
- បង្កើតអង្គភាពសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួល ពិនិត្យតាមដាន និង រាយការណ៍អំពីការអនុវត្តផែនការ សកម្មភាព។
- មានការពង្រឹងប្រព័ន្ធការពារកុមារដែលមានស្រាប់ និងការសម្របសម្រួលឱ្យមានប្រព័ន្ធការពារកុមារជាអន្តរក្រសួង និងគ្រប់ជ្រុងជ្រោយមួយ។
- មានការពង្រឹងប្រព័ន្ធរាយការណ៍ដែលមានស្រាប់ និងការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីកិច្ចការពារកុមារ មួយនៅកម្រិតថ្នាក់ជាតិ ដោយមានបញ្ជាក់អំពីសូចនាករនៃអំពើហិង្សាលើកុមារ។

### ៤.៤.២. យុទ្ធសាស្ត្រទី២ ៖ ការទប់ស្កាត់បឋម

**គោលបំណង ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារនៅតាមផ្ទះ សាលារៀន សហគមន៍ និងក្នុងប្រព័ន្ធផ្សព្វផ្សាយ តាមរយៈយុទ្ធសាស្ត្រទប់ស្កាត់បឋម ដែលមានការសម្របសម្រួលជាពហុវិស័យជាមួយក្រសួង និងស្ថាប័ននានា សំដៅកំណត់គោលដៅតួអង្គ និងវិស័យសំខាន់ៗ ដើម្បីឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។

**លទ្ធផល ៖**

- មានការកើនឡើងនូវការលើកកម្ពស់ការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយ ដែលបង្ហាញរូបភាព និងសារប្រកបដោយសមធម៌យេនឌ័រ និង បទដ្ឋានសង្គមដែលមិនមានភាពហិង្សា។
- កិច្ចការពារពីអំពើហិង្សាចំពោះកុមារី និងកុមារានៅតាមសាលារៀន តាមរយៈក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់មានការកើនឡើង។
- សមត្ថភាពរបស់អ្នកផ្តល់សេវាដើម្បីគាំទ្រដល់ឪពុកម្តាយ និងអ្នកថែទាំ ក្នុងការអភិវឌ្ឍចំណេះដឹង និងជំនាញអំពីការចិញ្ចឹមកូនបែបវិជ្ជមាន ដើម្បីជួយកសាងគ្រួសារ និងបរិយាកាសឱ្យមានសុវត្ថិភាព សមធម៌យេនឌ័រ និងភាពអហិង្សាមានការកើនឡើង។
- កិច្ចការពារកុមារី និងកុមារា នៅក្នុងសហគមន៍ ឱ្យចាកផុតពីអំពើហិង្សា តាមរយៈការរៀបចំកម្មវិធីនៅតាមសហគមន៍ និងនៅទីតាំងគោរព សាសនា មានការកើនឡើង។

### ៤.៤.៣. យុទ្ធសាស្ត្រទី៣ ៖ សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ

**គោលបំណង ៖** ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ តាមរយៈការពង្រឹងសមត្ថភាពរបស់អ្នកផ្តល់សេវាសង្គម (សុខភាព អប់រំ យុត្តិធម៌ និងកិច្ចការពារកុមារ) ដើម្បីផ្តល់សេវាប្រកបដោយគុណភាពដល់កុមារី និងកុមារា ដែលបានទទួលរងបានឃើញ ឬមានការប្រឈម ទៅនឹងអំពើហិង្សា។

**លទ្ធផល ៖**

- លទ្ធភាពទទួលបានសេវាផ្លូវច្បាប់ ដែលមានការពង្រឹងបន្ថែម មានប្រសិទ្ធភាព និងមានលក្ខណៈកុមារមេត្រី របស់កុមារី និងកុមារា មានការកើនឡើង។

- សមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ក្នុងការដោះស្រាយផ្នែកច្បាប់ចំពោះកុមារី និងកុមារា ដែលមានលក្ខណៈស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្ស អន្តរជាតិ និងស្របទៅតាមសេចក្តីត្រូវការរបស់ពួកគេ មានការកើនឡើង។
- មានការពង្រឹង និងពង្រីកប្រព័ន្ធការពារកុមារមួយដែលមានលក្ខណៈបរិយាប័ន្ន ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ។
- សមត្ថភាពរបស់ប្រព័ន្ធ និង អ្នកវិជ្ជាជីវៈផ្នែកថែទាំសុខភាព ព្រមទាំងក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌ ច្បាប់របស់ពួកគេ ដើម្បីកិច្ចការពារកុមារី និងកុមារា មានការកើនឡើង។
- សមត្ថភាពរបស់ប្រព័ន្ធ និងអ្នកវិជ្ជាជីវៈផ្នែកអប់រំ ព្រមទាំងក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់របស់ពួកគេដើម្បីកិច្ចការពារកុមារី និងកុមារា មានការកើនឡើង។

### ៤.៤.៤. យុទ្ធសាស្ត្រទី៤ ៖ ការបង្កើត និងការធ្វើវិសោធនកម្មច្បាប់ និង ការអនុវត្តគោលនយោបាយ

**គោលបំណង ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារ តាមរយៈការពង្រឹងក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌ គោលនយោបាយដើម្បីបង្ការ និងការពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន និង ការមិនអើពើ។

**លទ្ធផល ៖**

- កិច្ចការពារកុមារី និងកុមារា ពីទណ្ឌកម្មលើរាងកាយ និងអំពើហិង្សាក្នុងគ្រួសារ តាមរយៈក្របខ័ណ្ឌច្បាប់ ស្របតាមបទដ្ឋានសិទ្ធិមនុស្ស អន្តរជាតិ មានការកើនឡើង
- កិច្ចការពារកុមារី និងកុមារា ពីអំពើហិង្សាផ្លូវភេទ តាមរយៈក្របខ័ណ្ឌច្បាប់ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មានការកើនឡើង
- កិច្ចការពារកុមារី និងកុមារា ពីគ្រប់ទម្រង់ទាំងអស់នៃភាពមិនអើពើ តាមរយៈក្របខ័ណ្ឌច្បាប់ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មានការកើនឡើង
- កិច្ចការពារកុមារី និងកុមារា ពីគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា តាមរយៈក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយស្តីពីកិច្ចការពារកុមារ មានការកើនឡើង ។

### ៤.៤.៥. យុទ្ធសាស្ត្រទី៥ ៖ ការពិនិត្យតាមដាន និងវាយតម្លៃ

**គោលបំណង ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារ តាមរយៈការអភិវឌ្ឍប្រព័ន្ធគ្រប់ជ្រុងជ្រោយមួយ សម្រាប់ប្រមូលទិន្នន័យ ពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍អំពីបទពិសោធន៍ដែលកុមារក្នុងប្រទេសកម្ពុជាបានជួបប្រទះ។

**លទ្ធផល ៖**

- មានការបង្កើតឡើងនូវក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃពហុវិស័យមួយ ព្រមទាំងប្រព័ន្ធប្រមូលទិន្នន័យ និងរាយការណ៍ដែលមាន ការសម្របសម្រួលជាពហុវិស័យ អំពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។
- មានមូលដ្ឋានភស្តុតាងរឹងមាំ សម្រាប់រៀបចំតាក់តែងយុទ្ធសាស្ត្រស្តីពីការបង្ការ និងការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។

# ៥. ក្របខ័ណ្ឌលទ្ធផលផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ

**លទ្ធផលទូទៅ ៖** អំពើហិង្សាលើកុមារនៅកម្ពុជា ជាពិសេសកុមារដែលមានហានិភ័យ និងមានភាពប្រឈម ត្រូវបានកាត់បន្ថយតាមរយៈកំណើនកិច្ចអន្តរាគមន៍ក្នុងការទប់ស្កាត់ ការពង្រឹងការឆ្លើយតបកំណើននៃការទទួលបានសេវាដែលមានគុណភាព និងតាមរយៈការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាពហុវិស័យ។

**សូចនាករលទ្ធផលទូទៅទី ១ ៖** ប្រេវ៉ាឡង់ស្តីពីអំពើហិង្សាលើរាងកាយ ផ្លូវចិត្ត និងផ្លូវភេទដែលកុមារជួបប្រទះបានកាត់បន្ថយ។
**សូចនាករលទ្ធផលទូទៅទី ២ ៖** ភាគរយនៃពលរដ្ឋកម្ពុជាដែលមិនគាំទ្រវាល់ទម្រង់នៃអំពើហិង្សាលើកុមារក្នុងគ្រប់បរិបទទាំងអស់ (ផ្ទះ សាលារៀន សហគមន៍)។

**យុទ្ធសាស្ត្រទី ១ ៖ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ**

**គោលបំណងទូទៅ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារតាមរយៈក្របខ័ណ្ឌស្ថាប័នជាពហុវិស័យសម្រាប់កិច្ចការពារកុមារដែលសម្របសម្រួលរវាងក្រសួងនិងស្ថាប័នផ្សេងៗពាក់ព័ន្ធលើយុទ្ធសាស្ត្រទប់ស្កាត់បឋម និងយុទ្ធសាស្ត្រឆ្លើយតប ដោយផ្តោតលើអ្នកពាក់ព័ន្ធ និងបរិបទសំខាន់សម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន។

**ផ្នែករងទី១ ៖ ក្របខ័ណ្ឌស្ថាប័នជាពហុវិស័យ សម្រាប់កិច្ចការពារកុមារ**

**លទ្ធផលទី១ ៖** កិច្ចសម្របសម្រួល និងសហប្រតិបត្តិការរវាងក្រសួង និងស្ថាប័នរបស់រដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍ អ្នកផ្តល់សេវាសហគមន៍ និងអង្គការសង្គមស៊ីវិល ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារនៅគ្រប់កម្រិតទាំងអស់មានការកើនឡើង។

**សូចនាករលទ្ធផលទី១ក ៖** ភាគរយនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានបញ្ចូលសូចនាករអំពីកិច្ចការពារកុមារ និងអំពើហិង្សាលើកុមារក្នុងផែនការសកម្មភាពស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ទៅក្នុងផែនការប្រតិបត្តិ ផែនការថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន។
**សូចនាករលទ្ធផលទី១ខ ៖** បង្កើតក្របខ័ណ្ឌរួមមួយ សម្រាប់ប្រព័ន្ធកិច្ចការពារកុមារជាអន្តរក្រសួងនៅក្នុងប្រទេសកម្ពុជា។

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១.១- ពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់ជាតិ និង គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ (គកសក) ថ្នាក់ខេត្ត ដោយមានមុខងារ ភារកិច្ច ជាអង្គភាពសំខាន់ក្នុងការសម្របសម្រួលការអនុវត្តផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតប ចំពោះអំពើហិង្សាលើកុមារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | សូចនាករ ១.១ក ៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានភារកិច្ចច្បាស់លាស់ក្នុងការសម្របសម្រួលការអនុវត្តផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | ១.១.១- ពង្រឹងតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (កជក) និងអគ្គលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារជាអង្គភាពសំខាន់នៅថ្នាក់ជាតិដើម្បីសម្របសម្រួល ការអនុវត្តផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | X | X | | | | ក្រសួងពាក់ព័ន្ធ |
| | សូចនាករ ១.១ខ ៖ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គកសក) ខេត្ត រៀបចំរបាយការណ៍ដាក់ជូនក្រសួងមហាផ្ទៃ ជាទៀតទាត់ | ១.១.២- ពង្រឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ ស្ត្រី និង កុមារនៅថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងរាយការណ៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារជាទៀងទាត់តាមរយៈក្រសួងមហាផ្ទៃ | ក្រសួងមហាផ្ទៃ | X | X | X | X | X | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ ស្ត្រី និងកុមារ (គកសក) ខេត្ត |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ១.១គ ៖ ភាគរយនៃក្រសួង ស្ថាប័ន ដែលបានបញ្ចូលសកម្មភាពក្នុងផែនការសកម្មភាពស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារទៅក្នុងផែនការប្រតិបត្តិ និង ផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន | ១.១.៣- សម្របសម្រួលនិងរៀបចំលិខិតគតិយុត្តិ ដើម្បីបញ្ចូលសកម្មភាពនានាពីផែនការសកម្មភាពស្តីពីការទប់ស្កាត់ និង ឆ្លើយតបចំពោះអំពើហិង្សាលើកុមារទៅក្នុងផែនការប្រតិបត្តិ និងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | X | X | X | X | X | ស្ថាប័នពាក់ព័ន្ធ |

**យុទ្ធសាស្ត្រទី ២៖ ការទប់ស្កាត់បឋម**

**គោលបំណងទូទៅ ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារនៅតាមផ្ទះ សាលារៀន សហគមន៍ និងក្នុងប្រព័ន្ធផ្សព្វផ្សាយ តាមរយៈយុទ្ធសាស្ត្រទប់ស្កាត់ បឋមដែលសម្របសម្រួលជាពហុវិស័យរវាងក្រសួង និងស្ថាប័ននានាដោយផ្តោតលើអង្គភាព និងវិស័យសំខាន់ៗ ដើម្បីការផ្លាស់ប្តូរបែបវិជ្ជមាន

**ផ្នែករងទី១ ៖ ប្រព័ន្ធផ្សព្វផ្សាយ យុទ្ធសាស្ត្រទំនាក់ទំនង និងព័ត៌មាន**

**លទ្ធផលទី ២ ៖** កំណើនប្រព័ន្ធផ្សព្វផ្សាយដែលលើកកម្ពស់បទដ្ឋានសង្គម រូបភាព និងសារនានា ដែលបង្ហាញពីសមធម៌យេនឌ័រ និងអហិង្សា

**សូចនាករលទ្ធផលទី២ក ៖** ចំនួនប្រជាពលរដ្ឋទទួលបានសារផ្សព្វផ្សាយលើកកម្ពស់បទដ្ឋានសង្គម ដែលបង្ហាញពីសមធម៌យេនឌ័រ និង អហិង្សាក្នុងមួយសប្តាហ៍/ខែ/ឆ្នាំ
**សូចនាករលទ្ធផលទី២ខ ៖** ចំនួនគ្រឹះស្ថានសារព័ត៌មានដែលអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ ឬ បទដ្ឋានគោលការណ៍ណែនាំក្នុងការរាយការណ៍អំពីករណីអំពើហិង្សាលើស្ត្រី និងកុមារ

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា (ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ២.១- សមត្ថភាពរបស់ប្រព័ន្ធផ្សព្វផ្សាយ និង កម្មវិធីបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង (ICT Platform) ត្រូវបានបង្កើន ដើម្បីលើកកម្ពស់បទដ្ឋានសង្គម រូបភាព និងសារនានាដែលបង្ហាញពីសមធម៌យេនឌ័រ និងអហិង្សា និងដើម្បីរាយការណ៍ ឬ ដកចេញខ្លឹមសារដែលបង្ហាញ ឬ គាំទ្រអំពើហិង្សាលើកុមារ | សូចនាករ២.១ក ៖ ចំនួនឪពុកម្តាយ អាណាព្យាបាល និងមន្ត្រីរដ្ឋបាល ថ្នាក់ក្រោមជាតិ ទទួលបានសារនានាដែលលើកកម្ពស់តួនាទីយ៉ាងសំខាន់របស់ពួកគេ ក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ និងលើកកម្ពស់បទដ្ឋានសង្គម ដែលបង្ហាញពីសមធម៌យេនឌ័រ និងអហិង្សាក្នុងមួយសប្តាហ៍ /ខែ/ឆ្នាំ | ២.១.១- បង្កើតយុទ្ធនាការផ្លាស់ប្តូរអាកប្បកិរិយា (ព័ត៌មាន និង ទំនាក់ទំនង) ដើម្បីដោះស្រាយ បញ្ហាអំពើហិង្សាលើកុមារតាមរយៈការលើកកម្ពស់តួនាទីរបស់គ្រួសារ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ អ្នកដឹកនាំសាសនា ប្រព័ន្ធផ្សព្វផ្សាយ និង អង្គការនៅសហគមន៍ដើម្បីការពារកុមារពីគ្រោះថ្នាក់ និង ដោះស្រាយ បទដ្ឋានយេនឌ័រ ដែលបង្កគ្រោះថ្នាក់ផ្សេងៗ | ក្រសួងកិច្ចការនារី/ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | X | X | X | X | X | ក្រសួងព័ត៌មាន<br>ក្រសួងធម្មការ និងសាសនា |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ ២.១ខ ៖<br>ចំនួនកុមារ កុមារវ័យជំទង់ និងយុវជន ដែលប្រើប្រាស់ទូរស័ព្ទដៃ និងអ៊ីនធឺណិត ដើម្បីទទួលបានព័ត៌មាន សមស្របតាមវ័យអំពីការទប់ស្កាត់អំពើហិង្សា ការប្រឈមចំពោះ អំពើហិង្សា ការរៀបអាពាហ៍ពិពាហ៍ក្នុងវ័យ កុមារ ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត សិទ្ធិ និង សុខភាពបន្តពូជ និង ព័ត៌មានអំពីអ្នកផ្តល់សេវាសំខាន់ៗ | ២.១.២- ពង្រឹង និងពង្រីក ចំណេះដឹងបន្ថែមអំពីកម្មវិធី បច្ចេកវិទ្យា ព័ត៌មាន និង ការប្រាស្រ័យទាក់ទង (ICT) ក្នុងប្រទេសកម្ពុជាដើម្បីបញ្ចូលព័ត៌មានអំពីការបង្ការនិងទប់ស្កាត់អំពើហិង្សា ការរៀបអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត និង អំពីសិទ្ធិ និង សុខភាពបន្តពូជ | ក្រសួងកិច្ចការនារី | X | X | X | X | X | ក្រសួងព័ត៌មាន<br>ក្រសួងសុខាភិបាល |
| | សូចនាករ ២.១គ ៖<br>ចំនួនសាធារណជន ទទួលបានសារសំខាន់ៗស្តីពីអំពើហិង្សាលើកុមារ ដែលលើកកម្ពស់បទដ្ឋានយេនឌ័រ សមធម៌យេនឌ័រ និងអហិង្សា ក្នុងមួយសប្តាហ៍/ខែ/ឆ្នាំ | ២.១.៣- លើកកម្ពស់កម្មវិធីកំសាន្តដើម្បីការអប់រំដែលផ្តល់សារអំពីទំនាក់ទំនងប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើហិង្សា | ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | X | X | ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងព័ត៌មាន<br>ក្រសួងទេសចរណ៍<br>ក្រសួងធម្មការ និងសាសនា |
| | សូចនាករ២.១ឃ ៖<br>ចំនួនក្រុមហ៊ុនឯកជន ប្រព័ន្ធផ្សព្វផ្សាយ ដែលបានបង្កើតគោលនយោបាយផ្ទៃក្នុងសម្រាប់កិច្ចការពារកុមារ និងនីតិវិធីសម្រាប់ដកចេញនូវខ្លឹមសារមិនសមស្របទាំងឡាយណាដែលបង្ហាញ ឬគាំទ្រអំពើហិង្សាលើកុមារ | ២.១.៤- បង្កើតគោលនយោបាយ និងនីតិវិធីកិច្ចការពារកុមារ សម្រាប់ដក ឬលុប ខ្លឹមសារមិនសមស្របទាំងឡាយណាដែលបង្ហាញ ឬគាំទ្រអំពើហិង្សាលើកុមារតាមរយៈកិច្ចសហការជាមួយក្រុមហ៊ុនឯកជន ប្រព័ន្ធទំនាក់ទំនងបច្ចេកវិទ្យា និង អ្នកផ្តល់សេវាអ៊ីនធឺណិត | ក្រសួងព័ត៌មាន | X | X | X | X | X | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២.២- សមត្ថភាពរបស់គ្រឹះស្ថានប្រព័ន្ធផ្សព្វផ្សាយត្រូវបានពង្រឹងដើម្បីឆ្លើយតប និងរាយការណ៍ឱ្យបានសមស្រប និងប្រុងប្រយ័ត្នចំពោះព័ត៌មានស្តីពីអំពើហិង្សាលើកុមារ | សូចនាករ២.២ក ៖ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សារព័ត៌មាន និងបទដ្ឋានគោលការណ៍ណែនាំ សម្រាប់រាយការណ៍អំពីអំពើហិង្សាលើកុមារបានបង្កើត | ២.២.១- បង្កើតក្រុមប្រឹក្សាផ្តល់យោបល់ផ្នែកប្រព័ន្ធផ្សព្វផ្សាយចំណុះឱ្យក្រុមការងារបច្ចេកទេសយេនឌ័រស្តីពីអំពើហិង្សាផ្នែកយេនឌ័រ (TWGG-GBV) ដើម្បី រៀបចំបង្កើតក្រុមសីលធម៌ វិជ្ជាជីវៈ សម្រាប់សារព័ត៌មាន និង គោលការណ៍ណែនាំ សម្រាប់រាយការណ៍អំពីអំពើហិង្សាលើកុមារ | ក្រសួងកិច្ចការនារី | | X | | | | ក្រសួងព័ត៌មាន<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងធម្មការ និងសាសនា<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងទេសចរណ៍<br>អាជ្ញាធរពាក់ព័ន្ធ |
| | សូចនាករ២.២ខ ៖ ចំនួនគ្រឹះស្ថានសារព័ត៌ មានទទួលបានការបណ្តុះបណ្តាលអំពីបញ្ហាអំពើហិង្សាលើស្ត្រី និងកុមារ | ២.២.២- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សារព័ត៌មានដល់គ្រឹះស្ថានសារព័ត៌មាន | ក្រសួងព័ត៌មាន | | X | X | X | X | ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងទេសចរណ៍<br>ក្រសួងយុត្តិធម៌<br>អាជ្ញាធរពាក់ព័ន្ធ |
| | សូចនាករ ២.២គ ៖ របាយការណ៍ផ្លូវការអំពីអ្នកផ្សព្វផ្សាយសារព័ត៌មានអនុវត្តតាមក្រមសីលធម៌សារព័ត៌មានដែលបានបោះពុម្ពផ្សាយ | ២.២.៣- រៀបចំពិធីសារជាផ្លូវការសម្រាប់ពិនិត្យតាមដានសារព័ត៌មាន និងបោះពុម្ពផ្សាយរបាយការណ៍ជាទៀងទាត់អំពី អ្នកផ្សព្វផ្សាយសារព័ត៌មានទាំងឡាយណាដែលបានអនុវត្ត តាមក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន | ក្រសួងព័ត៌មាន | | | X | X | X | ក្រុមប្រឹក្សាផ្តល់យោបល់សារព័ត៌មាន<br>ក្រុមការងារបច្ចេកទេសយេនឌ័រ ស្តីពីអំពើហិង្សាផ្នែកយេនឌ័រ |

## ផ្នែករងទី២៖ កម្មវិធីតាមសាលារៀន

**លទ្ធផលទី៣** ៖ កិច្ចការពារកុមារី និងកុមារា ពីអំពើហិង្សានៅតាមសាលារៀន តាមរយៈក្របខ័ណ្ឌច្បាប់ និងស្ថាប័នត្រូវបានបង្កើន

**សូចនាករលទ្ធផលទី៣ក** ៖ ចំនួនកុមារី និងកុមារាដែលទទួលបានអត្ថប្រយោជន៍ពីសេវាគាំពារកុមារនៅតាមសាលារៀន
**សូចនាករលទ្ធផលទី៣ខ** ៖ ចំនួនរបាយការណ៍អំពីកុមារទទួលរងអំពើហិង្សាដែលបានប្រព្រឹត្តដោយមិត្តភក្តិ ឬ គ្រូបង្រៀន
**សូចនាករលទ្ធផលទី៣គ** ៖ ចំនួនរបាយការណ៍អំពីកុមារទទួលរងអំពើហិង្សាក្នុងគ្រួសារ ឬ សហគមន៍ត្រូវបានរាយការណ៍ទៅកាន់មន្ត្រីការពារកុមារក្នុងសាលារៀន

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ៣.១- សមត្ថភាពស្ថាប័ន និងបុគ្គលិកអប់រំត្រូវបានបង្កើនដើម្បីទប់ស្កាត់ និងពិនិត្យតាមដានអំពើហិង្សាលើកុមារ និងលើកកម្ពស់សាលាដែលគ្មានអំពើហិង្សា | សូចនាករ ៣.១ក៖ ភាគរយនៃលោកគ្រូ និងអ្នកគ្រូ ដែលទទួលបានការបណ្តុះបណ្តាលអំពីការប្រើវិន័យ និងវិធីសាស្ត្របង្រៀនបែបវិជ្ជមានដើម្បីកំណត់អត្តសញ្ញាណ និងរាយការណ៍ អំពីករណីអំពើហិង្សាលើកុមារ | ៣.១.១- បង្កើត និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ដល់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសំខាន់ៗដទៃទៀតទាំងមុនពេលចេញបម្រើការ និងពេលកំពុងបម្រើការងារនៅតាមសាលារៀនអំពី៖<br>(ក) ការគ្រប់គ្រងអាកប្បកិរិយារបស់កុមារ និងការដាក់វិន័យបែបវិជ្ជមាន<br>(ខ) ការកំណត់អត្តសញ្ញាណ និងរាយការណ៍អំពីករណីអំពើហិង្សាលើកុមារ ពិសេសកុមារី និងកុមារាដែលប្រឈមនឹងការទទួលរងអំពើហិង្សា<br>(គ) ការលើកកម្ពស់សមភាព យេនឌ័រដែលរួមមានការអប់រំអំពីទំនាក់ទំនងផ្លូវភេទ ប្រកបដោយសុវត្ថិភាព និងបំណិនជីវិតដល់កុមារ<br>(ឃ) ការកសាងជំនាញគ្រប់គ្រងអារម្មណ៍ និងអាកប្បកិរិយារបស់កុមារក្នុងទំនាក់ទំនងអហិង្សា និងមិនរើសអើង ជាមួយកុមារដទៃទៀត<br>(ង) ការកសាងភាពធាប់ប្រសើរឡើង (resilience) របស់កុមារ<br>(ច) ការលើកកម្ពស់ការចូលរៀន របស់កុមារ និងលើកកម្ពស់ការយល់ដឹងអំពី សិទ្ធិកុមារ និងសេវាគាំពារកុមារ<br>(ឆ) ការកសាងជំនាញអំពីសុវត្ថិភាពក្នុងប្រព័ន្ធព័ត៌មានសង្គមដល់កុមារ ដើម្បី ទប់ស្កាត់ ការលួងលោម និងកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធព័ត៌មានសង្គម | ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | X | X | ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ ៣.១ខ ៖ ចំនួនសាលារៀនដែលអនុម័ត និងអនុវត្តគោលនយោបាយ និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារតាមសាលារៀន | ៣.១.២- បង្កើតគោលនយោបាយ និងក្រមសីលធម៌ស្តីពីកិច្ចការពារកុមារតាមសាលារៀន ដើម្បីការពារសុវត្ថិភាពរបស់កុមារពីគ្រោះថ្នាក់នានា និងហាមឃាត់គ្រប់ទម្រង់នៃ អំពើហិង្សា តាមរយៈសេចក្តីប្រកាសដែលតម្រូវឱ្យសាលារៀនទាំងអស់អនុវត្តតាមគោលនយោបាយនេះ | ក្រសួងអប់រំ យុវជន និងកីឡា | X | X | | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៣.១គ ៖ ចំនួនរបាយការណ៍ ទទួលបានពីប្រព័ន្ធ គ្រប់គ្រងព័ត៌មាន(MIS) ដែលមានទិន្នន័យ (ទាំងបរិមាណ និងគុណភាព) អំពីកិច្ចការពារកុមារ | ៣.១.៣- ដាក់បញ្ចូលសូចនាករ សំខាន់ៗអំពីកិច្ចការពារកុមារនៅក្នុងក្របខ័ណ្ឌពិនិត្យតាមដានកម្មវិធីសាលាកុមារមេត្រី (CFS) | ក្រសួងអប់រំ យុវជន និងកីឡា | X | | | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | | ៣.១.៤- បណ្តុះបណ្តាលក្រុមបណ្តុះបណ្តាល និងតាមដានថ្នាក់ស្រុក (DTMTs) អំពីការប្រមូលទិន្នន័យ និងការរាយការណ៍ពីសូចនាករស្តីពីកិច្ចការពារកុមារ | ក្រសួងអប់រំ យុវជន និងកីឡា | X | X | | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៣.១ឃ ៖ ចំនួននិងប្រភេទសម្ភារៈដែលលើកកម្ពស់អំពើហិង្សាលើកុមារ ឬវិសមភាពយេនឌ័រ បានដកចេញពីកម្មវិធីសិក្សា និងសាលារៀន | ៣.១.៥- ពិនិត្យឡើងវិញកម្មវិធី សិក្សាសំខាន់ៗនៅកម្រិតសាលាមត្តេយ្យ បឋម និងមធ្យមសិក្សា ដើម្បីដកសម្ភារ និងរូបភាពទាំងឡាយ មានក្នុងសៀវភៅកម្មវិធីសិក្សា ដែលលើកកម្ពស់អំពើហិង្សាលើកុមារ ឬ វិសមភាពយេនឌ័រ | ក្រសួងអប់រំ យុវជន និងកីឡា | X | X | | | | ក្រសួងកិច្ចការនារី |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣.២- សមត្ថភាពកុមារ និងមនុស្សវ័យជំទង់ត្រូវបានបង្កើន ក្នុងការការពារខ្លួន ហ៊ាននិយាយពីអំពើហិង្សាគ្រប់ទម្រង់ និងកសាងទំនាក់ទំនងសមធម៌ យេនឌ័រ និងអហិង្សា | សូចនាករ ៣.២ក ៖ ចំនួនសាលារៀន អនុវត្តកម្រង កម្មវិធីសិក្សាអំពីផ្លូវភេទ និងទំនាក់ទំនងប្រកបដោយសុវត្ថិភាព | ៣.២.១- រៀបចំ និងបញ្ចូលកម្រង មេរៀនពេញលេញអំពីទំនាក់ទំនងផ្លូវភេទ និងទំនាក់ទំនង ដែលមានសុវត្ថិភាព ក្នុងកម្មវិធីសិក្សាសំខាន់ៗនៅកម្រិតសាលាមត្តេយ្យ បឋម និងមធ្យមសិក្សា សមស្របតាមអាយុ ដូចជា ៖<br>(ក) ជំនាញក្នុងការកំណត់អត្តសញ្ញាណនិងរាយការណ៍ពីអំពើហិង្សា អំពើរំលោភបំពាន ការមិនយកចិត្តទុកដាក់និងការកសាងភាពធាប់ប្រសើរឡើង(resilience)<br>(ខ)សុខភាពផ្លូវភេទនិងសុខភាព បន្តពូជ សិទ្ធិ និងកាតព្វកិច្ច ចំពោះមុខច្បាប់<br>(គ) ខ្លឹមសារសមស្របតាមវ័យអំពីទំនាក់ទំនងល្អនិងការគោរពគ្នាទៅវិញទៅមក<br>(ឃ) ការប្រឈមនឹងបទដ្ឋាន យេនឌ័រដែលបង្កគ្រោះថ្នាក់<br>(ង) បញ្ហានានាដែលទាក់ទងនឹងសិទ្ធិក្នុងការរួមភេទ<br>(ច) ផ្នែកឯកជននៃរូបរាងកាយ និងការប៉ះពាល់ដែលមានសុវត្ថិភាព (ថ្នាក់មត្តេយ្យ)<br>(ឆ)សុវត្ថិភាពក្នុងការប្រើប្រព័ន្ធ ព័ត៌មានសង្គម ដើម្បីបង្ការទប់ស្កាត់ការលួងលោម និងការកេងចំណេញផ្លូវភេទតាមប្រព័ន្ធព័ត៌មានសង្គម | ក្រសួងអប់រំ យុវជន និងកីឡា | X | X | | | | ក្រសួងមហាផ្ទៃ<br>ក្រសួងយុត្តិធម៌<br>ក្រសួងសុខាភិបាល |
| | សូចនាករ ៣.២ខ ៖ ចំនួនសាលារៀន ដែលបានបញ្ចូលកម្រងឯកសារមេរៀនអំពីការចិញ្ចឹមកូនបែបវិជ្ជមាន ក្នុងកម្មវិធីសិក្សាសំខាន់ៗ | ៣.២.២- បង្កើតកម្រងមេរៀន អំពីការចិញ្ចឹមកូនបែបវិជ្ជមានសម្រាប់យុវជន ដោយផ្អែកលើ កម្រងឯកសារមេរៀន អំពីការចិញ្ចឹមកូនបែបវិជ្ជមានដែលក្រសួងកិច្ចការនារីបានរៀបចំនិងបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា | ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | X | | ក្រសួងកិច្ចការនារី |
| | សូចនាករ ៣.២គ ៖ ចំនួនកម្មវិធីមិត្តអប់រំមិត្ត បានបង្កើតនៅតាមសាលារៀន | ៣.២.៣- បង្កើត និងលើកកម្ពស់ អភិក្រមសម្រាប់កម្មវិធីមិត្តអប់រំ មិត្តនៅតាមសាលារៀន ដើម្បី លើកទឹកចិត្តកុមារី និងកុមារាឱ្យគាំទ្រនិយាម និងការអនុវត្តបែប អហិង្សា បទដ្ឋានយេនឌ័រដែល មិនបង្កគ្រោះថ្នាក់ និងលើកកម្ពស់សមភាពយេនឌ័រ | ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |

### ផ្នែករងទី៣៖ គាំទ្រដល់ឪពុកម្តាយ អាណាព្យាបាល និងគ្រួសារ

**លទ្ធផលទី៤** ៖ បង្កើនសមត្ថភាពរបស់ អ្នកផ្តល់សេវា ដើម្បីគាំទ្រការផ្តល់ចំណេះដឹង និងជំនាញចិញ្ចឹមបីបាច់កូនបែបវិជ្ជមានដល់ឪពុកម្តាយ និងអាណាព្យាបាលក្នុងការជួយកសាងគ្រួសារ និងបរិយាកាសដែលមានសុវត្ថិភាព សមធម៌យេនឌ័រ និងអហិង្សា

**សូចនាករលទ្ធផលទី៤ក** ៖ ចំនួនឪពុកម្តាយដែលបានទទួលព័ត៌មានអំពីវិធីបង្កើតទំនាក់ទំនងមានសុវត្ថិភាព និងរឹងមាំជាមួយកូន និងក្នុងគ្រួសាររបស់ពួកគេ ដោយប្រើការដាក់វិន័យកូនបែបអហិង្សា និងមិនបង្កគ្រោះថ្នាក់

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ៤.១- អ្នកផ្តល់សេវាសម្រាប់កុមារ និង ក្រុមគ្រួសាររបស់ពួកគេត្រូវបានបង្កើនសមត្ថភាពដើម្បីផ្តល់ព័ត៌មាន និងជំនាញ ពិគ្រោះយោបល់អំពីការចិញ្ចឹមកូនបែបវិជ្ជមាន កម្រិតមូលដ្ឋាន | សូចនាករ ៤.១ក ៖ មេរៀននិងកម្មវិធីបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការចិញ្ចឹមបីបាច់កូនបែបវិជ្ជមាន ដែលមានផ្នែកជាក់លាក់សម្រាប់ឪពុកម្តាយមានកូនពិការ ត្រូវបានបង្កើត | ៤.១.១- ផ្តែកលើយុទ្ធសាស្ត្រ ចិញ្ចឹមកូនបែបវិជ្ជមាន ៖<br>បង្កើតកម្រងឯកសារ ចិញ្ចឹមកូនបែបវិជ្ជមាន រៀបចំជំពូកមេរៀនពិសេស ក្នុងកម្រងឯកសារ ចិញ្ចឹមកូន បែបវិជ្ជមាន ដើម្បីគាំទ្រឪពុកម្តាយ ដែលមានកូនពិការ | ក្រសួងកិច្ចការនារី | X | | | | | ក្រសួងសុខាភិបាល<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងមហាផ្ទៃ<br>ក្រសួងធម្មការ និងសាសនា<br>ក្រសួងព័ត៌មាន<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>NGOs |
| | សូចនាករ ៤.១ខ ៖ ភាគរយនៃអ្នកផ្តល់សេវាសង្គមបានទទួលការបណ្តុះបណ្តាលអំពីការចិញ្ចឹមកូនបែបវិជ្ជមានកម្រិតមូលដ្ឋាន ដើម្បីផ្តល់ព័ត៌មាន និងមតិយោបល់អំពីចំណេះដឹងមូលដ្ឋានស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ដល់ឪពុកម្តាយ អាណាព្យាបាល និងសាធារណជន | ៤.១.២- ផ្តែកលើកម្រងឯកសារ ចិញ្ចឹមកូនបែបវិជ្ជមានកម្រិត ១៖<br>ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្គោលបណ្តុះបណ្តាលអ្នកផ្តល់សេវាសង្គម និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់នូវចំណេះដឹងមូលដ្ឋាន អំពីការចិញ្ចឹមកូនបែបវិជ្ជមាន ដល់សាធារណជន ស្វែងរកការគាំទ្រមតិដើម្បីដាក់បញ្ចូលកម្រងកម្មវិធីសិក្សាកម្រិត ១ សម្រាប់បណ្តុះបណ្តាលអ្នកផ្តល់សេវាសង្គម ទាំងមុនពេល និង អំឡុងពេលបម្រើការងារ | ក្រសួងកិច្ចការនារី | X | X | X | X | X | ក្រសួងសុខាភិបាល<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងមហាផ្ទៃ<br>ក្រសួងធម្មការ និងសាសនា<br>NGOs |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ ៤.១គ ៖ ចំនួនឪពុកម្តាយ និងអាណាព្យាបាលក្នុងគ្រួសារដែលប្រឈមនឹងការប្រព្រឹត្តអំពើហិង្សា និងការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ បានទទួលការគាំទ្រក្នុងការចិញ្ចឹមកូនបែបវិជ្ជមាន | ៤.១.៣- ផ្តែកលើកម្រងឯកសារ ចិញ្ចឹមកូនបែបវិជ្ជមានកម្រិត២ ៖ គាំទ្រអ្នកផ្តល់សេវាសង្គម ដើម្បីបង្កើតក្រុមអន្តរាគមន៍ចិញ្ចឹមកូនបែបវិជ្ជមាន ដោយផ្តោតគោលដៅលើគ្រួសារដែលប្រឈមនឹងការប្រព្រឹត្តិអំពើហិង្សា ឬការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | X | X | X | X | X | ក្រសួងកិច្ចការនារី NGOs |
| ៤.២- ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាសង្គម ដើម្បីគាំទ្រឪពុកម្តាយ អាណាព្យាបាលកុមារ ដែលទទួលរង ឬកំពុងប្រឈមនឹងអំពើហិង្សាលើរាងកាយ និង/ឬ អំពើហិង្សាផ្លូវភេទ និងដើម្បីលើកកម្ពស់សមាហរណកម្មកុមារចេញពីមណ្ឌលថែទាំជំនួសទៅគ្រួសារវិញប្រកបដោយប្រសិទ្ធភាព | សូចនាករ ៤.២ក ៖ ចំនួនឪពុកម្តាយ និងអាណាព្យាបាលរបស់កុមារដែលជាជនរងគ្រោះ ឬកុមារដែលបានធ្វើសមាហរណកម្មពីមណ្ឌលថែទាំ ដែលបានទទួលការគាំទ្រសេវាជំនាញអំពីការចិញ្ចឹមកូនបែបវិជ្ជមាន | ៤.២.១- ផ្តែកលើកម្រងឯកសារចិញ្ចឹមកូនបែបវិជ្ជមានកម្រិត ៣ ៖ ពង្រឹងសមត្ថភាព អ្នកផ្តល់សេវាសង្គម ដើម្បីគាំទ្រនិងការផ្តល់ព័ត៌មាន អំពីការចិញ្ចឹមកូនបែបវិជ្ជមាន។ សេវាប្រឹក្សាយោបល់ និង ជំនួយហិរញ្ញវត្ថុ ជាផ្នែកមួយ ឆ្លើយតបនឹងកិច្ចការពារកុមារ នៅពេលពួកគេទទួលរង ឬ ប្រឈម នឹងអំពើហិង្សាលើរាងកាយ និង/ឬអំពើហិង្សាផ្លូវភេទ ឬ ការមិនយកចិត្តទុកដាក់ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | X | X | X | X | X | ក្រសួងកិច្ចការនារី NGOs |

## ផ្នែករងទី៤៖ កម្មវិធីក្នុងសហគមន៍

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| **លទ្ធផលទី៥** ៖ បង្កើនកិច្ចការពារកុមារី និងកុមារា ពីអំពើហិង្សានៅតាមទីកន្លែងសាសនា និងកម្មវិធីក្នុងសហគមន៍ រួមទាំងកុមារី និងកុមារាដែលមានហានិភ័យ ខ្ពស់ក្នុងការទទួលរងអំពើហិង្សា | | | | | | | | | |
| **សូចនាករលទ្ធផលទី ៥ក** ៖ ភាគរយកម្មវិធីក្នុងសហគមន៍ និង តាមទីកន្លែងប្រណិប័តន៍សាសនាបានដោះស្រាយករណីអំពើហិង្សាដែលបានរាយការណ៍ | | | | | | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ៥.១- កំណើនសមត្ថភាពរបស់មជ្ឈមណ្ឌលសាសនា មេដឹកនាំ សាសនា និងកម្មវិធីសហគមន៍ ដើម្បីបង្ការទប់ស្កាត់ កំណត់អត្តសញ្ញាណ និងឆ្លើយតបនឹងករណីអំពើហិង្សាលើកុមារ | សូចនាករ ៥.១ក ៖ ចំនួនអង្គការយុវជន ដែលអនុវត្តអភិក្រម មិត្តអប់រំមិត្ត | ៥.១.១ - បង្កើត និងលើកកម្ពស់កម្មវិធីមិត្តអប់រំមិត្ត ដល់អង្គការយុវជន ដើម្បីលើកទឹកចិត្តកុមារា និងកុមារីឱ្យគាំទ្របទដ្ឋាន និងការអនុវត្តអហិង្សា បទដ្ឋានយេនឌ័រមិនបង្កគ្រោះថ្នាក់ និងសមធម៌ យេនឌ័រ | ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៥.១ខ៖ ចំនួនវត្តអារាមដែលអនុវត្តកម្មវិធីកិច្ចការពារកុមារ | ៥.១.២- អនុវត្តកម្មវិធីកិច្ចការពារ កុមារតាមវត្តអារាម នៅក្នុងខេត្ត ចំនួន ៥ | ក្រសួងធម្មការ និងសាសនា | X | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៥.១គ៖ កម្រងមេរៀនស្តីពីកិច្ចការពារកុមារបានបញ្ចូលទៅក្នុងកម្មវិធីពុទ្ធិកសិក្សា | ៥.១.៣- បញ្ចូលប្រធានបទអំពី កិច្ចការពារកុមារ ក្នុងកម្មវិធីពុទ្ធិកសិក្សា | ក្រសួងធម្មការ និងសាសនា | X | X | | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៥.១ឃ៖ ចំនួនសហគមន៍ជនជាតិភាគតិចដែលអនុវត្តក្របខ័ណ្ឌ កិច្ចការពារកុមារ ពីអាពាហ៍ពិពាហ៍វ័យកុមារ និងការមាន ផ្ទៃពោះវ័យជំទង់ | ៥..១.៤- បង្កើត និង អនុវត្តក្របខ័ណ្ឌកិច្ចការពារកុមារដើម្បីទប់ ស្កាត់អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ និង ការមានផ្ទៃពោះក្នុងវ័យជំទង់ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច | ក្រសួងកិច្ចការនារី | X | X | X | X | X | ក្រសួងសុខាភិបាល |
| | សូចនាករ៥.១ង៖ ចំនួនកុមារា និងកុមារីដែលបានបោះបង់ការសិក្សា ទទួលបានសេវាដែលផ្សព្វផ្សាយ | ៥.១.៥- ពង្រីកសេវាកម្មក្នុងសហគន៍ដោយផ្តោតលើកុមារា និង កុមារី ដែលបោះបង់ការសិក្សា ដើម្បីផ្តល់ព័ត៌មានមូលដ្ឋានដល់ពួកគេអំពីសិទ្ធិកុមារ និង របៀបរាយការណ៍អំពីការរំលោភបំពាន និងអំពើហិង្សា | ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | X | X | ក្រសួងព័ត៌មាន<br>ក្រសួងមហាផ្ទៃ |

**យុទ្ធសាស្រ្តទី ៣៖ សេវាឆ្លើយតបជាពហុវិស័យ ចំពោះកិច្ចការពារកុមារ**

**គោលបំណងទូទៅ៖** ដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើកុមារតាមរយៈការពង្រឹងសមត្ថភាពរបស់អ្នកផ្តល់សេវាសង្គម (សុខភាព អប់រំ យុត្តិធម៌ និងកិច្ច ការពារកុមារ) ដើម្បីផ្តល់សេវាដែលមានគុណភាពក្នុងការការពារកុមារី និងកុមារាដែលធ្លាប់ទទួលរង ឬ ជួបប្រទះ ឬ ដែលប្រឈមនឹងអំពើហិង្សា

**ផ្នែករងទី១៖ ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព**

**លទ្ធផលទី ៦៖** កុមារី និងកុមារាដែលមានទំនាក់ទំនងជាមួយផ្លូវច្បាប់ ទទួលបានកិច្ចការពារ ពីការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈកុមារមេត្រី មានការកើនឡើង

**សូចនាករលទ្ធផលទី ៦ក៖** ចំនួនករណីរំលោភបំពានកុមារ និងករណីកិច្ចការពារកុមារដទៃទៀតបានចាត់ការដោយមន្ត្រីជំនាញ (មន្ត្រីចាត់តាំង) ផ្នែកកិច្ចការពារកុមារ (បែងចែកតាមវិស័យ និង/ឬតួនាទី ដូចជាមន្ត្រីនគរបាល មន្ត្រីតុលាការ ។ល។)

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ៦.១.១- មន្ត្រី អនុវត្តច្បាប់មាន សមត្ថភាពកាន់ តែប្រសើរឡើង ដើម្បីឆ្លើយតបនឹងករណីកុមារដែលមានទំនាក់ទំនងជាមួយច្បាប់ | សូចនាករ ៦.១ក៖ ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់មន្ត្រីអនុវត្តច្បាប់បានបង្កើត | ៦.១.១- បង្កើតក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់មន្ត្រីអនុវត្តច្បាប់ | ក្រសួងមហាផ្ទៃ | X | X | | | | ក្រសួងកិច្ចការនារី<br>ក្រសួងទេសចរណ៍<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងយុត្តិធម៌<br>ក្រសួងអប់រំ យុវជន និងកីឡា |
| | សូចនាករ ៦.១ខ៖ កម្រងមេរៀនស្តីពីកិច្ចការពារកុមារកម្រិតមូលដ្ឋានសម្រាប់មន្ត្រីអនុវត្តច្បាប់បានបង្កើត | ៦.១.២- បង្កើតកម្រងមេរៀនស្តីពីកិច្ចការពារកុមារកម្រិតមូលដ្ឋាន រួមទាំងកម្រងមេរៀនកម្រិតមូលដ្ឋាន ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាម ប្រព័ន្ធអ៊ីនធឺណិត ដើម្បីបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីអនុវត្តច្បាប់ | ក្រសួងមហាផ្ទៃ | X | X | | | | ក្រសួងកិច្ចការនារី<br>ក្រសួងទេសចរណ៍<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងយុត្តិធម៌ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ ៦.១គ៖ ភាគរយ និងចំនួនមន្ត្រីនគរបាល និងមន្ត្រីអនុវត្តច្បាប់បានទទួលការបណ្តុះបណ្តាលចំណេះដឹងអំពីកិច្ចការពារកុមារកម្រិតមូលដ្ឋាន( ទាំងមន្ត្រីកំពុងបម្រើការនិងមន្ត្រីដែលមិនទាន់ចេញបម្រើការ ) | ៦.១.៣- ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ ទាំងមុនពេលចេញបម្រើការងារ និងអំឡុងពេលបម្រើការងារអំពីកម្រងមេរៀនស្តីពីកិច្ចការពារកុមារកម្រិតមូលដ្ឋាន ។ | ក្រសួងមហាផ្ទៃ | | X | X | X | X | ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និង យុវនីតិសម្បទា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងយុត្តិធម៌ |
| ៦.២- កុមារមានទំនាក់ទំនងជាមួយផ្លូវច្បាប់ទទួលបានកិច្ចការពារកើនឡើង និងមានលក្ខណៈកុមារមេត្រីមន្ត្រីនគរបាល | សូចនាករ ៦.២ក៖ កម្រងមេរៀនកម្រិតខ្ពស់ស្តីពីកិច្ចការពារកុមារ បានបង្កើត | ៦.២.១- បង្កើតកម្រងមេរៀនស្តីពីកិច្ចការពារកុមារកម្រិតខ្ពស់ សម្រាប់មន្ត្រីនគរបាលដែលបានចាត់តាំង ដោយមានការទទួលខុសត្រូវចំពោះកិច្ចការពារកុមារ អំពីមេរៀនដូចជា ៖<br>( ក ) ការស៊ើបអង្កេត<br>( ខ ) ការគ្រប់គ្រងករណី<br>( គ ) ការសម្ភាស៍មានលក្ខណៈកុមារមេត្រី និង មានប្រសិទ្ធភាព សម្រាប់ជនរងគ្រោះដោយ អំពើហិង្សាជាកុមារ<br>( ឃ ) ការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រព័ន្ធអ៊ីនធឺណិត រួមទាំងការស៊ើបអង្កេត អំពើលួងលោម តាមប្រព័ន្ធអ៊ីនធឺណិត (grooming) ឬ ការជ្រើសរើសក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងសម្ភារៈ ឬ រូបភាពអាសអាភាសកុមារ | ក្រសួងមហាផ្ទៃ | X | X | | | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា<br>ក្រសួងកិច្ចការនារី<br>ក្រសួងទេសចរណ៍<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | សូចនាករ៦.២ខ៖ ចំនួនមន្ត្រីនគរបាលដែលបានចាត់តាំងសម្រាប់កិច្ច ការពារកុមារបានទទួលការបណ្តុះបណ្តាលចំណេះដឹងស្តីពីកិច្ចការពារកុមារកម្រិតខ្ពស់ | ៦.២.២- ផ្តល់វគ្គបណ្តុះបណ្តាលកំរិតខ្ពស់ អំពីកិច្ចការពារកុមារ ជាផ្នែកមួយនៃវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាល ដែលបានចាត់តាំង សម្រាប់កិច្ចការពារកុមារ ទាំងមុនពេលចេញបម្រើការ និងពេលកំពុងបម្រើការងារ ) | ក្រសួងមហាផ្ទៃ | | X | X | X | X | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ៦.២គ៖ ភាគរយនិងចំនួន មន្ត្រីអនុវត្តច្បាប់ជាស្ត្រី បានទទួលការបណ្តុះបណ្តាលអំពីកិច្ចការពារកុមារ | ៦.២.៣- ជ្រើសរើសមន្ត្រីអនុវត្តច្បាប់ជាស្ត្រី ជាមន្ត្រីនគរបាល និង កងរាជអាវុធហត្ថ (យ៉ាងហោចណាស់មានមន្ត្រីអនុវត្ត ច្បាប់ ជាស្ត្រី ១នាក់ បានទទួលការបណ្តុះបណ្តាលអំពីកិច្ចការពារកុមារ ដែលបម្រើការនៅប៉ុស្តិ៍នគរបាល និងប៉ុស្តិ៍កងរាជអាវុធហត្ថ) | ក្រសួងមហាផ្ទៃ | | X | X | X | X | ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |
| ៦.៣- បង្កើតនីតិ វិធី/ បទដ្ឋានពិធីសារប្រតិបត្តិ សម្រាប់មន្ត្រីអនុវត្តច្បាប់ ដើម្បីដោះស្រាយ ករណីកុមារមានទំនាក់ទំនងជាមួយច្បាប់ និងដាក់បញ្ចូលក្នុងនីតិវិធីប្រតិបត្តិការ សម្រាប់មន្ត្រីនគរបាល | សូចនាករ ៦.៣ក៖ នីតិវិធី/បទដ្ឋានពិធីសារប្រតិបត្តិសម្រាប់ករណីកុមារមានទំនាក់ទំនងជាមួយច្បាប់បានបង្កើត | ៦.៣.១- បង្កើតនីតិវិធី ឬ បទដ្ឋានពិធីសារប្រតិបត្តិ (Standard Operating Procedure) និងមានលក្ខណៈកុមារមេត្រីសម្រាប់ដោះស្រាយករណីកុមារដែលមានទំនាក់ទំនងជាមួយផ្លូវច្បាប់ រួមមាន៖<br>(ក) នីតិវិធីស៊ើបអង្កេតអន្តរវិស័យ<br>(ខ) ពិធីសារយុត្តិធម៌កុមារមេត្រី<br>(គ) យន្តការបញ្ជូន និងឆ្លើយតប<br>(ឃ) ការគាំទ្រដល់កុមារដែលមានទំនាក់ទំនងជាមួយច្បាប់ ក្នុងអំឡុងពេលស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពេលកាត់ក្តី និងក្រោយពេលកាត់ក្តី<br>(ង) ចងក្រងឯកសារ និងតាមដានគ្រប់របាយការណ៍ និង ករណីកិច្ចការពារកុមារដែលបានរាយការណ៍ឱ្យមន្ត្រីនគរបាល និងលទ្ធផលនៃការរាយការណ៍អំពីករណីទាំងនេះ | ក្រសួងមហាផ្ទៃ | | X | | | | ក្រសួងយុត្តិធម៌ |
| | សូចនាករ៦.៣ខ៖ ភាគរយ និងចំនួនករណីកុមារ មានទំនាក់ទំនងនឹងច្បាប់ បានចាត់ការស្របតាមនីតិវិធី ឬ ពិធីសារប្រតិបត្តិ ដែលបានបង្កើត | ៦.៣.២- ពង្រឹងសមត្ថភាពដល់ មន្ត្រីអនុវត្តច្បាប់ ដើម្បីអនុវត្តនីតិវិធី ឬ បទដ្ឋានពិធីសារប្រតិបត្តិ សម្រាប់ដោះស្រាយករណីកុមារមានទំនាក់ទំនងជាមួយច្បាប់ | ក្រសួងមហាផ្ទៃ | | | X | X | X | ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |

## ផ្នែករងទី២៖ ការទទួលបានយុត្តិធម៌កុមារមេត្រី

**លទ្ធផលទី៧៖** សមត្ថភាពរបស់ប្រព័ន្ធយុត្តិធ៌មត្រូវបានពង្រឹង និងអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីបង្កើនការយកចិត្តទុកដាក់សម្រាប់កុមារី និងកុមារាដែលមានទំនាក់ទំនងជាមួយច្បាប់ និងឆ្លើយតបតាមសេចក្តីត្រូវការរបស់កុមារ

**សូចនាករលទ្ធផលទី ៧ក៖** ភាគរយនៃតុលាការ ដែលកុមារផ្តល់កស្តុតាងក្នុងនាមជាជនរងគ្រោះ ឬ ជាសាក្សីនៃអំពើហិង្សាតាមនីតិវិធីកុមារមេត្រី (វាស់វែងដោយប្រៀបធៀបជាមួយនឹងទិន្នន័យគោល) មានចំនួនកើនឡើង

**សូចនាករលទ្ធផលទី ៧ខ៖** ភាគរយនៃកុមារដែលមានទំនាក់ទំនងជាមួយផ្លូវច្បាប់ ទទួលបានព័ត៌មានអំពីច្បាប់ ការពិគ្រោះយោបល់ និងជំនួយផ្លូវច្បាប់ ដែលមានលក្ខណៈកុមារមេត្រី (បែងចែកតាមភេទ និង វាស់វែងដោយប្រៀបធៀបទិន្នន័យគោល)

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ៧.១- សមត្ថភាពរបស់មន្ត្រីតុលាការត្រូវបានពង្រឹង ក្នុងការអនុវត្តនីតិវិធីកុមារមេត្រីសម្រាប់ដោះស្រាយករណីកុមារ ដែលមានទំនាក់ទំនងជាមួយច្បាប់ | សូចនាករ ៧.១ក៖ ភាគរយ នៃចៅក្រម និងព្រះរាជអាជ្ញាទទួលបន្ទុកដោះស្រាយករណីកុមារមានទំនាក់ទំនងជាមួយច្បាប់ ទទួលបានការបណ្តុះបណ្តាលអំពីការគ្រប់គ្រងករណីអំពើហិង្សាលើកុមារ (បែងចែករវាងមន្ត្រីដែលកំពុងបម្រើការនិងមិនទាន់ចេញបម្រើការ) | ៧.១.១- បង្កើត និងអនុវត្តកម្រង មេរៀនស្តីពីការគ្រប់គ្រងករណី ដោយបញ្ចូលកុមារដែលជាជនរងគ្រោះ កុមារជាសាក្សី និងជាជនល្មើស និងបញ្ចូលកម្មវិធីបណ្តុះបណ្តាលស្តីពីអំពើកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត រួមមានការស៊ើបអង្កេតអំពើលួងលោម (grooming) និងការផលិតសម្ភារៈ ឬ រូបភាពអាសអាភាសកុមារតាមប្រព័ន្ធអ៊ីនធឺណិតក្នុងវគ្គបណ្តុះបណ្តាល | ក្រសួងយុត្តិធម៌ | X | X | X | X | X | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ |
| | សូចនាករ ៧.១ខ៖ ភាគរយនៃតុលាការដែលបានបញ្ចូលនីតិវិធីកុមារមេត្រីទៅក្នុងបទដ្ឋានពិធីសារប្រតិបត្តិ | ៧.១.២- ពង្រឹងការអនុវត្តនីតិវិធី កុមារមេត្រីដើម្បីដោះស្រាយករណីកុមារដែលមានទំនាក់ទំនងជាមួយច្បាប់ | ក្រសួងយុត្តិធម៌ | X | X | X | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៧.១គ៖ ចំនួនករណីអនីតិជនទទួលបានការដោះស្រាយដោយចៅក្រមនិងព្រះរាជអាជ្ញាដែលទទួលបានការបណ្តុះបណ្តាលពីបទពិសោធន៍ល្អៗក្នុងការដោះស្រាយករណីអនីតិជន | ៧.១.៣- បង្កើតតុលាការដាច់ ដោយឡែកសម្រាប់ករណីកុមារ ដែលមានព្រះរាជអាជ្ញា និងចៅក្រមទទួលបានការបណ្តុះបណ្តាលពីបទពិសោធន៍ល្អៗក្នុងការដោះស្រាយករណីអនីតិជន | ក្រសួងយុត្តិធម៌ | | X | X | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៧.២- កុមារដែលមានទំនាក់ទំនងជាមួយច្បាប់ ទទួលបានសេវាផ្នែកច្បាប់ក្នុងប្រព័ន្ធតុលាការមានការកើនឡើង | សូចនាករ ៧.២ក៖ ចំនួនកម្មវិធីយុត្តិធម៌ជំនួស និង យុត្តិធម៌ស្តារឡើងវិញ បានសាកល្បង និងចងក្រងជាឯកសារ | ៧.២.១- អនុវត្តយន្តការគំរូយុត្តិធម៌ជំនួសឱ្យការឃុំខ្លួន និងយុត្តិធម៌ស្តារឡើងវិញ សម្រាប់ករណីអំពើហិង្សាលើកុមារកម្រិតស្រាលនិងមធ្យម ក្នុងវិស័យយុត្តិធម៌ (ផ្លូវការ និង ក្រៅផ្លូវការ) | ក្រសួងយុត្តិធម៌ | | X | | | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ |
| | សូចនាករ ៧.២ខ៖ ភាគរយនៃកំណើនកុមារដែលមានទំនាក់ទំនងជាមួយផ្លូវច្បាប់បានទទួលសេវាច្បាប់ និងតំណាងស្របច្បាប់ | ៧.២.២- ផ្តល់ជំនួយនិងសេវាផ្នែកច្បាប់ ដល់កុមារដែលមានទំនាក់ទំនងជាមួយច្បាប់ នៅថ្នាក់ក្រោមជាតិ | ក្រសួងយុត្តិធម៌ | | X | X | X | X | ក្រសួងមហាផ្ទៃ NGOs |

## ផ្នែករងទី៣៖ សេវាសង្គម និងការស្តារនីតិសម្បទា

**លទ្ធផលទី ៨៖** ពង្រឹង និងពង្រីក ប្រព័ន្ធកិច្ចការពារកុមារ ដើម្បីបង្ការនិងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ

**សូចនាករលទ្ធផលទី ៨ក៖** ភាគរយនៃកុមារដែលបានរាយការណ៍ពីអំពើហិង្សាទទួលបានសេវាការពារមានគុណភាពពីសំណាក់អ្នកផ្តល់សេវា និងស្ថាប័ន កុមារមេត្រីដែលទទួលបានការបណ្តុះបណ្តាលអំពីកិច្ចការពារកុមារ។

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ៨.១- កុមារដែលមានទំនាក់ទំនងជាមួយច្បាប់ ទទួលបានសេវាការពារដែលមានប្រសិទ្ធភាពមានការកើនឡើង | សូចនាករ៨.១ក៖ ចំនួននិងប្រភេទអន្តរាគមន៍ដែលការពារកុមារ គាំទ្រដោយ អង្គការ សង្គមស៊ីវិល (CSOs) | ៨.១.១- គាំទ្រ និង សហការជាមួយអង្គការសង្គមស៊ីវិល បង្កើតយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់កៀរគរធនធានដើម្បីផ្តល់សេវាការពារកុមារ រួមមានការកំណត់អត្តសញ្ញាណកុមារា និងកុមារីដែលប្រឈមនឹងអំពើហិង្សា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | X | | | | ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី |
| ៨.២-សមត្ថភាព អ្នកផ្តល់សេវាគាំពារកុមារ និងអ្នកពាក់ព័ន្ធ ត្រូវបានពង្រឹង ដើម្បីឆ្លើយតបនឹងករណីអំពើហិង្សាលើកុមារ | សូចនាករ៨.២ក៖ វគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋានអំពីកិច្ចការពារកុមារបានបង្កើតសម្រាប់អ្នកផ្តល់សេវា | ៨.២.១- បង្កើតកម្រងមេរៀនអំពីកិច្ចការពារកុមារកម្រិតមូលដ្ឋាន សម្រាប់អ្នកផ្តល់សេវាគាំពារកុមារ និងអ្នកពាក់ព័ន្ធ រួមមាន ជំនាញសម្រាប់កំណត់អត្តសញ្ញាណកុមារា និង កុមារីប្រឈមនឹង អំពើហិង្សា និង អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត។ | ក្រសួងសង្គម កិច្ច អតីត យុទ្ធជន និង យុវនីតិសម្បទា | | X | X | | | ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ អង្គការដៃគូ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ៨.២ខ៖ ចំនួនគ្រូបង្គោល ទទួលបានការបំពាក់បំប៉ន ដើម្បីបណ្តុះបណ្តាលបន្តអំពីកម្រងមេរៀនកម្រិតមូលដ្ឋានស្តីពីកិច្ចការពារកុមារ | ៨.២.២- ជ្រើសរើសគ្រូបង្គោល មានសមត្ថភាព ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលអំពីកិច្ចការពារកុមារ ដល់អ្នកផ្តល់សេវាសង្គម និងអ្នកពាក់ព័ន្ធនានា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | X | | | | ក្រសួងមហាផ្ទៃ<br>ក្រសួងយុត្តិធម៌<br>ក្រសួងសុខាភិបាល |
| | សូចនាករ ៨.២គ៖ កម្មវិធីសិក្សាអំពីកិច្ចការពារកុមារកម្រិតមូលដ្ឋានសម្រាប់បណ្តុះបណ្តាលគ្រូបង្គោល បានបង្កើត | ៨.២.៣- រៀបចំកម្មវិធីសិក្សា អំពីទ្រឹស្តី និងការអនុវត្តកិច្ចការពារកុមារ ដែលមានការទទួលស្គាល់ សម្រាប់បណ្តុះបណ្តាលដល់គ្រូបង្គោល | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | X | X | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ៨.២ឃ៖ ភាគរយនៃអ្នកផ្តល់សេវាគាំពារកុមារបានទទួលការបណ្តុះបណ្តាលអំពីកិច្ច ការពារកុមារកម្រិតមូលដ្ឋាន | ៨.២.៤- បណ្តុះបណ្តាល អំពីទ្រឹស្តី និងការអនុវត្តកិច្ចការពារកុមារ ដល់អ្នកផ្តល់សេវាគាំពារកុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| ៨.៣- ប្រព័ន្ធកិច្ចការពារកុមារ មានសេវាបញ្ជូននិងគាំទ្រសម្រាប់ កុមារដែលជាជនរងគ្រោះដោយអំពើហិង្សា | សូចនាករ ៨.៣ក៖ បង្កើតយន្តការបញ្ជូននៅថ្នាក់កណ្តាលដើម្បីសម្របសម្រួលសេវាសង្គម និង សេវាសុខភាពផ្លូវចិត្ត | ៨.៣.១- បង្កើតយន្តការបញ្ជូនមួយ នៅថ្នាក់កណ្តាល ដើម្បីសម្របសម្រួលសេវាសុខភាពសង្គម និងសុខភាពផ្លូវចិត្ត សម្រាប់កុមារដែលត្រូវការកិច្ច ការពារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | X | X | X | | | ក្រសួងសុខាភិបាល |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ ៨.៣ខ៖ ចំនួនស្រុកដែលមានប្រព័ន្ធ កិច្ចការពារកុមារ ផ្សារភ្ជាប់នឹងទូរស័ព្ទទាន់ហេតុការណ៍ | ៨.៣.២- បង្កើតអង្គភាពសម្របសម្រួលទូរស័ព្ទទាន់ហេតុការណ៍ដែលទទួលបន្ទុកដោយក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បី៖<br>(ក) ធានាថាទូរស័ព្ទទាន់ហេតុការណ៍ និងគេហទំព័រដែលផ្តល់សេវាឆ្លើយតបចំពោះអំពើហិង្សាលើកុមារ អាចប្រើប្រាស់បានពីសំណាក់កុមារទាំងអស់ក្នុងប្រទេស<br>(ខ) តាមដានករណីអំពើហិង្សា ដែលបានបញ្ជូនតាមទូរស័ព្ទទាន់ហេតុការណ៍<br>(គ) ប្រមូលទិន្នន័យនិងរបាយការណ៍ស្តីពីអំពើហិង្សាលើកុមារពីទូរស័ព្ទទាន់ហេតុការណ៍<br>(ឃ) គាំទ្រផ្នែកហិរញ្ញវត្ថុដោយនិរន្តរភាព សម្រាប់ដំណើរការទូរស័ព្ទទាន់ហេតុការណ៍ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | X | X | X | ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | សូចនាករ ៨.៣គ៖ បង្កើតយន្តការសម្រាប់កំណត់អត្តសញ្ញាណ និងរាយការណ៍តាមប្រព័ន្ធទូរស័ព្ទ និងតាមប្រព័ន្ធអ៊ីនធឺណិតទាន់ហេតុការណ៍ ដើម្បីលុបកម្មវិធី និងសម្ភារៈដែលគាំទ្រអំពើកេងប្រវ័ញ្ចកុមារក្នុងអ៊ីនធឺណិតដូចជា រូបភាព អាសអាភាសកុមារ និងគេហទំព័រដែលជំរុញការលួងលោមនិងជ្រើសរើសកុមារក្នុងបំណងកេងប្រវ័ញ្ចផ្លូវភេទ | ៨.៣.៣- បង្កើត និងសម្រប សម្រួលយន្តការអន្តរាគមន៍ទាន់ហេតុការណ៍ចល័ត តាមប្រព័ន្ធអ៊ីនធឺណិត និងទូរស័ព្ទ សម្រាប់កំណត់អត្តសញ្ញាណ និងរាយការណ៍ករណី កេងប្រវ័ញ្ចផ្លូវភេទកុមារ រួមមាន រូបភាពនិងសម្ភារៈអាសអាភាសកុមារ ការលួងលោម និង ជ្រើសរើស កុមារសម្រាប់ការកេងប្រវ័ញ្ចផ្លូវភេទ ក្នុងប្រព័ន្ធអ៊ីនធឺណិត និងដើម្បីដកសម្ភារៈទាំងនោះចេញ | ក្រសួងព័ត៌មាន | X | X | X | | | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងមហាផ្ទៃ |
| | សូចនាករ ៨.៣ឃ៖ អង្គភាពសម្រាប់ទទួលស្គាល់គុណភាពអ្នកផ្តល់សេវាប្រព័ន្ធទូរស័ព្ទ និងអ៊ីនធឺណិតទាន់ហេតុការណ៍ត្រូវបានបង្កើត | ៨.៣.៤- បង្កើតប្រព័ន្ធទទួលស្គាល់គុណភាពអ្នកផ្តល់សេវា ទាន់ហេតុការណ៍ រួមមានសេចក្តីត្រូវការឱ្យមានការបណ្តុះបណ្តាលជាអប្បបរមាសម្រាប់បុគ្គលិកជាអ្នកផ្តល់សេវាទាន់ហេតុការណ៍ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ ៨.៣ង៖ ភាគរយនៃអ្នកផ្តល់សេវាទូរស័ព្ទ និងអ៊ីនធឺណិតទាន់ហេតុការណ៍ទទួលបានការបណ្តុះបណ្តាល ជាអប្បបរមា តាមសេចក្តីត្រូវការ ដើម្បីផ្តល់សេវាទាន់ហេតុការណ៍ចំពោះករណីកិច្ចការពារកុមារ | ៨.៣.៥- បង្កើត និង ផ្តល់ការបណ្តុះបណ្តាលសម្រាប់បុគ្គលិកជាអ្នកផ្តល់សេវាទាន់ហេតុការណ៍ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| ៨.៤- ប្រព័ន្ធសេវាសង្គមដែលបង្កើតនីតិវិធី ឬបទដ្ឋាន ពិធីសារប្រតិបត្តិ សម្រាប់ចាត់ការ របាយការណ៍ និង ករណីអំពើហិង្សាលើកុមារ | សូចនាករ៨.៤ក៖ ភាគរយនៃករណី និង របាយការណ៍ស្តីពីអំពើហិង្សាលើកុមារបានដោះស្រាយតាមនីតិវិធី ឬ បទដ្ឋានពិធីសារប្រតិបត្តិ និង មានលក្ខណៈកុមារមេត្រី មានការកើនឡើង | ៨.៤.១- បង្កើតនីតិវិធី ឬ បទដ្ឋានពិធីសារប្រតិបត្តិការដែលមានលក្ខណៈកុមារមេត្រី សម្រាប់ដោះស្រាយករណី និង រាយការណ៍ករណីអំពើហិង្សាលើកុមារ សម្រាប់ស្ថាប័នសេវាសង្គម និងអ្នកផ្តល់សេវាសង្គម រួមមាន៖<br>(ក) ការបញ្ជូនទៅមន្ត្រី គាំពារ កុមារ/នគរបាល និង យន្តការ ឆ្លើយតប<br>(ខ) តាមដាន និងគាំទ្រ<br>(គ) ចងក្រងជាឯកសារ និង តាមដានករណីដែលបានរាយការណ៍ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | X | | | | ក្រសួងយុត្តិធម៌ |
| | សូចនាករ៨.៤ខ៖ ភាគរយនៃស្ថាប័នសេវាសង្គម (នាយកដ្ឋានសេវាសង្គម អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គភាពឆ្លើយតប ។ល។) ដែលបានបញ្ចូលនីតិវិធី ឬ បទដ្ឋានពិធីសារប្រតិបត្តិ និងមានលក្ខណៈកុមារមេត្រី ទៅក្នុងគោលនយោបាយផ្ទៃក្នុងរបស់អង្គភាព | ៨.៤.២- ពង្រឹងសមត្ថភាព ដល់អង្គភាពសេវាសង្គម ដើម្បីអនុវត្ត នីតិវិធី ឬ បទដ្ឋានពិធីសារប្រតិបត្តិ និង មានលក្ខណៈកុមារមេត្រី សម្រាប់ដោះស្រាយ និង រាយការណ៍ករណីអំពើហិង្សាលើកុមារ ដោយយកចិត្តទុកដាក់ជា ពិសេសលើកុមារពិការ និងកុមារា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |

## ផ្នែករងទី៤៖ សេវាសុខាភិបាល

| **លទ្ធផលទី៩៖** កុមារី និងកុមារទទួលបានកិច្ចការពារបន្ថែមពីប្រព័ន្ធសុខាភិបាល និងបុគ្គលិកសុខាភិបាល តាមរយៈក្របខ័ណ្ឌច្បាប់ និងស្ថាប័ន | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **សូចនាករលទ្ធផលទី៩ក៖** ចំនួនកុមារី និងកុមារដែលរួចផុតពីអំពើហិង្សា ទទួលបានសេវាសុខាភិបាលមានគុណភាព | | | | | | | | | |
| **លទ្ធផលបឋម** | **សូចនាករ** | **សកម្មភាព** | **ស្ថាប័នទទួលខុសត្រូវ** | **តារាងពេលវេលា(ឆ្នាំ)** | | | | | **ស្ថាប័នគាំទ្រ** |
| | | | | **១** | **២** | **៣** | **៤** | **៥** | |
| ៩.១- ពង្រឹងសមត្ថភាពរបស់ប្រព័ន្ធសុខាភិបាល និងមន្ត្រីវិជ្ជាជីវៈ ផ្នែកសុខាភិបាលក្នុងការកំណត់រក និងឆ្លើយតប ករណីកុមារដែលរងនូវអំពើហិង្សាគ្រប់ទម្រង់ | សូចនាករ ៩.១ក៖ ភាគរយនៃមណ្ឌលសុខភាពដែលមានអ្នកផ្តល់សេវាយ៉ាងហោចណាស់ ១នាក់ បានទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី និងកុមារ ផ្អែកលើគោលការណ៍ណែនាំ និងពិធីសារថ្នាក់ជាតិ | ៩.១.១-. ផ្សព្វផ្សាយ និងអនុវត្ត "គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រី និងកុមារ" នៅមន្ទីរពេទ្យ បង្អែក និងមណ្ឌលសុខភាព | ក្រសួងសុខាភិបាល | X | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៩.១ខ៖ ភាគរយ និង ចំនួនមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនឹងអនុវត្ត "សៀវភៅគ្លីនិក ស្តីពី ការថែទាំសុខភាពសម្រាប់កុមារដែលរងអំពីហិង្សា ឬ ការរំលោភបំពានផ្លូវភេទ" | ៩.១.២- បង្កើត និងផ្តល់វគ្គបណ្តុះបណ្តាលដល់ស្ថាប័នសុខាភិបាល និងបុគ្គលិកសុខាភិបាល អំពី "សៀវភៅស្តីពីការថែទាំសុខភាពកុមាររងគ្រោះដោយសារអំពើហិង្សា ឬអំពើរំលោភបំពានផ្លូវភេទនៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព" | ក្រសួងសុខាភិបាល | X | X | X | X | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៩.១គ៖ ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារសម្រាប់មន្ត្រីវិជ្ជាជីវៈផ្នែកសុខាភិបាលបានបង្កើត | ៩.១.៣- បង្កើតក្រមសីលធម៌វិជ្ជា ជីវៈស្តីពីកិច្ចការពារកុមារសម្រាប់មន្ត្រីវិជ្ជាជីវៈសុខាភិបាល | ក្រសួងសុខាភិបាល | X | X | | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៩.១ឃ៖ ភាគរយនៃមន្ត្រីវិជ្ជាជីវៈសុខាភិបាលទទួលបានការបណ្តុះបណ្តាលស្តីពីក្រមសីលធម៌វិជ្ជាជីវៈក្នុងកិច្ចការពារកុមារ | ៩.១.៤- បង្កើតកម្រងមេរៀន ស្តីពីក្រមសីលធម៌វិជ្ជាជីវៈ ក្នុងកិច្ចការពារកុមារ និងបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាល សម្រាប់មន្ត្រីវិជ្ជាជីវៈសុខាភិបាលទាំងមុនពេលចេញបម្រើការងារ និងអ្នកដែលកំពុងបម្រើការងារ | ក្រសួងសុខាភិបាល | | X | X | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៩.១ង៖ ភាគរយនៃមន្ត្រីវិជ្ជាជីវៈសុខាភិបាលទទួលបានការបណ្តុះបណ្តាលស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត | ៩.១.៥- បង្កើតកម្មវិធីបណ្តុះ បណ្តាលស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងបញ្ចូលកម្មវិធីទាំងនេះក្នុងកម្រងមេរៀនសម្រាប់មន្ត្រីវិជ្ជាជីវៈសុខាភិបាល | ក្រសួងសុខាភិបាល | | X | X | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ ៩.១ច៖ ចំនួនកោសលវិច័យសម្រាប់កុមាររងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទបានផ្តល់ដោយឥតគិតកម្រៃ | ៩.១.៦- ពង្រឹងការអនុវត្តមូលនិធិសន្តិសុខសង្គម សម្រាប់សេវាសុខភាព រួមមានការធ្វើកោសលវិច័យដោយឥតគិតថ្លៃសម្រាប់កុមារ ដែលជាជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ | ក្រសួងសុខាភិបាល | | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |

**លទ្ធផលទី១០៖** កិច្ចការពារកុមារី និងកុមារនៅតាមសាលារៀនមានការកើនឡើង តាមរយៈក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

**សូចនាករលទ្ធផលទី ១០ក៖** ចំនួនកុមារី និងកុមារដែលទទួលបានសេវាកិច្ចគាំពារកុមារនៅតាមសាលារៀន

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១០.១- ពង្រឹងសមត្ថភាពរបស់ស្ថាប័នអប់រំ និងបុគ្គលិកអប់រំ ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ ការកំណត់អត្តសញ្ញាណ និងឆ្លើយតបករណីកុមាររងាយរងគ្រោះនិងបានរងគ្រោះដោយអំពើហិង្សា | សូចនាករ១០ក៖ ភាគរយនិងចំនួនសាលាបឋមសិក្សា និងមធ្យមសិក្សា ដែលមានមន្ត្រីផ្នែកកិច្ចការពារកុមារ | ១០.១.១- រៀបចំប្រកាសដែលតម្រូវឱ្យមានការតែងតាំងមន្ត្រី ផ្នែកកិច្ចការពារកុមារនៅកម្រិតសាលាបឋម និងអនុវិទ្យាល័យ ជាផ្នែកមួយនៃការអនុវត្តក្របខ័ណ្ឌ សាលាកុមារមេត្រី | ក្រសួងអប់រំ យុវជន និងកីឡា | X | X | | | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១០ខ៖ ភារកិច្ចរបស់ក្រុមប្រឹក្សាកុមារត្រូវបានពិនិត្យនិងកែសម្រួលដើម្បីដាក់បញ្ចូលការទទួលខុសត្រូវអំពីកិច្ចការពារកុមារ | ១០.១.២- កែសម្រួលតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់គ្រូបង្រៀនចំនួនពីរនាក់ ដែលមានទំនាក់ទំនងជាមួយក្រុមប្រឹក្សាសិស្ស និងចាត់តាំងពួកគេជាមន្ត្រីទទួលបន្ទុកផ្នែកកិច្ចការពារកុមារ | ក្រសួងអប់រំ យុវជន និងកីឡា | | X | X | X | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១០គ៖ ភាគរយនៃក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក និង ខ័ណ្ឌ (DTMTs) មានសមាជិកដែលត្រូវបានចាត់តាំងយ៉ាងហោចណាស់ ១នាក់ បានទទួលការបណ្តុះបណ្តាលអំពីកិច្ចការពារកុមារកម្រិតមូលដ្ឋាន | ១០.១.៣- តែងតាំង និង បណ្តុះបណ្តាលមន្ត្រីជាគ្រូឧទ្ទេសផ្នែកកិច្ចការពារកុមារយ៉ាងហោចណាស់ ១នាក់ក្នុងចំណោមក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក ក្រុង និងខ័ណ្ឌ (DTMT) ដើម្បីផ្តល់ការគាំទ្រដល់មន្ត្រីផ្នែកកិច្ចការពារកុមារនៅតាមសាលារៀនទាំងកម្រិតបឋម និងអនុវិទ្យាល័យ | ក្រសួងអប់រំ យុវជន និងកីឡា | | X | X | X | | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |

**យុទ្ធសាស្ត្រទី ៤៖ ការបង្កើត និងការធ្វើវិសោធនកម្មច្បាប់ និងគោលនយោបាយ**

**គោលបំណងទូទៅ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារ តាមរយៈការពង្រឹងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយក្នុងការទប់ស្កាត់ និងការពារកុមារពី អំពើហិង្សាគ្រប់ទម្រង់ អំពើរំលោភបំពាន និង មិនយកចិត្តទុកដាក់

**ផ្នែករងទី១៖ ការដាក់ទណ្ឌកម្មលើរាងកាយ និងកិច្ចការពារកុមារពីអំពើហិង្សាក្នុងគ្រួសារ**

**លទ្ធផលទី ១១ ៖** ក្របខ័ណ្ឌច្បាប់ គោលនយោបាយ និង បទដ្ឋានគតិយុត្តនានាក្នុងការគាំពារកុមារពីការទទួលរងទណ្ឌកម្មលើរាងកាយ និងអំពើហិង្សាក្នុងគ្រួសារ ត្រូវអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

**សូចនាករលទ្ធផលទី ១១ក ៖** ច្បាប់ជាតិត្រូវបានធ្វើវិសោធនកម្ម ដើម្បីលុបបំបាត់ការដាក់ទណ្ឌកម្មលើរាងកាយកុមារក្នុងគ្រប់បរិបទទាំងអស់
**សូចនាករលទ្ធផលទី ១១ខ ៖** ច្បាប់ជាតិត្រូវបានធ្វើវិសោធនកម្ម ដើម្បីបញ្ចូលទោសទណ្ឌចំពោះការប្រើប្រាស់អំពើហិង្សា ឬការដាក់ទណ្ឌកម្ម លើរាងកាយ នៅក្នុងសាលារៀន

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១១.១ រាល់បទបញ្ញតិពាក់ព័ន្ធនឹងការប្រើទណ្ឌកម្មលើរាងកាយកុមារត្រូវបានធ្វើវិសោធនកម្ម | សូចនាករ១១.១ក៖ វិសោធនកម្មក្រមរដ្ឋប្បវេណីហាមឃាត់ការប្រើទណ្ឌកម្មលើរាងកាយកុមារនៅក្នុងគ្រប់បរិបទទាំងអស់ | ១១.១.១- ស្វែងរកការគាំទ្រមតិដើម្បីធ្វើបរិសោធនកម្ម មាត្រា១០៤៥ និង មាត្រា១០៧៩ ក្នុងក្រមរដ្ឋប្បវេណី ដែលពាក់ព័ន្ធ នឹងការដាក់ទណ្ឌកម្មលើរាងកាយកុមារថាជាអំពើខុសច្បាប់ | ក្រសួងយុត្តិធម៌ | X | X | X | | | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>ក្រសួង និងស្ថាប័នពាក់ព័ន្ធ<br>ក្រសួងកិច្ចការនារី<br>NGOs |
| | សូចនាករ ១១.១ខ៖ ភាគរយនៃករណីនៃការប្រើទណ្ឌកម្មលើរាងកាយនៅក្នុងបរិបទអប់រំសិក្សាត្រូវបានកំណត់រកឃើញជាមួយនឹងផលប៉ះពាល់ | ១១.១.២- ពង្រឹងប្រសិទ្ធភាពនៃ ការអនុវត្តក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ច្បាប់អប់រំ និង ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ដោយផ្តោតលើការអប់រំដល់មន្ត្រីរាជការជាពិសេសគ្រូបង្រៀន រួមទាំងជនបង្គោលក្នុងស្ថាប័ននីមួយៗ ដែលពាក់ព័ន្ធនឹងច្បាប់ ចំពោះការដាក់ទណ្ឌកម្មលើរាងកាយក្នុងសាលារៀន | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ | X | X | X | | | ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ១១.១គ៖ ចំនួនករណីនៃការប្រើទណ្ឌកម្មលើរាងកាយកុមារដាក់ដោយបុគ្គលិកអប់រំ ទទួលការដាក់ពិន័យ | ១១.១.៣- បន្ថែមមាត្រាថ្មីក្នុងច្បាប់អប់រំ ឬ ក្នុងគោលនយោបាយស្តីពីកិច្ចការពារកុមារ ក្នុងគ្រឹះស្ថានអប់រំ ដោយបញ្ចូលការដាក់ពិន័យលើបុគ្គលិកអប់រំ ចំពោះការប្រើទណ្ឌកម្មលើរាងកាយកុមារ | ក្រសួងអប់រំ យុវជន និងកីឡា | X | X | X | | | ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១១.១ឃ៖ គោលនយោបាយកិច្ចការពារកុមារក្នុងគ្រឹះស្ថានអប់រំសិក្សាត្រូវបានអនុម័ត | ១១.១.៤. ជំរុញការអនុម័ត និង អនុវត្តគោលនយោបាយកិច្ចការពារកុមារក្នុងសាលារៀន | ក្រសួងអប់រំ យុវជន និងកីឡា | | X | X | X | X | ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |
| ១១.២- មន្រ្តីនីតិកម្ម ចាត់ទុក អំពើហិង្សាក្នុងគ្រួសារលើកុមារ ថាជាទង្វើខុសច្បាប់ នៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ | សូចនាករ១១.២ក៖ វិសោធនកម្ម កថាខណ្ឌ ២ក្នុងមាត្រា ៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ | ១១.២.១- ធ្វើវិសោធនកម្ម កថាខណ្ឌ ២ ក្នុងមាត្រា ៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។ | ក្រសួងកិច្ចការនារី | X | X | X | | | ក្រសួងមហាផ្ទៃ<br>ក្រសួងយុត្តិធម៌ |
| | សូចនាករ១១.២ខ៖ វិសោធនកម្ម មាត្រា ២ នៃច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ | ១១.២.២- ធ្វើវិសោធនកម្មមាត្រា ២ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងមាត្រាមួយចំនួនទៀតនៅក្នុងច្បាប់ | ក្រសួងកិច្ចការនារី | X | X | | | | ក្រសួងមហាផ្ទៃ<br>ក្រសួងយុត្តិធម៌ |
| | សូចនាករ១១.២គ៖ អនុក្រិត្យស្តីពីសេចក្តីសម្រេចរដ្ឋបាលរបស់អាជ្ញាធរមូលដ្ឋានចំពោះករណីអំពើហិង្សាក្នុងគ្រួសារបានដាក់ចេញ និងប្រកាសផ្សព្វផ្សាយ | ១១.២.៣- ពិនិត្យឡើងវិញ និង អនុម័តអនុក្រិត្យដែលផ្តល់អំណាច ដល់អាជ្ញាធរមូលដ្ឋានដើម្បីដាក់ចេញសេចក្តីសម្រេចរដ្ឋបាលចំពោះករណីអំពើហិង្សាក្នុងគ្រួសារ | ក្រសួងមហាផ្ទៃ | | X | X | | | ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |

## ផ្នែករងទី២៖ អំពើហិង្សាផ្លូវភេទលើកុមារ

**លទ្ធផលទី១២៖** កុមារី និង កុមារា ទទួលបានការការពារពីអំពើហិង្សាផ្លូវភេទតាមរយៈក្របខ័ណ្ឌគតិយុត្តិដែលអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

**សូចនាករលទ្ធផលទី១២ក៖** វិសោធនកម្មច្បាប់ ឬអនុម័តច្បាប់ថ្មី ស្តីពីកិច្ចការពារកុមារពីអំពើហិង្សាផ្លូវភេទ ឱ្យស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១២.១- ចំណុចខ្វះចន្លោះក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិដែលទាក់ទងនឹងកិច្ចការពារកុមារពីអំពើហិង្សាដែលអនុលោម តាមបដ្ឋានអន្តរជាតិ បានពិនិត្យ និងកែសម្រួល | សូចនាករ១២.១ក៖ អនុក្រឹត្យ និង ក្រមសីលធម៌ស្តីពីកិច្ចការពារកុមារ ដែលបានបញ្ចូលអភិក្រមកុមារមេត្រី បានអនុវត្ត | ១២.១.១- ពិនិត្យឡើងវិញលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីកិច្ច ការពារកុមារ និងក្រមសីលធម៌វិជ្ជាជីវៈ កិច្ចការពារកុមារ និងធានាថាអភិក្រមទាំងនេះមានលក្ខណៈកុមារមេត្រី | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | | X | X | | | ស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១២.១ខ៖ វិសោធនកម្មមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌដើម្បីដំឡើងអាយុ នៃការរួមភេទ ដល់ ១៨ឆ្នាំ សម្រាប់អំពើរួមភេទជាមួយនឹងគូភាគី ដែលមានអាយុច្រើនជាងកុមារ៥ឆ្នាំ | ១២.១.២- ធ្វើវិសោធនកម្មមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ដោយកំណត់នីតិភាពនៃការរួមភេទដល់អាយុ ១៨ឆ្នាំ ចំពោះគម្លាត អាយុរវាងដៃគូរួមភេទច្រើនជាង៥ឆ្នាំ | ក្រសួងយុត្តិធម៌ | | X | X | | | ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី |
| | សូចនាករ១២.១គ៖ មាត្រាមួយថ្មីបានបន្ថែម ទៅក្នុងក្រមព្រហ្មទណ្ឌដែលផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌអំពើហិង្សាផ្លូវភេទមិនប៉ះពាល់ រាងកាយ និងការលួងលោមតាមប្រព័ន្ធអ៊ីនធឺណិត (Grooming) ដើម្បីកេងចំណេញផ្លូវភេទ | ១២.១.៣- បន្ថែមមាត្រាថ្មីមួយក្នុងក្រមព្រហ្មទណ្ឌ ដើម្បីធានាថាការប្រព្រឹត្តិអំពើហិង្សាផ្លូវភេទដែលមិនប៉ះពាល់រាងកាយ និងការលួងលោមតាមប្រព័ន្ធអ៊ីនធឺណិត (Grooming) ដើម្បីកេងចំណេញផ្លូវភេទត្រូវមានទោសព្រហ្មទណ្ឌ | ក្រសួងយុត្តិធម៌ | | X | X | | | ក្រសួងកិច្ចការនារី |
| | សូចនាករ១២.១ឃ៖ មាត្រាមួយថ្មីបានបន្ថែមទៅក្នុងក្រមព្រហ្មទណ្ឌ ដែលបញ្ជាក់ច្បាស់លាស់ និងផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌអំពើស្មន្ទការ | ១២.១.៤- បញ្ចូលមាត្រាមួយថ្មី ក្នុងក្រមព្រហ្មទណ្ឌ អំពីស្មន្ទការ (ការរួមភេទ សកម្មភាពផ្លូវភេទ និងការរំលោភសេពសន្ថវៈ រវាងសាច់ញាតិជិត) ជាបទល្មើសជាក់លាក់ | ក្រសួងយុត្តិធម៌ | | X | X | | | ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ១២.១ង៖ មាត្រា៤០ នៃច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ បានធ្វើវិសោធនកម្មដើម្បីពង្រីកនិយមន័យរូបភាព និងសម្ភារៈ អាសអាភាសកុមារឱ្យស្រប នឹងពិធីសារបន្ថែមស្តីពីអំពើលក់កុមារពេស្យាចារកុមារ រូបភាព និងសម្ភារៈអាសអាភាសកុមាររបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ | ១២.១.៥- ធ្វើវិសោធនកម្ម មាត្រា៤០ នៃច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទដើម្បីបញ្ចូលនិយមន័យរូបភាព និងសម្ភារៈអាសអាភាសកុមារ ដោយអនុលោមតាមពិធីសារ បន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការលក់កុមារ ពេស្យាកម្ម កុមារនិងកាមសាស្ត្រកុមារ | ក្រសួងយុត្តិធម៌ | | X | X | | | ក្រសួងមហាផ្ទៃ |
| | សូចនាករ១២.១ច៖ វិសោធនកម្មមាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដើម្បីផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ រាល់អំពើកាន់កាប់រូបភាព និង សម្ភារៈអាសអាភាសកុមារ ក្នុងគ្រប់បរិបទទាំងអស់ | ១២.២.៦- ធ្វើវិសោធនកម្មមាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបការ ជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដើម្បីចាត់ទុកអំពើកាន់កាប់សម្ភារៈអាសអាភាស កុមារទោះបីជាក្នុងរូបភាពណាក៏ដោយជាបទល្មើសព្រហ្មទណ្ឌ | ក្រសួងយុត្តិធម៌ | | X | X | | | ក្រសួងមហាផ្ទៃ |
| | សូចនាករ ១២.១ធ៖ បន្ថែមមាត្រាមួយថ្មីទៅក្នុងសេចក្តីព្រាងច្បាប់ពីបទល្មើសបច្ចេកវិទ្យាដើម្បីជានាការការពារកុមារជាជនរងគ្រោះនៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត រួមមាន ការគំរាមឬការជំរិតផ្លូវភេទ អំពើចែកចាយសារ ឬរូបភាពពាក់ព័ន្ធនឹងផ្លូវភេទ (ស៊ិចធីង) ការបង្ហាញផ្ទាល់លើអ៊ីនធឺណិតនូវអំពើរំលោភបំពានផ្លូវភេទកុមារ និងអំពើលួងលោមកុមារ | ១២.១.៧- បន្ថែមមាត្រាថ្មីក្នុងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ដើម្បីជានាកិច្ចការពារកុមារជាជនរងគ្រោះនៃអំពើកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធព័ត៌មានសង្គម រួមមានការគំរាម ឬ ការជំរិតផ្លូវភេទ ការចែកចាយ សារ ឬ រូបភាពដែលពាក់ព័ន្ធនឹងផ្លូវភេទកុមារ ការបង្ហាញ ផ្ទាល់តាមរយៈប្រព័ន្ធព័ត៌មាន សង្គម អំពីការរំលោភបំពានផ្លូវភេទកុមារ និងការលួងលោម ដើម្បីកេងប្រវ័ញ្ចផ្លូវភេទកុមារ | ក្រសួងយុត្តិធម៌ | | X | X | X | | ក្រសួងមហាផ្ទៃ |
| | សូចនាករ១២.១ជ៖ បន្ថែមមាត្រាមួយថ្មីទៅក្នុងសេចក្តីព្រាងច្បាប់ពីបទល្មើសបច្ចេកវិទ្យា ដែលផ្តល់អំណាចដល់មន្ត្រីអនុវត្តច្បាប់ធ្វើការស៊ើបអង្កេត រឹបអូសសម្ភារៈ និងប្លុកកម្មវិធីទាំងឡាយក្នុងប្រព័ន្ធអ៊ីនធឺណិតដែលចូលរួម លើកកម្ពស់ ឬសម្រប សម្រួលដល់អំពើរំលោភបំពានផ្លូវភេទនិងកេងប្រវ័ញ្ចផ្លូវភេទកុមារ | ១២.១.៨- បន្ថែមមាត្រាថ្មីក្នុងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា ដើម្បីផ្តល់អំណាចដល់មន្ត្រីអនុវត្តច្បាប់ ក្នុងការស៊ើបអង្កេត រឹបអូសឧបករណ៍ និងបិទកម្មវិធីក្នុងប្រព័ន្ធព័ត៌មានសង្គមដែលចូលរួមលើកកម្ពស់ ឬ សម្របសម្រួល អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ កុមារតាមប្រព័ន្ធអ៊ីនធឺណិត | ក្រសួងយុត្តិធម៌ | | X | X | X | | ក្រសួងមហាផ្ទៃ |
| | សូចនាករ១២.១ឈ៖ វិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍ដើម្បីបញ្ចូលពិធីសារស្តីពីកិច្ចការពារកុមារសម្រាប់កម្មវិធីអនឡាញ និងកម្មវិធីក្នុងប្រព័ន្ធទូរស័ព្ទចល័ត | ១២.១.៩- ពិនិត្យឡើងវិញច្បាប់ស្តីពីទូរគមនាគមន៍ ដើម្បីពង្រឹងប្រព័ន្ធបច្ចេកវិទ្យា និងទំនាក់ទំនងសម្រាប់ការពារកុមារតាមរយៈប្រព័ន្ធអ៊ីនធឺណិត | ក្រសួងយុត្តិធម៌ | | X | X | X | | ក្រសួង និង ស្ថាប័នពាក់ព័ន្ធ |

## ផ្នែករងទី៣៖ ការធ្វេសប្រហែសមិនយកចិត្តទុកដាក់ចំពោះកុមារ

**លទ្ធផលទី ១៣** ៖ កុមារី និងកុមារា ទទួលបានការការពារចំពោះការមិនអើពើយកចិត្តទុកដាក់គ្រប់រូបភាព តាមរយៈក្របខ័ណ្ឌច្បាប់ដែលអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

**សូចនាករលទ្ធផលទី ១៣ក** ៖ វិសោធនកម្មច្បាប់ និងអនុម័តច្បាប់ថ្មីដើម្បីឱ្យក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការមិនអើពើលើកុមារគ្រប់ទម្រង់ទាំងអស់រួមមានការមិនអើពើលើតម្រូវការផ្លូវកាយ និងផ្លូវចិត្ត ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលសុខត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១៣.១-មាត្រា ៣៣៧ និងមាត្រា៣២១ នៃក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងការមិនអើពើចំពោះតម្រូវការផ្នែករូបរាងកាយ ផ្នែកសុខភាព ការបោះបង់កុមារអាយុក្រោម១៨ឆ្នាំ បានធ្វើវិសោធនកម្ម | សូចនាករ១៣.១ក៖ វិសោធនកម្មមាត្រា ៣៣៧ ក្នុងក្រមព្រហ្មទណ្ឌ ដោយផ្តន្ទាទោស ការមិនអើពើ ចំពោះតម្រូវ ការផ្នែករូបរាងកាយកុមារអាយុក្រោម១៨ឆ្នាំ ជាបទល្មើសព្រហ្មទណ្ឌ | ១៣.១.១-ស្វែងរកការគាំទ្រមតិ ធ្វើវិសោធនកម្មមាត្រា ៣២១ និង មាត្រា ៣៣៧ ក្នុងក្រមព្រហ្មទណ្ឌ ដើម្បីអនុម័តការមិនអើពើចំពោះ តម្រូវការផ្នែករូបរាងកាយកុមារអាយុក្រោម ១៨ឆ្នាំ ជាបទល្មើសព្រហ្មទណ្ឌ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | X | X | | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ |
| | សូចនាករ១៣.១ខ៖ វិសោធនកម្មមាត្រា ៣៣៧ ក្នុងក្រមព្រហ្មទណ្ឌ ដោយផ្តន្ទាទោស ការមិនអើពើចំពោះតម្រូវការផ្នែកសុខភាពកុមារអាយុក្រោម១៨ឆ្នាំ ជាបទល្មើសព្រហ្មទណ្ឌ | ១៣.១.២- ស្វែងរកការគាំទ្រមតិ ធ្វើវិសោធនកម្មមាត្រា ៣៣៧ នៃក្រមព្រហ្មទណ្ឌ ដើម្បីអនុម័ត ការមិនអើពើចំពោះតម្រូវការផ្នែកសុខភាពរបស់កុមារអាយុក្រោម១៨ឆ្នាំ ក្លាយជាបទល្មើសព្រហ្មទណ្ឌ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | X | X | X | X | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ |
| | សូចនាករ១៣.១គ៖ វិសោធនកម្មមាត្រា៣២១ ក្នុងក្រមព្រហ្មទណ្ឌដោយផ្តន្ទាទោសអំពើបោះបង់កុមារអាយុក្រោម១៨ឆ្នាំជាបទល្មើសព្រហ្មទណ្ឌ | ១៣.១.៣- ស្វែងរកការគាំទ្រមតិ ធ្វើវិសោធនកម្មមាត្រា ៣២១ នៃក្រមព្រហ្មទណ្ឌ ដើម្បីអនុម័តអំពើបោះបង់កុមារជាបទល្មើសព្រហ្មទណ្ឌ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | X | X | X | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង យុត្តិធម៌ |
| ១៣.២- មាត្រាថ្មីនៃក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងការមិនយកចិត្តទុកដាក់ចំពោះផ្លូវចិត្តកុមារអាយុក្រោម ១៨ បានបញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌ | សូចនាករ១៣.២ក៖ ក្រមព្រហ្មទណ្ឌផ្តន្ទាទោសការធ្វេសប្រហែសមិនយកចិត្តទុកដាក់ចំពោះផ្លូវចិត្តរបស់កុមារជាបទល្មើសព្រហ្មទណ្ឌ | ១៣.២.១- ស្វែងរកការគាំទ្រមតិ បន្ថែមមាត្រាថ្មី ក្នុងក្រមព្រហ្មទណ្ឌដើម្បីអនុម័តការមិនយកចិត្តទុកដាក់ ចំពោះផ្លូវចិត្តកុមារ ក្រោមអាយុ ១៨ឆ្នាំ ជាបទល្មើសព្រហ្មទណ្ឌ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | X | X | | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តធម៌ |

## ផ្នែករងទី៤៖ ការបង្កើតគោលនយោបាយ

**លទ្ធផលទី ១៤៖** កុមារី និងកុមារទទួលបានកិច្ចការពារបន្ថែមទៀតចំពោះគ្រប់ទម្រង់នៃអំពើហិង្សា តាមរយៈក្របខ័ណ្ឌគតិយុត្តិនិងគោលនយោបាយ

**សូចនាករលទ្ធផលទី ១៤ក៖** ក្របខ័ណ្ឌគោលនយោបាយដែលគ្រប់ជ្រុងជ្រោយ និងតាមវិស័យ ស្តីពីការទប់ស្កាត់ ឆ្លើយតប និងសម្រាប់ការប្រមូលទិន្នន័យ អំពីអំពើហិង្សាលើកុមារត្រូវបានអនុម័តដោយក្រសួង និងស្ថាប័នសំខាន់ៗ

**សូចនាករលទ្ធផលទី ១៤ខ៖** ភាគរយ នៃសេវាកិច្ចការពារកុមារត្រូវបានគ្រប់គ្រងដោយបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារកុមារ

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១៤.១- កំណើនសមត្ថភាពរបស់ស្ថាប័នសំខាន់ៗដែលទទួលខុសត្រូវលើកិច្ចការពារកុមារពីអំពើហិង្សាគ្រប់ទម្រង់ | សូចនាករ១៤.១ក៖ វិសោធនកម្មច្បាប់ គោលនយោបាយ និងវិធាន ទាំងឡាយអំពីកិច្ចការពារកុមារដើម្បីកំណត់យន្តការបញ្ជូន និងគោលការណ៍ណែនាំមួយច្បាស់លាស់សម្រាប់ការតាមដាន ឬ កំណត់តួនាទីនិងភារកិច្ចច្បាស់លាស់របស់ក្រសួងនិងស្ថាប័នក្នុងករណីកិច្ចការពារកុមារ ដែលអនុលោមតាមកំណែទម្រង់ច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល | ១៤.១.១- ផ្អែកលើគោលនយោបាយកំណែទម្រង់ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ពិនិត្យ និងធ្វើបច្ចុប្បន្នភាពច្បាប់ គោលនយោបាយ និងវិធានទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ឱ្យអនុលោមតាមអនុសញ្ញាស្តីពី សិទ្ធិកុមារ រួមមាន៖<br>(ក) យន្តការបញ្ជូនសម្រាប់ករណីកិច្ចការពារកុមារ<br>(ខ) គោលការណ៍ណែនាំច្បាស់លាស់ សម្រាប់តាមដានករណីកិច្ចការពារកុមារ<br>(គ) កំណត់ពីតួនាទី និងភារកិច្ច សម្រាប់ក្រសួង និង អ្នកពាក់ព័ន្ធ ច្បាស់លាស់ ចំពោះករណីកិច្ច ការពារកុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | X | X | X | X | X | ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល<br>ក្រសួងយុត្តិធម៌<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងទេសចរណ៍<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | សូចនាករ១៤.១ខ៖ គោលនយោបាយស្តីពីកាតព្វកិច្ចក្នុងការរាយការណ៍អំពីករណីអំពើហិង្សាលើកុមារ និង អំពើរំលោភបំពាន កុមារត្រូវបានបង្កើតសម្រាប់មន្ត្រីវិជ្ជាជីវៈទាំងអស់ | ១៤.១.២- បង្កើតគោលនយបាយ ស្តីពីកាតព្វកិច្ចក្នុងការរាយការណ៍សម្រាប់មន្ត្រីវិជ្ជាជីវៈ ចំពោះអំពើហិង្សា និងការរំលោភបំពានលើកុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | X | X | X | X | X | ក្រសួងយុត្តធម៌<br>ក្រសួងសុខាភិបាល<br>ក្រសួងអប់រំ យុវជន និងកីឡា<br>អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍<br>ក្រសួងទេសចរណ៍<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សូចនាករ១៤.១គ៖ បទដ្ឋានអប្បបរមាសម្រាប់សេវាការពារកុមារបានបង្កើត | ១៤.១.៣.- បង្កើត និងអនុវត្ត បទដ្ឋានអប្បបរមាសម្រាប់ផ្តល់សេវាគាំពារកុមារទាំងអស់ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | X | X | X | X | X | ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១៤.១ឃ៖ ភាគរយនៃភាគីពាក់ព័ន្ធ និងស្ថាប័ន ដែលបានបង្ហាញនូវកំណើនចំណេះដឹងអំពីច្បាប់ គោលនយោបាយ និងវិធានស្តីពីកិច្ចការពារកុមារ | ១៤.១.៤- លើកកម្ពស់ចំណេះដឹង ក្នុងចំណោមអ្នកពាក់ព័ន្ធ អំពីច្បាប់ គោលនយោបាយ និងបទប្បញ្ញត្តិស្តីពីកិច្ចការពារកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | X | X | X | X | X | ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | សូចនាករ១៤.១ង៖ ក្របខ័ណ្ឌគោលនយោបាយដែលគ្រប់ជ្រុងជ្រោយតាមវិស័យសម្រាប់ការចូលរួមពីសំណាក់ក្រសួងនិងស្ថាប័នក្នុងការទប់ស្កាត់ ឆ្លើយតប និងប្រមូលទិន្នន័យអំពីអំពើហិង្សាលើកុមារ បានបង្កើត | ១៤.១.៥- ពិនិត្យគោលនយោបាយតាមវិស័យរបស់អន្តរក្រសួង និងបង្កើតគោលនយោបាយមួយដែលគ្រប់ជ្រុងជ្រោយ ដើម្បីពង្រឹងការបង្ការ និងឆ្លើយតប ចំពោះអំពើហិង្សាលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | X | X | X | X | X | ក្រសួងស្ថាប័នពាក់ព័ន្ធ |
| ១៤.២- រាជរដ្ឋាភិបាល បានប្តេជ្ញាចិត្តចំពោះការវិភាជន៍ថវិកាសម្រាប់កិច្ចការពារកុមារ | សូចនាករ ១៤.២ក៖ យុទ្ធសាស្ត្រ សម្រាប់ស្វែងរកការគាំទ្រមតិក្នុងការបង្កើតប្រព័ន្ធកិច្ចការពារកុមារ បានបង្កើត និង ទទួលយកដោយក្រសួង និង ស្ថាប័នសំខាន់ៗ | ១៤.២.១- បង្កើតយុទ្ធសាស្ត្រស្វែងរកការគាំទ្រមតិក្នុងការបង្កើតប្រព័ន្ធកិច្ចការពារកុមារដែលអនុលោមតាមបទដ្ឋានអន្តរជាតិ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | X | X | | | | ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ |
| | សូចនាករ១៤.២ខ៖ ភាគរយនៃរដ្ឋបាលថ្នាក់ស្រុក បញ្ចូលកម្មវិធីអំពីការបង្ការ និងឆ្លើយតបចំពោះ អំពើហិង្សាលើកុមារ និងកម្មវិធីកិច្ចការពារ កុមារទៅក្នុងផែនការថវិកានិងផែនការសកម្មភាពប្រចាំឆ្នាំ | ១៤.២.២- ស្វែងរកការគាំទ្រមតិ ពីសំណាក់អាជ្ញាធររដ្ឋបាលថ្នាក់ ស្រុក ក្រុងនិងខណ្ឌ ដើម្បីបញ្ចូល សកម្មភាពដែលទាក់ទងនឹងកិច្ចការពារកុមារទៅក្នុងផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ | ក្រសួងមហាផ្ទៃ | | X | X | X | X | ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

**យុទ្ធសាស្ត្រទី ៥៖ ការពិនិត្យតាមដាន និងវាយតម្លៃ**

**គោលបំណងទូទៅ៖** ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារ តាមរយៈការបង្កើតប្រព័ន្ធមួយដែលគ្រប់ជ្រុងជ្រោយសម្រាប់ប្រមូលទិន្នន័យ ពិនិត្យតាមដាន និងរាយការណ៍ករណីអំពើហិង្សាដែលកុមារកម្ពុជាបានទទួលរង

**ផ្នែករងទី១៖ ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ**

**លទ្ធផលទី ១៥ ៖** អនុវត្តក្របខ័ណ្ឌពហុវិស័យ ពិនិត្យតាមដាន វាយតម្លៃ និងប្រព័ន្ធប្រមូលទិន្នន័យ ដែលសម្របសម្រួល និងរាយការណ៍អំពីអំពើហិង្សាលើកុមារនៅកម្ពុជា

**សូចនាករលទ្ធផលទី ១៥ក ៖** ប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) ដែលអាចប្រមូលទិន្នន័យ និងរាយការណ៍អំពីអំពើហិង្សាលើកុមារបានបង្កើតនិងប្រតិបត្តិ

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១៥.១- ការពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍ពីការ អនុវត្តផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ មានប្រសិទ្ធភាព និងទាន់ពេលវេលា | សូចនាករ១៥.១ក ៖ ឧបករណ៍សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃ និងរាយការណ៍អំពីផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ បានបង្កើត និងដាក់ឱ្យប្រើប្រាស់ | ១៥.១.១ បង្កើតឧបករណ៍ ពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍អំពីផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដោយមានប្រព័ន្ធប្រមូលទិន្នន័យ និងស្ថាប័នទទួលខុសត្រូវក្នុងការប្រមូលទិន្នន័យ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | X | | | | | វិទ្យាស្ថានជាតិ ស្ថិតិ ក្រសួងផែនការ |
| | សូចនាករ១៥.១ខ៖ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្តផែនការសកម្មភាព បានបោះពុម្ព និងផ្សព្វផ្សាយ | ១៥.១.២- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំអំពីការអនុវត្តផែនការស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | X | X | X | X | X | ក្រសួង ឬស្ថាប័នពាក់ព័ន្ធ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សូចនាករ១៥.១គ៖ របាយការណ៍វឌ្ឍនភាពស្តីពីការពិនិត្យនិងវាយតម្លៃពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិ អំពីការអនុវត្តផែនការសកម្មភាព និងទិន្នន័យ | ១៥.១.៣- រៀបចំការពិនិត្យផែនការ ពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិ ដែលសង្ខេបអំពីដំណើរ ការអនុវត្តផែនការសកម្មភាពស្តីពី ការទប់ស្កាត់ និង ឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងទិន្នន័យពាក់ព័ន្ធដែលបានប្រមូល | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | | | X | | X | ក្រសួង ឬស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១៥.១ឃ៖ របាយការណ៍ចុងក្រោយអំពីផលប៉ះពាល់ដែលមានការវិភាគទិន្នន័យ និងបញ្ហាប្រឈម បទពិសោធន៍ និងមេរៀនល្អៗ ទទួលបានក្នុងរយៈពេល ៥ឆ្នាំនៃការអនុវត្តន៍ផែនការសកម្មភាពបានផ្សព្វផ្សាយ ជាសាធារណៈ | ១៥.១.៤-រៀបចំរបាយការណ៍លទ្ធផល ចុងក្រោយ ដែលវិភាគទិន្នន័យអំពី ការអនុវត្តផែនការសកម្មភាពស្តីពីការ ទប់ស្កាត់ និងឆ្លើយតប ចំពោះ អំពើហិង្សាលើកុមារ និង ការអនុវត្តល្អ បញ្ហាប្រឈម និង បទពិសោធន៍ដែលទទួលបានពីការអនុវត្តផែនការនេះក្នុងរយៈពេល ៥ឆ្នាំ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | | | | | X | វិទ្យាស្ថានជាតិស្ថិតិ ក្រសួង ផែនការ ឬស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១៥.១ង៖ ភាគរយនៃសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ បានទទួលការបណ្តុះបណ្តាលស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ អំពីផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | ១៥.១.៥- បណ្តុះបណ្តាលអំពីឧបករណ៍ត្រួតពិនិត្យតាមដាន និងវាយតម្លៃស្តីពី ការអនុវត្តផែនការសកម្មភាពដល់សមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារដើម្បីប្រើប្រាស់ជាចំណេះដឹង ក្នុងការអនុវត្តផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | | X | X | X | X | អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៥.២- មានប្រព័ន្ធ ប្រមូលទិន្នន័យពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍ អំពីសភាពនិងវិសាលភាពរបស់អំពើហិង្សាលើកុមារ | សូចនាករ១៥.២ក៖ នីតិវិធីសម្រាប់រាយការណ៍ និង ប្រមូលទិន្នន័យជាក់លាក់តាមវិស័យ (សុខាភិបាល អប់រំ យុត្តិធម៌ នគរបាល និងសេវាសង្គម ។ល។) សម្រាប់សូចនាករអំពើហិង្សានិងបរិយាកាសគាំពារបានបង្កើត | ១៥.២.១- បង្កើតនីតិវិធីជាក់លាក់តាមវិស័យសម្រាប់ប្រមូលទិន្នន័យ និង រាយការណ៍អំពីសូចនាករស្នូលនៃការរំលោភបំពាន និងបរិយាកាសគាំទ្រ | ក្រសួងមហាផ្ទៃ | X | X | | | | វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ |
| | សូចនាករ១៥.២ខ៖ បង្កើតប្រព័ន្ធទិន្នន័យមូលដ្ឋានសម្រាប់រាល់ទិន្នន័យដែលពាក់ព័ន្ធនឹងអំពើហិង្សាលើកុមារ | ១៥.២.២- បង្កើតប្រព័ន្ធទិន្នន័យមូលដ្ឋានដែលមានសង្គតិភាពសម្រាប់ផ្ទុកទិន្នន័យដែលមានសូចនាករអំពីអំពើហិង្សាលើកុមារតាមវិស័យពាក់ព័ន្ធ | វិទ្យាស្ថានជាតិ ស្ថិតិ ក្រសួងផែនការ | | X | X | | | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | សូចនាករ១៥.២គ៖ របាយការណ៍វិភាគអំពីសូចនាករស្នូលនៃអំពើហិង្សា និង បរិយាកាសគាំពារ បានបោះពុម្ពផ្សព្វផ្សាយរៀងរាល់ឆ្នាំ | ១៥.២.៣- បោះពុម្ពផ្សាយរបាយការណ៍វិភាគប្រចាំឆ្នាំដែលមានសូចនាករស្នូលអំពីអំពើហិង្សាលើកុមារ និងបរិយាកាសគាំពារ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | | | X | X | X | វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ |
| | សូចនាករ១៥.២ឃ៖ របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិនិងបញ្ចប់អាណត្តិបានបោះពុម្ពនិងផ្សព្វផ្សាយដល់គ្រប់ក្រសួងនិងស្ថាប័នដែលចូលរួមទាំងអស់ | ១៥.២.៤- ធ្វើការវាយតម្លៃពាក់កណ្តាល និងចុងអាណត្តិនៃការអនុវត្តផែនការសកម្មភាពស្តីពី ការទប់ស្កាត់និងឆ្លើយតបចំពោះ អំពើហិង្សាលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ | | | X | | X | វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ |

**ផ្នែករងទី២៖ ការពិនិត្យតាមដាន លើការទប់ស្កាត់និង ឆ្លើយតបចំពោះអំពើហិង្សាលើកុមារដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន**

**លទ្ធផលទី១៦** ៖ ភស្តុតាងសម្រាប់យុទ្ធសាស្ត្រស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនៅកម្ពុជាបានពង្រឹង

**សូចនាករលទ្ធផលទី ១៦ក** ៖ បញ្ហានានាស្តីពីអំពើហិង្សាលើកុមារនិងកិច្ចការពារកុមារ បានបញ្ចូលក្នុងរបៀបវារៈនៃការសិក្សាស្រាវជ្រាវ និងអង្កេតសំខាន់ៗនៅថ្នាក់ជាតិ

| លទ្ធផលបឋម | សូចនាករ | សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | តារាងពេលវេលា(ឆ្នាំ) | | | | | ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | |
| ១៦.១- ពង្រឹងកិច្ចសហការ និងសមត្ថភាពរបស់សាកលវិទ្យាល័យ និង ស្ថាប័នស្រាវជ្រាវក្នុងនិងក្រៅ ប្រទេស សម្រាប់ការវាយតម្លៃដែលប្រាកដប្រជាលើកម្មវិធីកិច្ចការពារកុមារ | សូចនាករ១៦.១ក៖ ចំនួននៃការវាយតម្លៃដែលរឹងមាំអំពីផលប៉ះពាល់ របស់គោលនយោបាយ និងកម្មវិធីទៅលើសូចនាករសំខាន់ៗនៃអំពើហិង្សាលើកុមារ | ១៦.១.១- បង្កើតភាពជាដៃគូជាមួយសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវក្នុងនិងក្រៅប្រទេស និងលើកទឹកចិត្តការវាយតម្លៃច្បាស់លាស់ ស្តីពីផលប៉ះពាល់ទៅលើសូចនាករស្នូលនៃអំពើហិង្សាលើកុមាររបស់កម្មវិធីអាទិភាព និងជាក់លាក់ណាមួយ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | X | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១៦.១ខ៖ យន្តការកៀរគរមូលនិធិ សម្រាប់ការវាយតម្លៃជាអាទិភាពពីផែនការសកម្មភាពនិងគោលនយោបាយដែលផ្តោតទៅលើអំពើហិង្សាលើកុមារ | ១៦.១.២- បង្កើតយុទ្ធសាស្ត្រ ស្វែងរកថវិកាសម្រាប់គាំទ្រការវាយតម្លៃអំពីគោលនយោបាយ និងកម្មវិធី ដែលផ្តោតលើអំពើហិង្សាលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | X | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| ១៦.២- អ្នកពាក់ព័ន្ធសំខាន់ៗ បានបង្កើនចំណេះដឹងអំពីបទពិសោធន៍ និង ការអនុវត្តល្អៗ ដើម្បីទប់ស្កាត់ និង ឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | សូចនាករ១៦.២ក៖ ភាគរយនៃស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលបានបញ្ចូលរបកគំហើញនៃការវាយតម្លៃ ទៅក្នុងការរៀបចំសេវាគាំពារនិងកម្មវិធីរបស់ខ្លួន | ១៦.២.១-ចងក្រងឯកសារបទពិសោធន៍ និងការអនុវត្តល្អៗ ដែលមានមូលដ្ឋានលើការវាយតម្លៃគោលនយោបាយ និងកម្មវិធីអំពើហិង្សាលើកុមារសម្រាប់ការតស៊ូមតិអំពី គោលនយោបាយស្តីពីកិច្ចការពារកុមារ និងអំពើហិង្សាលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| | សូចនាករ១៦.២ខ៖ ចំនួនមន្ត្រីវិជ្ជាជីវៈបានស្វែងយល់អំពីរបកគំហើញសំខាន់ៗរបស់ការវាយតម្លៃ តាមរយៈកិច្ចប្រជុំ អង្គសិក្ខាសាលា និង តាមប្រព័ន្ធទំនាក់ទំនងសង្គម | ១៦.២.២- ផ្សព្វផ្សាយឱ្យបានទូលំទូលាយរបកគំហើញនៃកម្មវិធីវាយតម្លៃ តាមកិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយសង្គម | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | X | X | X | X | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |

## ៦. ការពិនិត្យតាមដាន ការរាយការណ៍ និង ការវាយតម្លៃ

គោលដៅនៃកិច្ចខិតខំទាំងនេះ គឺដើម្បីកំណត់អំពីវឌ្ឍនភាពនៅក្នុងសកម្មភាពទប់ស្កាត់ និង ឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ព្រមទាំងកំណត់រកចំណុចខ្សោយ ចន្លោះប្រហោង និង បញ្ហាប្រឈមនានា។ ជោគជ័យ និង ឧបសគ្គដែលត្រូវបានកំណត់រកឃើញក្នុងពេលអនុវត្តន៍ នឹងត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានព័ត៌មានសម្រាប់ការកែសម្រួលទៅលើអន្តរាគមន៍បែបយុទ្ធសាស្ត្រ និង ចងក្រងជាមេរៀន បទពិសោធន៍ដែលបានរៀនសូត្រ និង ការអនុវត្តល្អ សម្រាប់ផ្សព្វផ្សាយ និង ប្រើប្រាស់នៅក្នុងការរៀបចំផែនការក្នុងជំហានបន្ទាប់ សម្រាប់អន្តរាគមន៍ចំពោះបញ្ហាអំពើហិង្សាលើកុមារ។ ដូច្នេះ ត្រូវការឱ្យមានការត្រួតពិនិត្យ ការរាយការណ៍ និង ការវាយតម្លៃទៅលើផែនការសកម្មភាព ដើម្បីធានាឱ្យការអនុវត្តន៍ទទួលបានជោគជ័យ។

ការត្រួតពិនិត្យ និងវាយតម្លៃទៅលើផែនការសកម្មភាព ជារួមមានរបាយការណ៍សកម្មភាពប្រចាំឆ្នាំមួយ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិមួយ និង ការត្រួតពិនិត្យចុងអាណត្តិមួយ ព្រមទាំងការវាយតម្លៃបញ្ចប់។ យន្តការថ្មីៗ និង យន្តការដែលមានស្រាប់ ព្រមទាំងឧបករណ៍នានា នឹងត្រូវបានយកមកប្រើប្រាស់ ដើម្បីបង្កើតប្រព័ន្ធប្រមូលទិន្នន័យមួយ សម្រាប់ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព ក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធ និង អង្គការសង្គមស៊ីវិល។ ប្រព័ន្ធត្រួតពិនិត្យនេះ នឹងជួយសម្របសម្រួលដល់ការប្រមូលទិន្នន័យ អំពីអំពើហិង្សាលើកុមារ និង ផ្តល់លទ្ធភាពក្នុងការទទួលបានទិន្នន័យដែលមានពីប្រភពផ្សេងៗគ្នា ក្រោមមូលដ្ឋានមួយដែលទៀងទាត់ និង អាចជឿទុកចិត្តបាន ដើម្បីបង្កលក្ខណៈឱ្យក្រសួងរបស់រដ្ឋាភិបាល និង អ្នកពាក់ព័ន្ធដទៃទៀតអាចធ្វើការប៉ាន់ប្រមាណក្នុងលក្ខណៈជាប្រព័ន្ធទៅលើនិន្នាការ ដើម្បីកែលម្អអន្តរាគមន៍ចំពោះបញ្ហាអំពើហិង្សាលើកុមារ។ ប្រព័ន្ធនេះនឹងផ្តល់ធនធានជូនក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការអភិវឌ្ឍ និង វិភាគគោលនយោបាយ កែលម្អ ការផ្តល់សេវា និងកំណត់អំពីការប្រើប្រាស់ធនធានដែលមាន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងការលំបាកនានាក្នុងការអនុវត្ត ដែលទង្វើនេះបានលើកកម្ពស់នូវតម្លាភាព និង គណនេយ្យភាពរបស់សកម្មភាពរដ្ឋាភិបាលផងដែរ។

## ៧. ការគណនាថ្លៃចំណាយនៃផែនការសកម្មភាព

ផែនការសកម្មភាពនេះ រួមមានការប៉ាន់ប្រមាណថ្លៃចំណាយ ក្នុងលក្ខណៈជាឧបសម្ព័ន្ធ ដែលនឹងជួយផ្តល់មូលដ្ឋានព័ត៌មានសម្រាប់នីតិវិធីគណនាថ្លៃចំណាយរបស់ក្រសួងពាក់ព័ន្ធ ដែលមានលក្ខណៈទូលំទូលាយជាងនេះ អាស្រ័យដោយគេបញ្ចូលសកម្មភាពអំពើហិង្សាលើកុមារ ទៅក្នុងផែនការប្រតិបត្តិ និងផែនការថវិកាប្រចាំឆ្នាំ។

ក្រសួងពាក់ព័ន្ធទទួលខុសត្រូវក្នុងការធានាឱ្យមានមូលនិធិសម្រាប់អនុវត្តផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ តាមរយៈកិច្ចគាំទ្រពីថវិកាជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ឬ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និង ម្ចាស់ជំនួយដទៃទៀត។ ការប៉ាន់ប្រមាណថ្លៃចំណាយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យរយៈពេលវែង (៥ឆ្នាំ) ជួយគាំទ្រដល់ការអនុវត្ត តាមរយៈការជួយកំណត់អំពីរបៀប ក្នុងការវិភាជន៍ថវិកាដ៏ប្រសើរបំផុត និងចាត់អាទិភាពទៅលើធនធានដែលមានកម្រិត និងតាមរយៈការកំណត់រកចន្លោះប្រហោងធនធាន ដើម្បីធ្វើការចង្អុលទិសចំពោះសកម្មភាពស្វែងរកមូលនិធិ។

## ៨. សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពនេះមានគោលបំណងអភិវឌ្ឍន៍ប្រព័ន្ធការពារកុមាររបស់កម្ពុជា ទៅក្នុងក្របខ័ណ្ឌមួយដ៏រឹងមាំ សម្រាប់អន្តរាគមន៍បែបប្រតិសកម្ម និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលទប់ស្កាត់កុមារី និង កុមារាពីការប្រឈមទៅនឹងអំពើហិង្សា និងផ្តល់ការឆ្លើយតបដែលដោះស្រាយឫសគល់នៃបញ្ហានៅពេលដែលអំពើហិង្សាកើតឡើង។ នៅក្នុងការផ្តល់សេវា ប្រទេសកម្ពុជានឹងបោះជំហានឆ្ពោះទៅរកអភិក្រមការពារកុមារមួយដែលមានលក្ខណៈពហុវិស័យ និង មានការសម្របសម្រួលរួមបញ្ចូលគ្នាទាំងស្រុង ជាមួយតួអង្គសំខាន់ៗ ដែលសហការ និងសហប្រតិបត្តិការផ្តល់អន្តរាគមន៍ប្រកបដោយបរិយាប័ន្ន ដែលកាន់តែមានលក្ខណៈកុមារមេត្រី និងផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ។ ប្រទេសកម្ពុជានឹងបោះជំហានចេញពីការអភិវឌ្ឍច្បាប់ និង គោលនយោបាយមូលដ្ឋាន ឆ្ពោះទៅរកការពង្រឹងការយល់ដឹង ការអនុវត្ត និង ការប្រតិបត្តិច្បាប់ និងគោលនយោបាយទាំងនេះនៅកម្រិតថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។ ប្រព័ន្ធប្រមូលទិន្នន័យគ្រប់ជ្រុងជ្រោយមួយ នឹងត្រូវបានអភិវឌ្ឍន៍ និងអនុវត្ត ដើម្បីត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពនេះ។ ក្នុងឆ្នាំ២០២១ តាមរយៈការពិនិត្យ កែសម្រួលឡើងវិញ ការត្រួតពិនិត្យ និងការវាយតម្លៃ នៅក្នុងឆ្នាំចុងក្រោយនៃផែនការយើងត្រូវសម្រេចឱ្យបាននូវលទ្ធផលជាវិជ្ជមានដែលទទួលបានតាមរយៈកិច្ចខិតខំរយៈពេល៥ឆ្នាំនេះដោយមានកិច្ចគាំទ្រ និង ការចូលរួមយ៉ាងសកម្មពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង សង្គមស៊ីវិល នៅក្នុងសកម្មភាពនីមួយៗ។

# ៩. សន្ទានុក្រម

| កុមារ ឬ អនីតិជន | បុគ្គលទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ។ |
|---|---|
| **ពលកម្មកុមារ ឬ ការកេងប្រវ័ញ្ចពលកម្មកុមារ** (**សូមមើលផងដែរនូវទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**) | ការងារដែលធ្វើឱ្យកុមារបាត់បង់កុមារភាព សក្តានុពល និង ភាពថ្លៃថ្នូររបស់ពួកគេ និង ដែលបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្លូវកាយ និង ផ្លូវចិត្ត និងរាប់បញ្ចូលការងារដែលមានគ្រោះថ្នាក់ផ្នែកផ្លូវចិត្ត ផ្លូវកាយ សង្គម ឬសីលធម៌ចំពោះកុមារ។ ធ្វើឱ្យពួកគេបាត់បង់ឱកាសទៅសាលារៀន តម្រូវឱ្យពួកគេចាកចេញពីសាលារៀនមុនពេលកំណត់ ឬ ទាមទារឱ្យពួកគេប៉ុនប៉ងធ្វើការប្រពាច់បញ្ចូលគ្នានូវការទៅរៀននៅឯសាលា ជាមួយការងារ ដែលមានរយៈពេលវែង និងធ្ងន់ធ្ងរ[44]។ ពលកម្មកុមារត្រូវបានចាត់ទុកថាជាទម្រង់មួយនៃការកេងប្រវ័ញ្ចកុមារ។ |
| **អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ** | ការចងសម្ព័ន្ធមេត្រីតាមបែបវប្បធម៌ ឬ តាមផ្លូវច្បាប់ រវាងមនុស្សពីរនាក់ (យ៉ាងហោចណាស់ភាគីម្ខាងមានអាយុក្រោម១៨ឆ្នាំ) ដែលបង្កើតឱ្យមាននូវសិទ្ធិ និង កាតព្វកិច្ចជាក់លាក់ រវាងពួកគេ កូនរបស់ពួកគេ និង គ្រួសាររបស់ពួកគេ (សាច់ថ្លៃ)។ រាប់បញ្ចូលផងដែរនូវការចងសម្ព័ន្ធមេត្រី បែបមិនផ្លូវការ ដែលកុមារអាយុក្រោម១៨ឆ្នាំ រស់នៅជាមួយដៃគូម្នាក់ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍។ នេះគឺជាទម្រង់មួយនៃការកេងប្រវ័ញ្ចកុមារ[45]។ |
| **ការជួញដូរកុមារ[46] ឬ ការជួញដូរមនុស្ស** | ឧក្រិដ្ឋកម្មមួយដែលពាក់ព័ន្ធការចរាចរកុមារនៅក្នុងប្រទេស ឬ ឆ្លងកាត់ព្រំដែន មិនចំពោះថាមាន ឬ គ្មានការប្រើប្រាស់កម្លាំងឡើយ សម្រាប់គោលបំណងកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬ កេងប្រវ័ញ្ចផ្លូវភេទ។ |
| **កុមារមេត្រី** | ទីកន្លែង ប្រព័ន្ធ នីតិវិធី ឬ សេវាដែលត្រូវបានរចនាឡើង និង ធ្វើប្រតិបត្តិការក្នុងលក្ខណៈមួយដែលផ្តោតអាទិភាពទៅលើសុវត្ថិភាព និង ប្រយោជន៍របស់កុមារ និង ពិចារណាអំពីសុខុមាលភាព និង សេចក្តីត្រូវការផ្នែកអភិវឌ្ឍន៍ផ្លូវកាយ ចិត្តសាស្ត្រ ចិត្តសង្គម និង ស្មារតីរបស់កុមារ ដោយមានការយល់ដឹងជាក់លាក់ អំពីហានិភ័យចំពោះកុមារនៃក្រុមងាយរងគ្រោះ ឬ ក្រុមដែលមានការប្រឈម ឬ កុមារដែលស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ជាសក្តានុពល។ |
| **កុមារមានទំនាក់ទំនងជាមួយច្បាប់** | បុគ្គលទាំងឡាយណាអាយុក្រោម១៨ឆ្នាំ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ណាមួយ (ព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬ រដ្ឋបាល) ក្នុងសមាសភាពណាមួយ មិនចំពោះថា ជាជនរងគ្រោះ ឬ សាក្សីនៃឧក្រិដ្ឋកម្ម ជាកម្មវត្ថុនៃសវនាការតុលាការ ឬ ជាជនសង្ស័យ ឬ ជនជាប់ចោទប្រព្រឹត្តបទល្មើសឡើយ។ |

44 ILO, Migration and Child Labour.

45 Hamilton C.,Legal Protection from Violence: Analysis of Domestic Laws Related to Violence Against children in ASEAN Member States, 2015.

46 ILO, Towards the Elimination of the Worst Forms of Child Labour (TECL), 2007.

| | |
|---|---|
| **អង្គការសង្គមស៊ីវិល (CSOs)** | អង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ ដែលបម្រើប្រយោជន៍ និង សុខុមាលភាពរបស់ក្រុមនានានៅក្នុងសង្គម តាមរយៈសកម្មភាពមួយ ចំនួន ដូចជាការផ្តល់សេវា ការកៀរគរសហគមន៍ ការស្រាវជ្រាវអំពីគោលនយោបាយ និង ការស្វែងរកការគាំទ្រ និង ជាញឹកញាប់ត្រូវបាន បង្កើត និង គ្រប់គ្រងដោយសមាជិកនៃក្រុមសង្គមទាំងនេះដោយខ្លួនឯង។ អង្គការ សង្គម ស៊ីវិល មានសមត្ថភាពពិសេសក្នុងការអនុវត្តន៍សកម្មភាព ដែលមានសារៈសំខាន់ សម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពដែលកើតឡើងជាក់ស្តែងនៅមូលដ្ឋាន។ អង្គការសង្គមស៊ីវិល រួមមានអង្គការមិនមែន រដ្ឋាភិបាលជាតិ និង អន្តរជាតិ អង្គការជនពិការ ក្រុមជួយខ្លួនឯង និង អង្គការសហគមន៍។ |
| **ទណ្ឌកម្មលើរាងកាយ** | ទណ្ឌកម្មទាំងឡាយណាដែលប្រើកម្លាំងកាយ និង មានបំណងបង្កការឈឺចាប់ ឬ ភាពមិនស្រណុក ក្នុងកម្រិតណាមួយ បើទោះបីជាវាមានកម្រិត “ស្រាល” ប៉ុណ្ណាក៏ដោយ។<br><br>ឧទាហរណ៍រួមមាន ៖ ការវាយកុមារដោយប្រើដៃ ឬ ជាមួយនឹងវត្ថុអ្វីមួយ (ដូចជា រំពាត់ផ្តៅ ខ្សែក្រវ៉ាត់ ខ្សែតី ស្បែកជើង ។ល។) ការទាត់ធាក់ ការអង្រួន ឬ ការគ្រវែងកុមារ ការក្តិច ឬ ការបោចសក់ ការបង្ខំកុមារឱ្យស្ថិតនៅក្នុងជំហរមួយដែលមិនស្រណុក ឬ បាត់បង់ភាពថ្លៃថ្នូរ ឬ ការអនុវត្តលំហាត់ប្រាណច្រើនហួសប្រមាណ និង ការបង្កការរលាក ឬស្លាកស្នាមលើកុមារ។ |
| **ការកំសាន្តអប់រំ** | ការកំសាន្តប្រកបដោយការអប់រំ |
| **អំពើហិង្សាផ្លូវចិត្ត ឬ អំពើរំលោភបំពានផ្លូវចិត្ត** | “ការប្រព្រឹត្តអាក្រក់ ឬ ការប្រព្រឹត្តមិនយកចិត្តទុកដាក់របស់ឪពុកម្តាយ ឬ អ្នកមើលថែកុមារ ដែលធ្វើឱ្យកុមារបាត់បង់ទំនុកចិត្តលើខ្លួនឯង ធ្វើឱ្យធ្លាក់ចុះនូវអារម្មណ៍ជឿជាក់ក្នុងការសម្រេចលទ្ធផលការងារ ធ្វើឱ្យថយចុះនូវអារម្មណ៍ថាខ្លួនឯងជាចំណែកនៃអ្វីមួយ រាំងស្ទះដល់ការ អភិវឌ្ឍល្អប្រសើរ និង ភាពខ្លាំងក្លារបស់កុមារ ព្រមទាំងធ្វើឱ្យបាត់បង់សុខុមាលភាពរបស់កុមារ” [47]។ អំពើហិង្សាផ្លូវចិត្តត្រូវបានកំណត់លក្ខណៈតាមរយៈ “ឥរិយាបថអវិជ្ជមានដែលកើតឡើង ជាបន្តបន្ទាប់ ការជំរុញឱ្យមាននូវការផ្សារភ្ជាប់ទំនាក់ទំនងដែលគ្មានសុវត្ថិភាព ការរំពឹងទុក និងការពិចារណាទៅលើការអភិវឌ្ឍដែលមិនសមស្រប ការគ្មានអារម្មណ៍ ការមិនបានទទួលស្គាល់លក្ខណៈបុគ្គលរបស់កុមារ និង ព្រំដែននៃចិត្តសាស្ត្រ ព្រមទាំងការបែកសតិ និងភាពគ្មានសង្គតិភាព” [48]។ បន្ថែមពីនេះទៀត អំពើហិង្សាផ្លូវចិត្តអាចប្រព្រឹត្តដោយមិត្តភក្តិរបស់កុមារ ដូចជាការសម្លុត។<br><br>ឧទាហរណ៍រួមមាន ៖ ការបង្កការរន្ធត់ និង ការគំរាមកំហែង ការតិះដៀល និងការបដិសេធ ការដាក់ឱ្យនៅដាច់ដោយឡែកពីគេឯង ឬ ការមិនយកចិត្តទុកដាក់ចំពោះកុមារ ឬ ការបង្ហាញឱ្យឃើញអំពីភាពលម្អៀងចំពោះកុមារដទៃ ការមិនអើពើចំពោះសេចក្តីត្រូវការផ្នែកសុខភាពផ្លូវចិត្ត ឬ ផ្នែកវេជ្ជសាស្ត្រ និង ការអប់រំរបស់កុមារ ការប្រមាថ ការហៅឈ្មោះ បែបមិនគួរសម ការបង្កការអាប់ឱន ការមិនផ្តល់តម្លៃ ការសើចចំអក និង ការបង្កការឈឺចាប់ចំពោះអារម្មណ៍របស់កុមារ ការធ្វើឱ្យកុមារឃើញអំពើហិង្សា ការឃុំឃាំងកុមារដាច់ដោយឡែកពីគេឯង ការរក្សាកុមារឱ្យនៅដាច់ដោយឡែក លក្ខខណ្ឌនៃការឃុំខ្លួនដែលបង្កការអាប់ឱន ឬ បន្ទាបបន្ថោក និង ការសម្លុតខាងចិត្តសាស្ត្រ និង ការប្រព្រឹត្តបៀតបៀនពីសំណាក់មនុស្សពេញវ័យ ឬ កុមារដទៃទៀត រាប់បញ្ចូល តាមរយៈ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICTs) ដូចជា ៖ ទូរស័ព្ទចល័ត និងអ៊ីនធឺណិត ដែលគេស្គាល់ថាជា “ការសម្លុតតាមប្រព័ន្ធអ៊ីនធឺណិត [49]”។ |

47 Iwaniec D., The Emotionally Abused and Neglected Child, 1995, p.14.

48 Glaser,In Clinical Paediatrics: Child Abuse, 1993.

49 UN Committee on the Rights of the Child (UNCRC),The Rights of the Child to Freedom from all Forms of Violence, 2011.

| | |
|---|---|
| **ការប្រព្រឹត្តផ្លូវភេទប្រកបដោយគ្រោះថ្នាក់របស់កុមារ** | ការប្រព្រឹត្តផ្លូវភេទរបស់កុមារ និង យុវជនអាយុក្រោម១៨ឆ្នាំ ដែលពុំមានភាពសមស្របចំពោះការអភិវឌ្ឍ អាចមានគ្រោះថ្នាក់ចំពោះខ្លួនឯង ឬ អ្នកដទៃ និង/ឬ អាចបង្កការរំលោភបំពានចំពោះកុមារ យុវជន ឬ មនុស្សពេញវ័យ ដទៃទៀត។ |
| **មន្ត្រីអនុវត្តច្បាប់** | មន្ត្រី ភ្នាក់ងារ ឬ និយោជិតរបស់រដ្ឋាភិបាល ដែលច្បាប់បានប្រគល់សិទ្ធិអំណាចឱ្យទទួលខុសត្រូវ ឬ ចូលរួមនៅក្នុងការបង្ការ ការស៊ើបអង្កេត ការចាប់ខ្លួន ឬ ការឃុំខ្លួនបុគ្គលដែលសង្ស័យ ឬ ត្រូវបានផ្តន្ទាទោសពីបទល្មើសដែលមានកំណត់ចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ ឧទាហរណ៍ រួមមានមន្ត្រីនគរបាលជាតិ និង មន្ត្រីអាវុធហត្ថ ចៅក្រម និង មន្ត្រីតុលាការ ព្រះរាជអាជ្ញា និយោជិតរបស់មណ្ឌលឃុំឃាំង ភ្នាក់ងារអធិការកិច្ច និងភ្នាក់ងារដទៃទៀតរបស់រដ្ឋាភិបាល ដែលមានសិទ្ធិអំណាច ធ្វើការស៊ើបអង្កេត ឬ អនុវត្តការងារស្របតាមច្បាប់។ |
| **ការរៀនសូត្រអំពីការរស់នៅក្នុងប្រទេសកម្ពុជា** | កម្មវិធីបំណិនជីវិតអន្តរប្រព័ន្ធផ្សព្វផ្សាយមួយដែលបង្កលក្ខណៈ និង លើកទឹកចិត្តយុវជនវ័យក្មេងឱ្យចូលរួមក្នុងបញ្ហាយេនឌ័រ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ព្រមទាំងសិទ្ធិ (SRHR)។ វាធ្វើការច្របាច់បញ្ចូលគ្នា រវាងប្រព័ន្ធរៀនសូត្រអេឡិចត្រូនិចនិងតាមកុំព្យូទ័រ ជាមួយសេវាសំណួរ និងចម្លើយតាមទូរស័ព្ទចល័ត។ វាក៏បញ្ចូលប្រព័ន្ធផ្សព្វផ្សាយថ្មីៗដែលមានសម្រាប់យុវជនវ័យក្មេងនៅក្នុងប្រទេសផ្សេងៗគ្នាផងដែរ។ |
| **គ្រឹះស្ថានប្រព័ន្ធផ្សព្វផ្សាយ** | អង្គការមួយដែលសមត្ថភាពស្នូលរបស់អង្គការនេះ គឺជាការបង្កើតមាតិកា ព័ត៌មានដែលត្រូវបានយកមកលក់ជា “ផលិតផល” មួយ និងផ្សព្វផ្សាយជូនអ្នកប្រើប្រាស់ព័ត៌មាន តាមរយៈបច្ចេកវិទ្យាផ្សព្វផ្សាយមួយ ឬ ច្រើន រាប់បញ្ចូលការបោះពុម្ពផ្សាយ ការផ្សាយតាមវិទ្យុ និង ទូរទស្សន៍ និងការផ្សព្វផ្សាយតាមអ៊ីនធឺណិត។ |
| **ការមិនអើពើ ឬ ការប្រព្រឹត្តមិនអើពើ**[50] | ការខកខានដោយចេតនាក្នុងការផ្តល់ជូន សម្រាប់ការអភិវឌ្ឍកុមារក្នុងគ្រប់វិស័យ ៖ សុខភាព អប់រំ ការអភិវឌ្ឍស្មារតី អាហារូបត្ថម្ភ ជម្រក កិច្ចគាំពារ សង្គម និង វិស័យដទៃទៀត។<br><br>និយមន័យនៃការមិនអើពើ ត្រូវពិចារណាអំពីការមានធនធាន ដើម្បីឱ្យការមិនអើពើ ត្រូវបានបែងចែកឱ្យដាច់ពីការខ្វះខាតដោយសារតែភាពក្រីក្រ។<br><br>ឧទាហរណ៍រួមមាន ៖ (ក) ការមិនអើពើផ្លូវកាយ ៖ ការខកខានក្នុងការ ការពារកុមារពីគ្រោះថ្នាក់ រាប់បញ្ចូល តាមរយៈកង្វះការមើលការខុសត្រូវ ឬ ការផ្តល់ឱ្យកុមារនូវសេចក្តីត្រូវការចាំបាច់មូលដ្ឋាន រួមមានអាហារ ជម្រក សម្លៀកបំពាក់ និង ការថែទាំសុខភាពមូលដ្ឋានឱ្យបានគ្រប់គ្រាន់ (ខ) ការមិនអើពើផ្នែកចិត្តសាស្ត្រ ឬ ផ្លូវចិត្ត រួមមាន ការខកខានក្នុងការផ្តល់កិច្ចគាំទ្រផ្លូវចិត្ត និង ក្តីស្រឡាញ់ដល់កុមារ ការមិនយកចិត្តទុកដាក់រ៉ាំរ៉ៃ និង “ការគ្មានចិត្តសាស្ត្រ” តាមរយៈការមើលរំលងចំពោះសញ្ញាណ និង សញ្ញានានារបស់កុមារតូច និង ការប្រឈមទៅនឹងអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬ ការប្រើប្រាស់បំពានគ្រឿងញៀន ឬ គ្រឿងស្រវឹង (គ) ការមិនអើពើចំពោះការអប់រំ ៖ ការខកខានក្នុងការអនុវត្តស្របតាមច្បាប់ ដែលតម្រូវឱ្យអ្នកថែទាំធានាឱ្យបាននូវការអប់រំរបស់កូនពួកគេ តាមរយៈ ការទៅរៀននៅឯសាលា ឬ កន្លែងដទៃទៀត និង (ឃ) ការបោះបង់កុមារ[51]។ |

50 Krug E., World Report on Violence and Health, 2002.

51 UN Committee on the Rights of the Child (UNCRC),The Rights of the Child to Freedom from all Forms of Violence, 2011.

| | |
|---|---|
| **អំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត**[52] | ទម្រង់មួយនៃការកេងប្រវ័ញ្ច និង ការរំលោភបំពានផ្លូវភេទកុមារ ដែលកើតឡើងនៅក្នុងវេទិកា ICT ដូចជាគេហទំព័រ និង វេទិកាតាមប្រព័ន្ធ អ៊ីនធឺណិតដទៃទៀត ទូរស័ព្ទ និង កម្មវិធីចល័ត ដោយរាប់បញ្ចូល ៖<br>• ការផលិត ការកាន់កាប់ និង ការចែកចាយសម្ភារៈរំលោភ បំពានផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត<br>• ការល្បួងកុមារដែលអាចក្លាយជាជនរងគ្រោះតាមប្រព័ន្ធអ៊ីនធឺណិត ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ<br>• ការផ្សាយបន្តផ្ទាល់នូវអំពើកេងប្រវ័ញ្ច និង រំលោភបំពានផ្លូវភេទលើកុមារ។ |
| **អភិក្រម/កម្មវិធីរវាងមិត្តភក្តិ** | សកម្មភាព ដែលមានគោលបំណងបណ្តុះកិច្ចសន្ទនារវាងក្រុមយុវជន ដើម្បីឱ្យផ្តល់មតិយោបល់ត្រឡប់ជូនគ្នាទៅវិញទៅមក។ |
| **អំពើហិង្សាផ្លូវកាយលើកុមារ**[53] **ឬ អំពើរំលោភបំពានផ្លូវកាយ** | ការប្រើប្រាស់កម្លាំង ឬ អំណាចដោយចេតនា ដែលបណ្តាលឱ្យមានគ្រោះថ្នាក់លើរាងកាយជាក់ស្តែង ឬ មានសក្តានុពលក្នុងការបង្កគ្រោះថ្នាក់លើរាងកាយ។ ឧទាហរណ៍រួមមាន ៖ ការវាយនឹងដៃ ឬ វត្ថុអ្វីមួយ ការទះកំផ្លៀង ការគ្រវែង ការរលាក់ ការក្តិច ការបោចសក់ ការញឹងត្រចៀក ការវាយនឹងរំពាត់ ការវាយនឹងខ្សែតី ការខាំ ការច្របាច់ក ការខ្ទាចនឹងក្រចក ការធ្វើឱ្យរលាកដោយចេតនា ការដុត ការធ្វើឱ្យស្លាក់ ការព្យាយាមធ្វើឱ្យលង់ទឹក ការបំពុល ការបង្ខំឱ្យទទួលទាន ការធ្វើឱ្យថប់ដង្ហើម ឬ ការប្រើប្រាស់ ឬ ការគំរាមប្រើប្រាស់អាវុធ ដូចជាកាំបិត ឬ អាវុធដទៃទៀត។ នៅក្នុងករណីជាច្រើន អំពើហិង្សាលើកុមារ អាចត្រូវបានប្រើប្រាស់ក្នុងលក្ខណៈជាទម្រង់មួយនៃការដាក់ទណ្ឌកម្ម។ |
| **ប្រកាស** | លិខិតបទដ្ឋានគតិយុត្តិអនុម័តដោយក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់ ឬ អនុក្រឹត្យជាក់លាក់ណាមួយ។ |
| **ការចូលរួមនៅក្នុងសាលារៀន** | ការចូលរួមរបស់កុមារនៅក្នុងសេចក្តីសម្រេច និង វិធានរបស់សាលារៀន សកម្មភាពសាលារៀន ព្រឹត្តិការណ៍របស់សាលារៀន និង ការយល់ឃើញ វិជ្ជមានអំពីការចូលរួមនៅក្នុងសាលារៀន។ |
| **អ្នកផ្តល់សេវា** | ស្ថាប័នរដ្ឋាភិបាល ឬ អង្គការមនុស្សធម៌ដែលផ្តល់សេវាមួយដើម្បីលើកកម្ពស់សុខុមាលភាពមនុស្ស ដូចជាសេវាការពារកុមារ ការផ្តល់ប្រឹក្សា ឬ ការថែទាំសុខភាព ជាពិសេសសម្រាប់កុមារ និង មនុស្សពេញវ័យដែលបាត់បង់ប្រយោជន៍។ |

52 WeProtect Global Alliance, Our Strategy to end the Child Sexual Exploitation of children Online, 2016.
53 WHO website; Fulu E., National Survey on Women's Health and Life Experiences, 2015.

| | |
|---|---|
| **អំពើហិង្សាផ្លូវភេទលើកុមារ[54] ឬ អំពើរំលោភបំពានផ្លូវភេទ អំពើប្រទូសកេរ្តិ៍ភេទកុមារ** | រាល់សកម្មភាពផ្លូវភេទ ឬ ការប៉ុនប៉ងទទួលបានសកម្មភាពផ្លូវភេទ ដែលប្រព្រឹត្តទៅលើកុមារដោយគ្មានការយល់ព្រម ឬ ការយល់ពីពួកគេ មិនចំពោះថា កុមារដឹង ឬ មិនដឹងអំពីអ្វីដែលកំពុងកើតឡើងឡើយ ដែលសកម្មភាពនេះប្រព្រឹត្តដោយបុគ្គលណាមួយ ឬបុគ្គលមួយក្រុម មិនចំពោះថា មានទំនាក់ទំនងដូចម្ដេចជាមួយជនរងគ្រោះឡើយ។<br><br>អំពើហិង្សាផ្លូវភេទ គ្របដណ្ដប់ទៅលើបទល្មើសមួយចំនួន ដែលរួមមានជាអាទិ៍ សកម្មភាពផ្លូវភេទគ្មានការព្រមព្រៀងដែលបានសម្រេច (ដូចជា ការរំលោភតាមមាត់ តាមទ្វារមាស ឬ តាមរន្ធគូទ ការរួមភេទក្រោមសម្ពាធ) ការប៉ុនប៉ងប្រព្រឹត្តសកម្មភាពផ្លូវភេទគ្មានការព្រមព្រៀង ការប៉ះពាល់ផ្លូវភេទដោយរំលោភបំពាន (ដូចជាការប៉ះពាល់ដែលគេមិនចង់ឱ្យប៉ះ) និង ការរំលោភបំពានផ្លូវភេទដោយគ្មានការប៉ះពាល់ (ឧ. ការគំរាមប្រព្រឹត្តហិង្សាផ្លូវភេទ ការបង្ហាញកេរ្តិ៍ភេទ ការបៀតបៀនផ្លូវភេទដោយពាក្យសម្ដី)។ វាក៏រាប់បញ្ចូលផងដែរនូវការលួងលោម ឬ ការបង្ខិតបង្ខំកុមារម្នាក់ឱ្យចូលរួមនៅក្នុងសកម្មភាពផ្លូវភេទណាមួយដែលខុសច្បាប់ ឬ បង្កគ្រោះថ្នាក់ដល់ចិត្តសាស្ត្ររបស់កុមារ ការប្រើប្រាស់កេងប្រវ័ញ្ចកុមារ នៅក្នុងពេស្យាកម្ម ឬ ការអនុវត្តផ្លូវភេទដទៃទៀតដែលខុសច្បាប់ និង ការប្រើប្រាស់កេងប្រវ័ញ្ចកុមារនៅក្នុងការសម្ដែងរូបភាព និង សម្ភារៈអាសអាភាស។ វាក៏អាចរាប់បញ្ចូលផងដែរនូវការធ្វើឱ្យកុមារចូលរួមមើល ឬ ស្ថិតនៅក្នុងការផលិតរូបភាពផ្លូវភេទ ការមើលសកម្មភាពផ្លូវភេទ ការលើកទឹកចិត្តកុមារឱ្យប្រព្រឹត្តក្នុងលក្ខណៈផ្លូវភេទដែលមិនសមស្រប ការផ្ដល់មតិយោបល់ ឬ ការរីកចម្រើនខាងផ្លូវភេទដែលគេមិនចង់បាន ឬ ការរៀបចំត្រៀមលក្ខណៈកុមារសម្រាប់ការរំលោភបំពាន។ អំពើហិង្សាផ្លូវភេទអាចរាប់បញ្ចូលអំពើហិង្សាដែលប្រព្រឹត្តទៅលើកុមារី និង កុមារា ដោយមនុស្សពេញវ័យជាបុរស និង ស្ត្រី និង អំពើហិង្សាដែលប្រព្រឹត្តទៅលើកុមារដោយកុមារដទៃទៀត។ |
| **ទ្រឹស្ដីនៃការផ្លាស់ប្ដូរ** (ToC) | ការពន្យល់ដែលមានការបែងចែករចនាសម្ព័ន្ធអំពីរបៀបដែលសកម្មភាព ឬ អន្តរាគមន៍ជាក់លាក់ត្រូវបានគេយល់ថានឹងបង្កើតឱ្យមាននូវកម្រងលទ្ធផលមួយចំនួន ដែលនឹងរួមចំណែកដល់ការសម្រេចបាននូវផលប៉ះពាល់ចុងក្រោយដែលគេចង់បាន (ក្នុងករណីនេះ គឺការកាត់បន្ថយ ឬការលុបបំបាត់អំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា)។ |
| **ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ** (**សូមមើលផងដែរអំពីពលកម្មកុមារ**) | រាល់គ្រប់ទម្រង់ទាំងអស់នៃទាសភាព ឬ ការអនុវត្តស្រដៀងគ្នានឹង ទាសភាព ការប្រើប្រាស់ ការធ្វើសញ្ជារកម្ម ឬ ការផ្ដល់កុមារសម្រាប់គោលបំណងពេស្យាកម្ម ការផលិតរូបភាពអាសអាភាស ឬ សម្រាប់គោលបំណងរូបភាពអាសអាភាស ការប្រើប្រាស់ ការធ្វើសញ្ជារកម្ម ឬ ការផ្ដល់កុមារសម្រាប់សកម្មភាពខុសច្បាប់[55]។ |

54 WHO website; Fulu E., National Survey on Women's Health and Life Experiences, 2015.
55 ILO, Worst Forms of Child Labour Convention, 1999. Ibid

# ១០. ឯកសារយោង


1. Aberdein, C., & Zimmerman, C. (2015). Access to Mental Health and Psychosocial Services in Cambodia by Survivors of Trafficking and Exploitation: A Qualitative Study. International Journal of Mental Health Systems, 9(1), 16. Retrieved from: http://doi.org/10.1186/s13033-015-0008-8

2. Amnesty International. (2010). Breaking the Silence: Sexual Violence in Cambodia. Amnesty International Publications. Retrieved from: http://www.aidsdatahub.org/sites/default/files/documents/Breaking_the_Silence_Cambodia.pdf

3. Astbury, J., & Walji, F. (2013). Triple Jeopardy : Gender - Based Violence and Human Rights Violations Experienced by Women with Disabilities in Cambodia, AusAID Research Working Paper 1, pg. 1–34. Retrieved from: https://dfat.gov.au/about-us/publications/Documents/triple-jeopardy-working-paper.pdf

4. Astbury, J., & Walji, F. (2014). The Prevalence and Psychological Costs of Household Violence by Family Members Against Women with Disabilities in Cambodia. Journal of Interpers Violence, 29(17), pg. 3127–3149. Retrieved from: http://doi.org/10.1177/0886260514534528

5. Cambodian Center for Human Rights (CCHR). (2010). Coming Out in the Kingdom: Lesbian, Gay, Bisexual and Transgender People in Cambodia. Phnom Penh, Cambodia. Retrieved from: http://www.cchrcambodia.org/admin/media/report/report/english/2010-12-09%20COMING%20OUT%20IN%20THE%20KINGDOM%20LESBIAN,%20GAY,%20BISEXUAL%20AND%20TRANSGENDER%20PEOPLE%20IN%20CAMBODIA_EN%20.pdf

6. Cambodian Center for Human Rights (CCHR). (2012). Rainbow Khmer: From Prejudice to Pride. Phnom Penh, Cambodia. Retrieved from: http://www.cchrcambodia.org/admin/media/report/report/english/2012_12_31_CCHR_LGBT_Report_Rainbow_Khmer_en.pdf

7. Coram Children's Legal Center, Findings from a Systematic Literature Review Analysis of Existing Datasets on Violence Against Children in Cambodia. 2016. Unpublished Manuscript.

8. Davy, D. (2014). Understanding the Complexities of Responding to Child Sex Trafficking in Thailand and Cambodia. International Journal of Sociology and Social Policy, 34(11/12), pg. 793–816. Retrieved from: http://doi.org/10.1108/IJSSP-10-2013-0103

9. Derks, A., Henke, R., & Vanna, L. Y. (2006). Review of a Decade of Research On Trafficking in Persons, Cambodia. Review Literature And Arts Of The Americas. Retried from: http://www.no-trafficking.org/content/pdf/taf%20research%20review%20report%202006.pdf

10. Fang, X. (2014). The Economic Burden of Health Consequences of Violence Against Children in Cambodia - Preliminary Results. UNICEF. Retrieved from: http://www.unicef.org/cambodia/Economic_burden_of_heath_consequences_of_violence_against_children.pdf

11. Friends International. (2011). Cambodian Street Children Profile. Retrieved from: http://www.friends-international.org/resources/research/Street_Children_Profile_2011.pdf

12. Fulu, E. (2015). National Survey on Women's Health and Life Experiences in Cambodia: Report. World Health Organisation, pg. 1–179. Retrieved from: http://www.unwomen.org/~/media/field%20office%20eseasia/docs/publications/2015/11/national%20survey%20on%20womens%20health%20and%20life%20experiences%20in%20cambodia.pdf?v=1&d=20151120T040512

13. Fulu, E., Jewkes, R., Roselli, T., & Garcia-Moreno, C. (2013). Prevalence of and Factors Associated with Male Perpetration of Intimate Partner Violence: Findings from the UN Multi-country Cross-sectional Study on Men and Violence in Asia and the Pacific. The Lancet Global Health, 1(4), pg187–207. Retrieved from: http://doi.org/10.1016/S2214-109X(13)70074-3

14. Glaser D. (1993). Emotional Abuse. In Clininical Paediatrics: Child Abuse (eds. C. Hobbs and J. Wynne) Bailliere's Clinical Paediatrics, 1(1), pg. 251–267. Bailliere Tindall, London.

15. Hackett, S. (2014). Children and Young People with Harmful Sexual Behaviours. London: Research in Practice.

16. Hackett, S., Holmes, D. and Branigan, P. (2016). Operational Framework for Children and Young People Displaying Harmful Sexual Behaviours. London, NSPCC. Retrieved from: https://www.nspcc.org.uk/globalassets/documents/publications/harmful-sexual-behaviour-framework.pdf

17. Hamilton, C. (2015). Legal Protection from Violence: Analysis of Domestic Laws Related to Violence Against Children in ASEAN Member States. Retrieved from: http://www.unicef.org/eapro/ASEAN_VAC(1).pdf

18. Harvard University Center for the Developing Child. In Brief: The Science of Neglect. Retrieved from: http://46y5eh11fhgw3ve3ytpwxt9r.wpengine.netdna-cdn.com/wp-content/uploads/2015/05/InBrief-The-Science-of-Neglect-3.pdfAccessed: August 3, 2016.

19. Hilton, A. (2008). I Thought it Could Never Happen to Boys. Hagar & World Vision. Retrieved from: http://www.first-step-cambodia.org/fileadmin/user_upload/SPEAKING_TRUTH_edited_final_20-3-08.pdf

20. International Labour Organisation. (2007). Towards the Elimination of the Worst Forms of Child Labour (TECL). Pretoria, South Africa. 01 March, 2007. Retrieved from: http://www.ilo.org/wcmsp5/groups/public/---ed_mas/---eval/documents/publication/wcms_175626.pdf

21. International Labour Organisation. (1999). Worst Forms of Child Labour Convention, C182, 17 June 1999. Retrieved from: http://www.ilo.org/public/english/standards/relm/ilc/ilc87/com-chic.htm

22. International Labour Organisation. Migration and Child Labor. http://www.ilo.org/ipec/areas/Migration_and_CL/lang--en/index.htm. Accessed: 3 August, 2016.

23. International Labour Organization and National Institute of Statistics (NIS), Cambodia Labour Force and Child Labour Survey 2012.. Retrieved from: http://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/---sro-bangkok/documents/publication/wcms_230721.pdf

24. Iwaniec, D. (1995). The Emotionally Abused and Neglected Child: Identification, Assessment and Intervention: A Practice Handbook. Wiley, USA.

25. Jones L., et al. (2012). Prevalence and Risk of Violence Against Children with Disabilities: A Systematic Review and Meta-analysis of Observational Studies. Lancet. 380:9. Retrieved from: http://www.who.int/disabilities/publications/violence_children_lancet.pdf

26. Krug, E. (2002). World Report on Violence and Health. World Health Organisation. Retrieved from: http://doi.org/10.1136/ip.9.1.93

27. Cambodian League for the Promotion and Defense of Human Rights (LICADHO). (2015). Mothers Behind Bars: The Impact of Detention on Women and their Children. Retrieved from: http://www.licadho-cambodia.org/reports.php?perm=206

28. Ministry of Education, Youth and Sport. (2010). Most at Risk Young People Survey Cambodia. Retrieved from: http://hivhealthclearinghouse.unesco.org/sites/default/files/resources/bangkok_maryp_2010_report_eng.pdf

29. Ministry of Education, Youth and Sport and UNICEF. (2016). Out-of-School Children Report for Cambodia.

30. Ministry of Interior. (2015). National Plan of Action of the National Committee for Counter Trafficking 2014-2018. Retrieved from: http://ncct.gov.kh/docs/ncct-action-plan-2014-2018-en.pdf

31. Ministry of Social Affairs, Veterans and Youth Rehabilitation. (2014). Cambodia Gender Analysis: Chapter 9. Vulnerable groups of Women and Girls.

32. Ministry of Social Affairs, Veterans and Youth Rehabilitation. (2015). Preliminary Data Compilation and Findings: Mapping of Residential Care Institutions. Retrieved from: http://www.unicef.org/cambodia/MAPPING_REPORT_5_provinces_ENG.pdf

33. Ministry of Women's Affairs. National Action Plan to Prevent Violence Against Women, 2014-2018. Retrieved from: http://cambodia.unfpa.org/sites/asiapacific/files/pub-pdf/NAPVAW2014-2018%28Eng%29.pdf http://cambodia.unfpa.org/publications/national-action-plan-prevent-violence-against-women-2014-2018 Accessed 21 June 2016

34. Ministry of Women's Affairs. (2014). Violence Against Women and Girls. Policy Brief 7. Received from: http://doi.org/10.1017/CBO9781107415324.004

35. National Institute of Public Health and National Institute of Statistics. (2006). Cambodia Demographic and Health Survey 2005, pg. 1–516. Retrieved from: https://dhsprogram.com/pubs/pdf/FR185/FR185[April-27-2011].pdf

36. National Institute of Statistics and the Ministry of Health. (2015). Cambodian Demographic and Health Survey 2014. Retrieved from: https://dhsprogram.com/pubs/pdf/FR312/FR312.pdf

37. National Institute of Statistics and Columbia University. National Estimation of Homeless Children in Cambodia. 2015, Cambodia.

38. National Institute of Statistics & Directorate General for Health. (2011). Cambodia Demographic and Health Survey 2010, pg. 393. Retrieved from: https://dhsprogram.com/pubs/pdf/FR249/FR249.pdf

39. National Multi-sectoral Orphans and Vulnerable Children Task Force. Orphans, Children Affected by HIV, and other Vulnerable Children in Cambodia: A Situation and Response Assessment, 2007. Retrieved from: http://www.unicef.org/eapro/OVC_Situation_Assess_June_2008.pdf

40. Nguyen, Lyma and Sperfeldt, Christoph. A Boat Without Anchors: A Report on the Legal Status of Ethnic Vietnamese Minority Populations in Cambodia under Domestic and International Laws Governing Nationality and Statelessness. Jesuit Refugee Services, Cambodia. 2012. Retrieved from: https://www.jrsusa.org/assets/Publications/File/BoatWithoutAnchorsOnline.pdf

41. Pinheiro, Paulo Sérgio. World Report on Violence Against Children. Geneva, Switzerland. 2006.

Retrieved from: http://www.unicef.org/violencestudy/I.%20World%20Report%20on%20 Violence%20against%20Children.pdf

42. Reimer, J.K. “At What Price, Honour?” Research into Domestic Trafficking of Vietnamese (girl) Children for Sexual Exploitation, From Urban Slums to Phnom Penh. Chab Dai. Phnom Penh, Cambodia, 2006. Retrieved from: http://www.no-trafficking.org/content/pdf/pages%20 1-40%20from%20at%20what%20price,%20honour.pdf

43. Royal Government of Cambodia. National Social Protection Strategy for the Poor and Vulnerable 2011-2015. Retrieved from: http://www.unicef.org/cambodia/National_Social_ Protection_Strategy_for_the_Poor_and_Vulnerable_Eng.pdf

44. Special Representative of the Secretary General on Violence Against Children. Toward a World Free from Violence: Global Survey on Violence Against Children, pg. 19. 2013. Retrieved from: http://srsg.violenceagainstchildren.org/sites/default/files/documents/docs/Toward%20a%20 World%20Free%20from%20Violence.pdf

45. Steering Committee on Violence Against Children. (2013). Findings from Cambodia's Violence Against Children Survey 2013. Retrieved from: http://www.unicef.org/cambodia/UNICEF_VAC_ Full_Report_English.pdf

46. Sullivan, P. M. and Knutson J. F. Maltreatment and Disabilities: A Population-based Epidemiological Study. Child Abuse & Neglect, Vol. 24, No 10, pp. 1257-1273.

47. UN Committee on the Rights of the Child (CRC). General comment No. 13 (2011): The Right of the Child to Freedom from all Forms of Violence. United Nations. 2011. Retrieved from: http://www2.ohchr.org/english/bodies/crc/docs/CRC.C.GC.13_en.pdf

48. UN General Assembly. A/61/299: Promotion and Protection of the Rights of the Child. Retrieved from: http://www.unicef.org/violencestudy/reports/SG_violencestudy_en.pd,f Accessed 21 June2016.

49. UN General Assembly. A/61/299: Report of the Independent Expert for the United Nations Study on Violence Against Children. 29 August 2006. Retrieved from: http://www.unicef.org/ violencestudy/reports/SG_violencestudy_en.pdf. Accessed 09.August2016.

50. UN General Assembly. A/70/1: Transforming Our World: the 2030 Agenda for Sustainable Development. 2015. Retrieved from: http://www.unfpa.org/sites/default/files/resource-pdf/ Resolution_A_RES_70_1_EN.pdf Accessed 09 August 2016

51. UNAIDS. (2013) Methodology – Understanding the HIV estimates. UNAIDS: Geneva, Switzerland. Retrieved from: http://www.unaids.org/sites/default/files/media_asset/UNAIDS_ methodology_HIVestimates_en.pdf

52. UNICEF. (2015). Economic Burden of the Health Consequences of Violence Against Children in Cambodia. Retrieved from: http://www.unicef.org/cambodia/Economic_burden_of_heath_ consequences_of_violence_against_children.pdf

53. UNICEF. Ending Violence Against Children: Six Strategies for Action. Retrieved from: http://www.unicef.org/publications/files/Ending_Violence_Against_Children_Six_strategies_for_ action_EN_9_Oct_2014.pdf. Accessed 21June 2016.

54. UNICEF. Revised Supplementary Programme Note on the Theory of Change for the UNICEF Strategic Plan, 2014-2017. Retrieved from: http://www.unicef.org/strategicplan/files/2014-CRP_14-Theory_of_Change-7May14-EN.pdf. Accessed 21 June 2016.

55. UNICEF. (2009). An Analysis of the Situation of Children & Women in Cambodia. Retrieved from: http://www.unicef.org/sitan/files/Sitan_UNICEF_Cambodia_March_2010.pdf

56. UNICEF. UNICEF Cambodia Country Programme 2016-2018: Child Protection. Retrieved from: http://www.unicef.org/cambodia/Country_kit_Child_Protection_Final_A4.pdf. Accessed 21 June 2016

57. Vicente S. Salas & Srun Sorn. (2013). An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities in Some Areas of Cambodia and Their Ways of Coping. Phnom Penh: SPCUCARDPress. Retrieved from: http://www.aidsdatahub.org/sites/default/files/publication/Cambodia_Journal_GLBT_for_publication.pdf

58. WePROTECT Global Alliance. (2016). Our Strategy to End the Child Sexual Exploitation of Children Online. Retrieved from: http://www.weprotect.org/

59. World Health Organization, US Centres for Disease Control and Prevention, Ministry of Health, Ministry of Education, Youth and Sports. (2013). Global School-based Student Health Survey in Cambodia.


## ប្រភពដទៃទៀតដែលបានដកស្រង់


- Miles, G., & Blanch, H. (2011). What about Boys? An Initial Exploration of Sexually Exploited Boys in Cambodia, 9(September).
- Mith Samlanh. (2004). 10 Years - Mith Samlanh: A Program for Street Children, Their Families and Their Community. Phnom Penh, Cambodia.
- UNICEF. (2016). UNICEF Cambodia Child Protection Adolescent Report. April 2016.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១ ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង គោលដៅពាក់ព័ន្ធនឹងកិច្ចការពារកុមារ

| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង គោលដៅពាក់ព័ន្ធនឹងកិច្ចការពារកុមារ | |
|---|---|
| 4 ការអប់រំប្រកបដោយគុណភាព | **គោលដៅទី៤ ៖ ការអប់រំប្រកបដោយគុណភាព**<br>ធានាឱ្យមានការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និង សមធម៌ ព្រមទាំងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ជនគ្រប់រូប |
| | ៤.ក. កសាង និង កែលម្អកន្លែងផ្តល់ការអប់រំ ដែលគិតគូរចំពោះកុមារ ពិការភាព និងយេនឌ័រ និងផ្តល់បរិយាកាសរៀនសូត្រដែលមានសុវត្ថិភាព អហិង្សា ប្រកបដោយបរិយាប័ន្ន និង មានប្រសិទ្ធភាពសម្រាប់ជនគ្រប់រូប |
| 5 សមភាពយេនឌ័រ | **គោលដៅទី៥ ៖ សមភាពយេនឌ័រ**<br>សម្រេចឱ្យបាននូវសមភាពយេនឌ័រ និង ផ្តល់អំណាចដល់ស្ត្រី និងកុមារីគ្រប់រូប |
| | ៥.១. បញ្ចប់រាល់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនិងកុមារីគ្រប់រូបនៅគ្រប់កន្លែងទាំងអស់<br>៥.២. លុបបំបាត់រាល់គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងកុមារីគ្រប់រូប នៅតាមកន្លែងសាធារណៈ និងឯកជន រាប់បញ្ចូល ការជួញដូរ និង ការកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងការកេងប្រវ័ញ្ចដទៃទៀត<br>៥.៣. លុបបំបាត់រាល់ការអនុវត្តទាំងអស់ដែលមានគ្រោះថ្នាក់ ដូចជាអាពាហ៍ពិពាហ៍ក្នុងវ័យកុមារ អាពាហ៍ពិពាហ៍នៅមុនគ្រប់អាយុ និង ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងការកាត់ប្រដាប់ភេទក្មេងស្រី |
| 8 ការងារសមរម្យ និង កំណើនសេដ្ឋកិច្ច | **គោលដៅទី៨ ៖ ការងារសមរម្យ និង កំណើនសេដ្ឋកិច្ច**<br>លើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ននិងនិរន្តរភាព និង មុខរបរពេញលេញប្រកបដោយផលិតភាពខ្ពស់ និង ការងារសមរម្យសម្រាប់មនុស្សគ្រប់រូប |
| | ៨.៧. ចាត់វិធានការភ្លាមៗ និង ប្រកបដោយប្រសិទ្ធភាព ដើម្បីលុបបំបាត់ពលកម្មដោយបង្ខំ បញ្ចប់ទាសភាពបែបទំនើប និង អំពើជួញដូរមនុស្ស ព្រមទាំងធានាហាមឃាត់ និង លុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ រាប់បញ្ចូលការជ្រើសរើស និង ការប្រើប្រាស់យោធាជាកុមារ និង បញ្ចប់គ្រប់ទម្រង់ទាំងអស់នៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។ |

# ឧបសម្ព័ន្ធ ២ ៖ គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិស្តីពី សិទ្ធិកុមារ ក្នុងប្រទេសកម្ពុជា

**អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារសិទ្ធិកុមារ ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័ន**

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (១៩៩២)
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ
- សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (១៩៩២)**

អនុសញ្ញាស្តីពីសិទ្ធិកុមារ និង រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូប ដូចខាងក្រោម ៖

- មាត្រា២ ៖ សិទ្ធិក្នុងការមិនទទួលរងការរើសអើស
- មាត្រា៣ ៖ ឧត្តមប្រយោជន៍របស់កុមារ
- មាត្រា១៩ ៖ សិទ្ធិក្នុងការទទួលបានកិច្ចការពារពីគ្រប់ទម្រង់នៃអំពើហិង្សាផ្លូវកាយ ឬ ផ្លូវចិត្ត អំពើរំលោភបំពាន ឬ ការមិនអើពើ ឬ ការកេងប្រវ័ញ្ច
- មាត្រា៣២ ៖ សិទ្ធិក្នុងការទទួលបានកិច្ចការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច
- មាត្រា៣៣ ៖ សិទ្ធិក្នុងការទទួលបានកិច្ចការពារពីការប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់
- មាត្រា៣៤ ៖ សិទ្ធិក្នុងការទទួលបានកិច្ចការពារពីគ្រប់ទម្រង់ទាំងអស់នៃអំពើកេងប្រវ័ញ្ច និង អំពើរំលោភបំពានផ្លូវភេទ
- មាត្រា៣៥ ៖ សិទ្ធិក្នុងការទទួលបានកិច្ចការពារពីការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារ
- មាត្រា៣៦ ៖ សិទ្ធិក្នុងការទទួលបានកិច្ចការពារពីគ្រប់ទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ច
- មាត្រា៣៧ ៖ សិទ្ធិក្នុងការទទួលបានកិច្ចការពារពីការធ្វើទារុណកម្ម ការប្រព្រឹត្តិឃោរឃៅ ឬ អមនុស្សធម៌ ទោសប្រហារជីវិត និង ការដកហូតសេរីភាពដោយខុសច្បាប់
- មាត្រា៣៩ ៖ សិទ្ធិក្នុងការទទួលបានភាពសះស្បើយឡើងវិញផ្នែកផ្លូវកាយ និង ផ្លូវចិត្ត និង សមាហរណកម្មក្នុងសង្គម
- មាត្រា៤០ ៖ សិទ្ធិរបស់កុមារជាប់ចោទពីបទបំពានច្បាប់ព្រហ្មទណ្ឌ និង វិធានការសម្រាប់ដោះស្រាយ នៅក្រៅនីតិវិធីតុលាការ

**ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ**

- ពិធីសារបន្ថែមស្តីពីការលក់កុមារ ពេស្យាចារកុមារ និង រូបភាពអាសអាភាសកុមារ
- ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ

**សិទ្ធិកុមារនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

- មាត្រា៣១ ៖ រដ្ឋទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងលក្ខន្តិកអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស រាប់បញ្ចូលកតិកាសញ្ញា និង អនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និង សិទ្ធិកុមារ។
- មាត្រា៤៧ ៖ កំណត់អំពីភារកិច្ចរបស់ឪពុកម្តាយក្នុងការថែទាំ និង អប់រំកូនឱ្យក្លាយជាពលរដ្ឋល្អ និង កំណត់អំពីភារកិច្ចដូចគ្នាសម្រាប់កូនដែលត្រូវមើលថែឪពុកម្តាយរបស់ខ្លួន នៅពេលដែលពួកគេមានវ័យចំណាស់។
- មាត្រា៤៨ ៖ តម្រូវឱ្យរដ្ឋការពារសិទ្ធិកុមារ ដូចមានចែងនៅក្នុង "អនុសញ្ញាស្តីពីសិទ្ធិកុមារ" ជាពិសេស សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានកិច្ចការពារនៅពេលមានសង្គ្រាម និង កិច្ចការពារពីអំពើកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬ អំពើកេងប្រវ័ញ្ចផ្លូវភេទ។ តម្រូវឱ្យរដ្ឋការពារកុមារពីសកម្មភាពដែលរារាំងឱកាសទទួលបានការអប់រំ សុខភាព និង សុខុមាលភាពរបស់ពួកគេ។
- មាត្រា៧៣ ៖ តម្រូវឱ្យរដ្ឋផ្តល់ការពិចារណាពេញលេញចំពោះកុមារ និងម្តាយគ្រប់រូប ព្រមទាំងបង្កើតឱ្យមានទារកដ្ឋាន និង ផ្តល់ការគាំទ្រដល់ស្ត្រី និងកុមារដែលពុំទទួលបានការទំនុកបម្រុងគ្រប់គ្រាន់។

**ច្បាប់ និងគោលនយោបាយជាតិស្តីពីសិទ្ធិកុមារ**

- គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (២០០០-២០១៥)
- ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (២០១៦-២០១៨)
- យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (២០១១-២០១៥)
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (២០១៦)

**អំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និង ការមិនអើពើ**

- ក្រមព្រហ្មទណ្ឌ (២០០៩) ៖ បទល្មើសប្រឆាំងនឹងអនីតិជន
- ច្បាប់ស្តីពី ទេសចរណ៍ (២០០៩)
- ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ (២០០៨)
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (២០០៥)
- ច្បាប់ស្តីពីការរំលូតកូន (១៩៩៧)
- ច្បាប់ការងារ (១៩៩៧)
- ផែនការសកម្មភាពជាតិស្តីពី ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០០៨-២០១២)
- គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព (២០១០)
- ផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨)
- ផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជំហានទី២ (២០១៤-២០១៨)
- អនុក្រឹត្យស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន (២០១១)
- អនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ អំពើរត់ពន្ធ និង ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (២០០៩)
- អនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន នៃក្រសួងមហាផ្ទៃ (២០០២)
- អនុក្រឹត្យស្តីពី ការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និង វីដេអូ (២០០០)
- អនុក្រឹត្យស្តីពី ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស (១៩៩៥)
- គោលនយោបាយ និង បទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស (២០០៩)

**អប់រំ និងសុខុមាលភាព**

- ច្បាប់ស្តីពី កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ (២០០៩)
- ច្បាប់ស្តីពី ការអប់រំ (២០០៧)
- ច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក (២០០៧)
- ច្បាប់ស្តីពី ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (២០០២)
- អនុក្រឹត្យស្តីពី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន (២០០៨)
- គោលនយោបាយជាតិស្តីពី ការគាំពារ និងអភិវឌ្ឍន៍កុមារតូច (២០១០)
- បទដ្ឋាន និងគោលការណ៍ណែនាំសម្រាប់ការថែទាំ ការគាំទ្រ និងការការពារចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ (២០១១)
- គោលនយោបាយស្តីពី ការអប់រំកុមារពិការ (២០០៨)
- គោលនយោបាយស្តីពី សាលាកុមារមេត្រី (២០០៧)
- គោលនយោបាយស្តីពី ការអប់រំបំណិនជីវិត (២០០៦)
- សេចក្តីណែនាំស្តីពី ការកំណត់ទណ្ឌកម្មលើសិស្ស (២០០៦)
- គោលនយោបាយស្តីពីកិច្ចការពារកុមារក្នុងសាលារៀន (២០១៦)
- សៀវភៅស្តីពីការថែទាំសុខភាពកុមាររងគ្រោះដោយសារអំពើហិង្សា ឬអំពើរំលោភបំពានផ្លូវភេទ (២០១៧)

### គ្រួសារ និង ការថែទាំជំនួស

- ច្បាប់ស្តីពី ស្មុំកូនអន្តរប្រទេស (២០០៩)
- ក្រមរដ្ឋប្បវេណី ៖ អាយុអប្បបរមានៃការរៀបអាពាហ៍ពិពាហ៍កំណត់ត្រឹម១៨ឆ្នាំ
- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ (២០០៦)
- សារាចរណែនាំស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលស្នាក់នៅមណ្ឌលរដ្ឋ និង អង្គការមិនមែនរដ្ឋាភិបាល (២០០៧)
- សេចក្តីពន្យល់ស្តីពីស្មុំកូនក្នុងប្រទេស (២០១៦)
- ផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន ៣០ ភាគរយ ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាពពីឆ្នាំ ២០១៦ ទៅឆ្នាំ ២០១៨ (២០១៦)
- អនុក្រឹត្យលេខ ១១៩ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (២០១៥)

### កុមារដែលពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌

- ច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន (២០១១)
- ច្បាប់ស្តីពី ពន្ធនាគារ (២០១១)
- ក្រមព្រហ្មទណ្ឌ (២០០៩) ៖ បញ្ញត្តិពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់
- ក្រមនីតិវិធីព្រហ្មទណ្ឌ (២០០៧)
- ក្រមនីតិវិធីរដ្ឋប្បវេណី (២០០៦)
- ច្បាប់ស្តីពី យុត្តិធម៌អនីតិជន (២០១៦)
- អនុក្រឹត្យស្តីពី ការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (២០១០)
- ផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ “ភូមិ ឃុំ មានសុវត្ថិភាព” (២០១០)

# ឧបសម្ព័ន្ធ ៣ ៖ ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា

| ផលប៉ះពាល់កម្រិតខ្ពស់ | អនុវត្តន៍បានពេញលេញសិទ្ធិទទួលបានកិច្ចការពារ នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ | | | សម្រេចបានគោលដៅអភិវឌ្ឍន៍នានា (ឧ. SDGs) អាស្រ័យដោយឧបសគ្គចម្បងៗ ដែលរាំងស្ទះដល់ជោគជ័យនៃគោលដៅអភិវឌ្ឍន៍ទាំងនេះ ត្រូវបានលុបបំបាត់ | | | |
|---|---|---|---|---|---|---|---|
| **ផលប៉ះពាល់** | កុមារី និងកុមារា រួចផុតពីគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា និងការគំរាមកំហែងចំពោះអំពើហិង្សា | | | | | | |
| **លទ្ធផលរយៈពេលវែង** | កិច្ចគាំពារសង្គមមាន ភាពរីកចម្រើនក្នុង កម្រិតមួយ ដែលការ ប្រឈមរបស់ កុមារគ្រប់រូប (និងគ្រួសាររបស់ពួកគេ) ចំពោះ អំពើរំលោភបំពាន ការកេងប្រវ័ញ្ច និង ការជួញដូរ ត្រូវបានកាត់បន្ថយ ឬ លុបបំបាត់ | កុមារមានលទ្ធភាព ទទួលបានការអប់រំកម្រិតបឋមសិក្សា និងអនុវិទ្យាល័យដោយឥតគិតថ្លៃនៅឯសាលាកុមារមេត្រី និងមានឱកាសស្មើភាពគ្នាក្នុងការទទួលបានការអប់រំថ្នាក់ឧត្តមសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលបច្ចេកទេស។ | គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាលើកុមារ ត្រូវបានចាត់ទុកថា មិនអាចទទួលយកបាន ទោះនៅក្នុងបរិបទ និងស្ថានភាពណាក៏ដោយ។ គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាលើកុមារ ត្រូវបានផ្តន្ទាទោស និងប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិតទាំងអស់។ | ទំនាក់ទំនងអំណាច និងការគ្រប់គ្រងទៅលើធនធាន មានតុល្យភាពយេនឌ័រ។ កុមារី និងកុមារាអនុវត្ត សកម្មភាព និង ស្វ័យភាពលើខ្លួន និងជីវិតរស់នៅ របស់ពួកគេ។ | មន្ត្រីរាជការ គ្រូបង្រៀន ឪពុកម្តាយ កុមារ និង អ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត បានដឹង និងយល់អំពីសិទ្ធិកុមារដែលត្រូវទទួលបានកិច្ចការពារពីអំពើហិង្សា។ កុមាររងគ្រោះនៃអំពើរំលោភ បំពាន អាចទទួលបានយុត្តិធម៌ ប្រកបដោយសុវត្ថិភាព ដោយគ្មានការរើសអើង ឬ ភ័យខ្លាចចំពោះការសងសឹក។ | ជនរងគ្រោះនៃ អំពើរំលោភបំពាន ទទួលបានកិច្ចគាំទ្រផ្នែកច្បាប់គ្រប់គ្រាន់ សេវាស្តារនីតិសម្បទា និងការបណ្តុះបណ្តាលជំនាញបំណិនជីវិត។ "វដ្តនៃអំពើហិង្សា" ត្រូវបានទម្លាយ។ | មានប្រព័ន្ធការពារកុមារមួយ ដែលទទួលបានមូលនិធិ គាំទ្រ និងមានបុគ្គលិកបម្រើការងារគ្រប់គ្រាន់ មានហេដ្ឋារចនាសម្ព័ន្ធសមស្រប (ឧ. មានសមត្ថភាពក្នុងការស៊ើបអង្កេត និង ធ្វើការប៉ាន់ប្រមាណ នៅពេលមានការបញ្ជូនកុមារម្នាក់ដែលជាជនរងគ្រោះនៃអំពើហិង្សា) និង មានជម្រើស នៃការថែទាំជំនួសសមស្រប ស្របតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ |
| **លទ្ធផលបឋម** | កិច្ចគាំពារសង្គម មានភាពរីកចម្រើន ដូច្នេះកុមារ (និងគ្រួសាររបស់ពួកគេ) មិនសូវងាយរងគ្រោះទៅនឹងអំពើរំលោភបំពាន ការកេងប្រវ័ញ្ច និង ការជួញដូរ។ | កុមារមានលទ្ធភាពកាន់តែខ្ពស់ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅកម្រិតមត្តេយ្យ សិក្សា បឋមសិក្សា និង មធ្យមសិក្សាដែលមានសុវត្ថិភាព និងមានលក្ខណៈកុមារមេត្រីព្រមទាំងមានលទ្ធភាពកាន់តែខ្ពស់ក្នុងការទទួលបាន ការអប់រំកម្រិតឧត្តមសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលបច្ចេកទេស។ | កម្មវិធីដែលមានគោលបំណងផ្តោតលើ ការលើកកម្ពស់ការយល់ដឹងអំពីផលវិបាក អវិជ្ជមាននៃការអនុវត្តន៍ វិន័យធ្ងន់ធ្ងរបែបហិង្សា និងការផ្តល់បច្ចេកទេស អនុវត្តវិន័យបែបវិជ្ជមាន ជំនួសវិញ បានជ្រាប ទៅដល់មន្ត្រីរាជការ គ្រូបង្រៀន ឪពុកម្តាយនិងកុមារកាន់តែច្រើន។ | កម្មវិធីដែលមានគោលបំណងផ្តោតលើការលើកកម្ពស់ការយល់ដឹងអំពីសមភាពយេនឌ័រ និង ការមិនរើសអើង បានជ្រាបទៅដល់មន្ត្រីរាជការ គ្រូបង្រៀន ឪពុកម្តាយ និងកុមារកាន់តែច្រើន។ | កម្មវិធីដែលមានគោលបំណងផ្តោតលើការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ដែលហាមឃាត់ចំពោះអំពើហិង្សាលើកុមារ បានជ្រាបទៅដល់មន្ត្រីរាជការ គ្រូបង្រៀន ឪពុកម្តាយ និងកុមារកាន់តែច្រើន។ ការបណ្តុះបណ្តាលអំពីច្បាប់ និងការអនុវត្តន៍ច្បាប់ ត្រូវបានផ្តល់ជូនដល់តួអង្គ ពាក់ព័ន្ធនៅក្នុងវិស័យយុត្តិធម៌ កាន់តែច្រើនឡើង។ ប្រព័ន្ធច្បាប់កាន់តែប្រសើរ ដើម្បីបង្ការ ទទួលស្គាល់ និង ឆ្លើយតបទៅនឹងគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាលើកុមារ។ | មានគោលនយោបាយ ថវិកា និងធនធានមនុស្ស របស់រាជរដ្ឋាភិបាល សម្រាប់ផ្តល់សេវាបង្ការ និង ឆ្លើយតប។ បុគ្គលដែលធ្លាប់ទទួលរងអំពើរំលោភបំពាន មានលទ្ធភាពកាន់តែខ្ពស់ក្នុងការទទួលបាន សេវាព្យាបាលអាការៈបាក់ស្មារតី និងសេវាប្រឹក្សាយោបល់ និង មាននិន្នាការថយចុះចំពោះ ការប្រព្រឹត្តបទល្មើស/ការក្លាយជាជនរងគ្រោះជាថ្មីម្តងទៀត។ | |

**ការសន្និដ្ឋានសំខាន់ៗ**

ការទទួលស្គាល់ជាបន្តបន្ទាប់ពីអ្នកពាក់ព័ន្ធសំខាន់ៗថាកុមារមានសិទ្ធិទទួលបានកិច្ចការពារ ការបន្តវិនិយោគ (ប្រកបដោយអត្ថន័យ) ចំពោះ កិច្ចការពារកុមារ អ្នកពាក់ព័ន្ធសំខាន់ៗ ជ្រើសរើសអនុវត្តអភិក្រម រួមមួយចំពោះ កិច្ចការពារ កុមារ យកចិត្តទុកដាក់ និងខិតខំផ្លាស់ប្តូរទម្លាប់សង្គម។

ការបន្តឆន្ទៈ នយោបាយ មានការសម្របសម្រួល សមត្ថភាព និង ធនធានរដ្ឋាភិបាលនៅ គ្រប់កម្រិតទាំងអស់ ការបន្តបោះជំហាន ឆ្ពោះទៅរកសមភាព យេនឌ័រ និង ការកាត់បន្ថយភាពក្រីក្រ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ឧបសគ្គ/ កត្តារាំងស្ទះ** | ខ្វះកិច្ចគាំទ្រពីម្ចាស់ជំនួយ វិសមភាពសកល លើ ផ្នែករចនាសម្ព័ន្ធ ទម្លាប់ ជុំវិញបញ្ហាបំណុលពីមួយ ជំនាន់ទៅមួយជំនាន់ | ខ្វះគ្រូបង្រៀនដែលមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រាក់បៀវត្សរ៍ទាប ការយល់ឃើញថាការអប់រំ ផ្តល់ផលតបស្នងមកវិញ ក្នុងកម្រិតទាប តម្លៃ កាលានុវត្តភាពខ្ពស់ ដែល ជំរុញកុមារឱ្យចូល ទៅក្នុងទីផ្សារការងារ និង សាលារៀនគ្មានសុវត្ថិភាព | ការប្រឆាំងចំពោះការ សម្របទៅនឹងការអនុវត្ត ចិញ្ចឹមកូន ការបង្រៀន និង ការអនុវត្តវិន័យតាំងពីយូរ លង់មកដែលកើតឡើងជា ទូទៅនៅក្នុងសង្គមទាំង មូល និង ឋានានុក្រមអាយុ | ការប្រឆាំងចំពោះការសម្រប ទៅនឹង ការអនុវត្តដែលរើស អើងផ្អែកយេនឌ័រតាំងពី យូរលង់មកដែលកើតឡើង ជាទូទៅនៅក្នុងសង្គម ទាំងមូល | ខ្វះការជឿទុកចិត្តទៅលើ ប្រព័ន្ធច្បាប់ ការមិនអនុវត្ត តាមច្បាប់ជាតិ ការមិន អនុវត្តច្បាប់ ប្រព័ន្ធច្បាប់ ដែលប្រកួតប្រជែងគ្នា (សាសនា ប្រពៃណី។ល។) ការខកខានក្នុងការយកចិត្ត ទុកដាក់ឱ្យបានដិតដល់ ចំពោះបណ្តឹងរបស់កុមារ ការចង់ដោះស្រាយ បញ្ហានៅក្នុងគ្រួសារ ឬ សហគមន៍ | ខ្វះសេវា ខ្វះសមត្ថភាពក្នុងការផ្គត់ផ្គង់បុគ្គលិកដើម្បី ផ្តល់សេវា ខ្វះបុគ្គលិកសង្គមកិច្ច ខ្វះហេដ្ឋារចនាសម្ព័ន្ធ និងរចនាសម្ព័ន្ធសម្រាប់បន្តផ្តល់ជំនួយ និងការថែទាំ សមស្រប ភាពឯកជន ការសម្ងាត់ និង ភាពថ្លៃថ្នូរ របស់ជនរងគ្រោះ ភាពស្ទាក់ស្ទើរក្នុងចំណោម ជនរងគ្រោះនៃអំពើរំលោភបំពានក្នុងការចេញមុខ ដោយសារតែការមាក់ងាយ និងការយល់ឃើញ អវិជ្ជមានចំពោះគុណភាព ភាពសមស្រប និង តម្លៃនៃសេវាឆ្លើយតប។ | |
| **ការផ្តួចផ្តើម**[56] | អនុវត្តកម្មវិធីដែលមាន គោលបំណងកាត់បន្ថយ ភាពក្រីក្រ និង វិសមភាព (ឧ. កម្មវិធីគាំពារសង្គម អន្តរាគមន៍ដើម្បីលើក កម្ពស់ ជីវភាពរស់នៅ ឱកាសការងារ។ល។) | អនុវត្តគំនិតផ្តួចផ្តើមនានា ដែលបង្កើនវត្តមាននៅ សាលារៀន (ចូលរៀន) កាត់បន្ថយថ្លៃសិក្សា (ក្រៅផ្លូវការ) បង្កើនសុវត្ថិ ភាពនៅសាលារៀន និង កែលម្អគុណភាពអប់រំ លើកកម្ពស់ការយល់ដឹង អំពីអត្ថប្រយោជន៍នៃការ អប់រំ។ | អនុវត្តកម្មវិធីដែលមានគោល បំណងផ្លាស់ប្តូរទម្លាប់សង្គម ដែលគាំទ្រការអនុវត្តន៍ វិន័យ បែបអហិង្សា និង លើកកម្ពស់ទំនាក់ទំនងល្អ ដែលអំណោយផលដល់ ការលូតលាស់ របស់កុមារ ព្រមទាំងពង្រឹងបន្ថែមទៅ លើទម្លាប់នៃការប្រព្រឹត្ត អហិង្សាដែលមាននៅក្នុង ការបង្រៀនសាសនា។ | អនុវត្តកម្មវិធីដែលមាន គោលបំណងផ្លាស់ប្តូរ ទម្លាប់ រើសអើងយេនឌ័រ (ឧ. បញ្ចូលការពិភាក្សា អំពីការរើស អើងដែលមាន មូលដ្ឋានផ្អែកលើយេនឌ័រ និងអំពើហិង្សា ទៅក្នុងកម្ម វិធីសិក្សាក្នុងសាលារៀន កម្មវិធីវិជ្ជមានដូចជា ក្លឹប កុមារី)។ | អនុវត្តកម្មវិធីដែលមាន គោលបំណងលើកកម្ពស់ ការយល់ដឹង អំពីច្បាប់ ដែលហាមឃាត់ចំពោះ អំពើហិង្សាលើកុមារ និង កសាង សមត្ថភាព របស់មន្ត្រីនគរបាល បុគ្គលិកសង្គមកិច្ច អយ្យការ ប្រព័ន្ធតុលាការ និង គ្រូបង្រៀន ដើម្បីចូល រួមក្នុងការអនុវត្តច្បាប់។ | អនុវត្តកម្មវិធីដែលផ្តល់ កិច្ចគាំទ្រផ្នែក ច្បាប់ សេវា ស្តារនីតិ សម្បទា និង ជំនាញ បំណិនជីវិត សម្រាប់ជនរងគ្រោះនៃ អំពើរំលោភបំពាន។ | បង្កើតប្រព័ន្ធការពារកុមារ មួយទូទាំងប្រទេសដែល មានភាពពាក់ព័ន្ធទៅនឹង បរិបទរបស់ប្រទេសកម្ពុជា និងមានលក្ខខណ្ឌស្រប តាមបទដ្ឋានអន្តរជាតិ។ កសាងឆន្ទៈនយោបាយ ព្រមទាំងសមត្ថភាពផ្នែក ច្បាប់ និងសមត្ថភាព ស្ថាប័ន ដើម្បីបង្ការ និង ឆ្លើយតបទៅនឹងអំពើ ហិង្សាលើកុមារ។ |
| **កត្តាកំណត់** | ភាពក្រីក្រ និង វិសមភាព ផ្នែកសង្គម-សេដ្ឋកិច្ច | ការអប់រំ | ទម្លាប់ដែលគាំទ្រដល់ការ អនុវត្តន៍វិន័យបែបហិង្សា | ទម្លាប់រើសអើង យេនឌ័រ | និទណ្ឌភាព/ខ្វះការយល់ ដឹងអំពីច្បាប់ | បទពិសោធន៍កន្លងមក ទាក់ទងនឹងអំពើហិង្សា[57] | ខ្វះសេវា |
| **ភស្តុតាង** | ការត្រួតពិនិត្យឯកសារលក្ខណៈជាប្រព័ន្ធ និង ការវិភាគទៅលើកម្រងទិន្នន័យស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជាដែលមានស្រាប់ ។ | | | | | | |
| **បញ្ហា** | កុមារី និងកុមារដែលទទួលរងផលប៉ះពាល់ពីទម្រង់ផ្សេងៗគ្នានៃអំពើហិង្សា និង ការគំរាមកំហែងចំពោះអំពើហិង្សា នៅផ្ទះ សាលារៀន និងសហគមន៍ ដែលរំលោភបំពានទៅលើសិទ្ធិរបស់ពួកគេ ក្នុងការទទួលបានបូរណភាពផ្លូវកាយ និង សិទ្ធិទទួលបានកិច្ចការពារ ព្រមទាំងនាំឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើសិទ្ធិមួយចំនួនដទៃទៀត ដែលរួមមានជាអាទិ៍ សិទ្ធិទទួលបានការអប់រំ និង សិទ្ធិក្នុងការ អភិវឌ្ឍសក្តានុពលរបស់ពួកគេឱ្យបានពេញលេញ។ | | | | | | |

រាល់ឧបសគ្គ និង កត្តារាំងស្ទះទាំងអស់ដែលបានកំណត់រកឃើញត្រូវបានធ្វើការដោះស្រាយ គ្រប់ជ្រុងជ្រោយ រាជរដ្ឋាភិបាលកម្ពុជាបន្តប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវបឋមចំពោះការបង្ការ និងការឆ្លើយតបនឹងអំពើហិង្សាលើកុមារ ការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាត្រូវបានកំណត់ និង បែងចែកច្បាស់លាស់

កត្តាកំណត់នៃអំពើហិង្សាលើកុមារដែលត្រូវបានកំណត់រកឃើញត្រូវបានសន្និដ្ឋានថាមានប្រតិបត្តិការក្នុងលក្ខណៈស្រដៀងគ្នានៅក្នុងបរិបទផ្សេងៗគ្នានៅថ្នាក់តំបន់និងថ្នាក់មូលដ្ឋានដើម្បីឱ្យការសន្និដ្ឋានអំពីអាទិភាពបង្ការ និងឆ្លើយតប អាចត្រូវបានធ្វើឡើងជាទូទៅនៅកម្រិត ថ្នាក់ជាតិ។ ប៉ុន្តែ បើទោះជាដូច្នេះក្តីអន្តរាគមន៍ ជាក់ស្តែងត្រូវបានគេសន្និដ្ឋានថាផ្តល់ជូនស្របទៅតាមបរិបទក្នុងមូលដ្ឋាន។

56 សម្រាប់កិច្ចពិភាក្សាលម្អិតជាងនេះអំពីការផ្តួចផ្តើមបង្ការ និងឆ្លើយតបសំខាន់ៗនៅកម្រិតគ្រួសារ សាលារៀន សហគមន៍ និងរដ្ឋាភិបាល សូមមើលផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា។ ផែនការសកម្មភាពនេះ ក៏រួមមានសកម្មភាពសំខាន់ៗមួយចំនួនផងដែរ ដែលត្រូវអនុវត្តន៍ ទាក់ទងនឹងកំណែទម្រង់ច្បាប់ និង/ឬ ការត្រួតពិនិត្យ/ការប្រមូលទិន្នន័យ។

57 ភស្តុតាងដែលមានស្រាប់បានឱ្យដឹងថា ការដែលកុមារធ្លាប់ជួបប្រទះអំពើហិង្សាកន្លងមក ធ្វើឱ្យកុមារមានការប្រឈមកាន់តែខ្ពស់ទៅនឹងការក្លាយជាជនរងគ្រោះម្តងទៀត ព្រមទាំងទំនងនឹងធ្វើឱ្យកុមារប្រព្រឹត្ត អំពើហិង្សានៅពេលក្រោយមកទៀតនៅក្នុងជីវិតរបស់ពួកគេ (ពេលដែលពួកគេក្លាយជាមនុស្សពេញវ័យ)។

Government of Canada Gouvernement du Canada

Together for girls
Ending violence against children

unicef
ដើម្បីកុមារគ្រប់រូប